**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences de Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# វិធានគតិយុត្តស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិកនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **ឈុន សេននាង**

ក. **ត្រាង ធារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ **ម៉ាន់ គីមឡេង**

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université  Royale de Droit et des Sciences de Économiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# វិធានគតិយុត្តស្តីពាណិជ្ជកម្មតាមប្រព័ន្ធ
# អេឡិចត្រូនិកនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **ឈុន សេននាង**

ក. **ត្រាង ឆារ៉ា**

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ **ម៉ាន់ គីមឡេង**

| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | |
| ជំនាន់ទី ២១ | |
| ឆ្នាំចូលសិក្សា | ២០១៧ |
| ឆ្នាំសរសេរសារណា | ២០២១ |

# សេចក្ដីថ្លែងអំណរគុណ

ᨀᨁᨂ

យើងខ្ញុំឈ្មោះ **ត្រាន ឆាវ៉ា** និង **ឈុន សេនឆាន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២១ រៀនក្រុម $L_4A_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖**

លោកឪពុក អ្នកម្ដាយ ជាអ្នកមានគុណទាំងទ្វេដែលបានផ្ដល់កំណើត និងព្យាយាមយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងការចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងផ្នែកស្មារតី និងសម្ភារៈ ថែមទាំងបានអប់រំប្រៀនប្រដៅផ្ដល់ដំបូន្មានល្អៗ និងលើកទឹកចិត្តដល់កូនគ្រប់ពេលវេលា ព្រមទាំងអាធ្យាស្រ័យរាល់កំហុសខុសឆ្គងរបស់កូនដែលកើតមានឡើងកន្លងមក។ បើពុំមានអ្នកមានគុណទាំងពីរ និងសមាជិកក្រុមគ្រួសារលើកទឹកចិត្តឱ្យយើងខ្ញុំរៀនសូត្រតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សាបានខ្ពង់ខ្ពស់នោះទេ យើងខ្ញុំពិតជាគ្មានថ្ងៃនេះឡើយ។

ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ថែមទាំងជួយសម្រួលគ្រប់បញ្ហាដែលកើតមានឡើងក្នុងការសិក្សាតាំងពីឆ្នាំមូលដ្ឋានរហូតដល់បច្ចុប្បន្ន។ ជាងនេះទៅទៀត យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះបុគ្គលិកជាច្រើនរូបនៅក្នុងសាកលវិទ្យាល័យដែលបានរៀបចំឱ្យទីធ្លា និងបរិស្ថានសាលាមានអនាម័យ សន្តិសុខខ្ពស់។

លោកសាស្ត្រាចារ្យ **ម៉ាន់ គីមឡេខ** ដែលមិនត្រឹមតែបង្ហាត់បង្រៀនយើងខ្ញុំប៉ុណ្ណោះទេ ថែមទាំងចំណាយពេលវេលាដ៏មានតម្លៃ ចំណាយទាំងកម្លាំងកាយចិត្តក្នុងការជួយពន្យល់ណែនាំ ផ្ដល់យោបល់ និងកែលម្អស្នាដៃសារណាបញ្ចប់ការសិក្សានេះ។ ដោយមានការជ្រោមជ្រែងយ៉ាងពេញទំហឹងពីលោកសាស្ត្រាចារ្យទើបធ្វើឱ្យការសរសេរសារណារបស់យើងខ្ញុំបានបញ្ចប់ទៅជាស្ថាពរដោយរលូន និងប្រកបដោយជោគជ័យ។

ជាចុងបញ្ចប់យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធទាំងអស់នៅក្នុងប្រទេសកម្ពុជា សូមឱ្យជួយថែរក្សាការពារដល់អ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ឱ្យជួបប្រទះនូវពុទ្ធទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជៀសផុតពីជំងឺសាហាវទាំងឡាយ។

# អារម្ភកថា

ក្រុមយើងខ្ញុំពិតជាមានសេចក្តីសោមនស្សក្នុងការស្រាវជ្រាវលើប្រធានបទស្តីពី វិធានគតិយុត្តស្តីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា។ កិច្ចការស្រាវជ្រាវនេះ កើតចេញពីការខិតខំប្រឹងប្រែងព្យាយាមរបស់យើងខ្ញុំទាំងពីរ ក្រោមការដឹកនាំប្រកបដោយការយកចិត្តទុកដាក់ខ្ពស់បំផុតពីសំណាក់លោកសាស្ត្រាចារ្យ **ម៉ាន់ គីមឡេង**។ នៅក្នុងការស្រាវជ្រាវលើប្រធានបទនេះ ពិតជាមិនភាពងាយស្រួលឡើយ ដោយហេតុថាការស្រាវជ្រាវនេះទាមទារនូវការស្វែងរកឯកសារពិគ្រោះទាំងក្នុងស្រុក និងបរទេសជាច្រើនដែលអាចជឿទុកចិត្តបានដើម្បីយកមកធ្វើការតាក់តែងអត្ថបទជាលាយលក្ខណ៍អក្សរ។ ការស្រាវជ្រាវមួយនេះបានបង្កើនចំណេះដឹងយ៉ាងច្រើនដល់យើងខ្ញុំទាំងពីរនាក់អំពី វិធានគតិយុត្តស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាដែលមានដូចជា៖ សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក របបគតិយុត្តិទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក ព្រមទាំងអត្ថប្រយោជន៍ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ក្រុមយើងខ្ញុំបានធ្វើការសម្រេចចិត្តជ្រើសរើសនូវប្រធានបទនេះ ក្រោយកត់សម្គាល់ពីសន្ទុះរីករាលដាលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសកម្ពុជា និងក្នុងបណ្តាប្រទេសនានាក្នុងពិភពលោកក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ក្រុមយើងខ្ញុំបានធ្វើការសម្រេចចិត្តជ្រើសរើសនូវប្រធានបទនេះ ក្នុងគោលបំណងឱ្យអ្នកអានស្វែងយល់កាន់តែច្បាស់ពីទំនាក់ទំនងពាណិជ្ជកម្មអេឡិចត្រូនិក រួមផ្សំដោយការបកស្រាយតាមច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកជាគោល។ លើសពីនេះយើងខ្ញុំសង្ឃឹមថាការចងក្រងសារណាបញ្ចប់ការសិក្សានេះអាចចូលរួមចែកជាចំណេះដឹង និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរបបគតិយុត្តទាក់ទងនឹងពាណិជ្ជកម្មនេះដល់និស្សិត និងមិត្តៗអ្នកអាន។

ដោយសារនេះគឺជាស្នាដៃដំបូងរបស់យើងខ្ញុំ ហើយថ្វីត្បិតតែយើងខ្ញុំបានខិតខំស្រាវជ្រាវប្រកបដោយការយកចិត្តទុកដាក់បំផុតក្តី ក៏ការបកស្រាយរមែងចៀសមិនផុតពីការខ្វះខាត ដែលកើតមានឡើងដោយអចេតនាក្រោមប្រការណាមួយដូចជា ការប្រើប្រាស់ពាក្យពេចន៍ ឃ្លាឃ្លោងឆ្គាំឆ្គង ឬកំហុសខុសឆ្គងផ្នែកអក្ខរាវិរុទ្ធជាដើម។ ហេតុដូចនេះហើយ យើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងនៅក្នុងអត្ថបទខាងក្រោម។ យើងខ្ញុំសូមធ្វើការស្វាគមន៍ជានិច្ចនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់អ្នកអាន និងអ្នកស្រាវជ្រាវទាំងឡាយដោយសេចក្តីសោមនស្សរីករាយ ដើម្បីយកមកពិចារណា និងធ្វើឱ្យខ្លឹមសារសារណានេះកាន់តែមានន័យជាងនេះមួយកម្រិតទៀត។

## មាតិកា

ទំព័រ

**សេចក្តីផ្តើម** .......................................................................... ១

**ជំពូកទី១**

**សញ្ញាណទូទៅ នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

**១.១ ប្រវត្តិនៃពាណិជ្ជកម្មអេឡិចត្រូនិក និងនិយមន័យ** .......................................... ៤

១.១.១ ប្រវត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ................................................ ៤

១.១.២ និយមន័យពាណិជ្ជកម្មអេឡិចត្រូនិក .......................................................... ៧

ក. និយមន័យតាមច្បាប់អន្តរជាតិ ............................................................ ៧

ខ. និយមន័យតាមច្បាប់ជាតិ ................................................................... ៨

**១.២ភាពខុសគ្នារវាងពាណិជ្ជកម្មបែបប្រពៃណី និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**១០

១.២.១ ពាណិជ្ជកម្មតាមបែបប្រពៃណី............................................................ ១០

១.២.២ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ...................................................... ១១

ក. ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក............ ១១

ខ. ដំណើរការបញ្ជាទិញទំនិញតាមប្រព័ន្ធអេឡិចត្រូនិក ........................................ ១១

គ. ស្ថានភាពជាក់ស្តែងនៃដំណើរការពាណិជ្ជកម្មប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា............. ១១

ឃ. អន្តរការី និងបុគ្គលផ្តល់សេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក.................... ១២

**១.៣លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក**......១២

**ជំពូកទី២**

**របបគតិយុត្តទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក**

**២.១ សុពលភាពទំនាក់ទំនងពាណិជ្ជកម្មអេឡិចត្រូនិក**.......................................... ២០

**២.២ ទំនាក់ទំនងព័ត៌មានក្នុងពាណិជ្ជកម្មអេឡិចត្រូនិក**........................................ ២១

២.២.១ ការបញ្ជូនចេញនៃព័ត៌មាន ............................................................. ២១

២.២.២ ការទទួលព័ត៌មាន.......................................................................... ២២

**២.៣ ការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក**............................................ ២២

២.៣.១ សញ្ញាណទូទៅនៃការបង្កើតកិច្ចសន្យា ........ ២៣
ក. សំណើ ........ ២៣
ខ. ស្ទីការ ........ ២៤
២.៣.២ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិសម្រាប់បង្កើតកិច្ចសន្យា ........ ២៥

**ជំពូកទី៣**

**អត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

**៣.១ អត្ថប្រយោជន៍** ........ ២៦
៣.១.១ ចំពោះអតិថិជន ........ ២៧
៣.១.២ ចំពោះពាណិជ្ជករ ........ ២៧
៣.១.៣ ចំពោះសេដ្ឋកិច្ច ........ ២៨
**៣.២ បញ្ហាប្រឈមទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ២៨
៣.២.១ បទល្មើសផ្សេងៗដែលកើតមានក្នុងពាណិជ្ជកម្មអេឡិចត្រូនិក ........ ២៨
ក. ការលួចប្រើប្រាស់អត្តសញ្ញាណ ........ ២៨
ខ. ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំ និងកូដព្យាបាទ ........ ២៩
៣.២.២ បញ្ហាប្រឈម និងកង្វល់របស់សហគ្រាស និងភាគីពាក់ព័ន្ធ ........ ២៩
ក. បញ្ហាប្រឈមរបស់សហគ្រាស ........ ២៩
ខ. កង្វល់របស់ភាគីពាក់ព័ន្ធ ........ ៣០
**៣.៣ លទ្ធផលសម្រេចបានឆ្នាំ២០២០ និងគោលដៅយុទ្ធសាស្ត្រឆ្នាំ២០២១របស់ក្រសួងពាណិជ្ជកម្ម** ........ ៣១
៣.៣.១ លទ្ធផលសម្រេចបានឆ្នាំ២០២០ ........ ៣១
៣.៣.២ គោលដៅយុទ្ធសាស្ត្រឆ្នាំ២០២១ ........ ៣២
**សេចក្តីសន្និដ្ឋាន** ........ ៣៤
**អនុសាសន៍** ........ ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce សំដៅលើសកម្មភាពទិញលក់ទំនិញ និងទូទាត់សេវាកម្មតាមរយៈប្រព័ន្ធអ៊ិនធឺណិត។ វត្តមាននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានឡើងបន្តិចម្តងៗ ស្របពេលដែលប្រទេសកម្ពុជាកំពុងតែអភិវឌ្ឍឥតឈប់ឈរ។ ក្នុងឱកាសដែលសេដ្ឋកិច្ចរបស់ប្រទេសកាន់តែរីកចម្រើន ចំនួនប្រជាជនដែលប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ជាពិសេសទូរស័ព្ទដៃទំនើប និងប្រើប្រាស់អ៊ិនធឺណិតក៏មានការកើនឡើងជាលំដាប់។ ទន្ទឹមនឹងនេះដែរ សកម្មភាពពាណិជ្ជកម្មតាមបណ្តាញផ្សព្វផ្សាយសង្គម ធ្វើឱ្យមានការលេចឡើងនៃសហគ្រិនខ្នាតមីក្រូដែលធ្វើពាណិជ្ជកម្មជាលក្ខណៈអតិថិជនទៅអតិថិជន។ ក្រៅពីនេះ គេក៏សង្កេតឃើញថាមានក្រុមហ៊ុនពាណិជ្ជកម្មតាមអេឡិចត្រូនិកជាច្រើន ទាំងក្រុមហ៊ុនជាតិ និងអន្តរជាតិបានលេចឡើងក្នុងផ្នែកផ្សេងៗនៃប្រព័ន្ធអេកូឡូហ្ស៊ីនៃពាណិជ្ជកម្មតាមអេឡិចត្រូនិក ហើយផ្នែកមួយដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស គឺប្រព័ន្ធទូទាត់ប្រាក់តាមប្រព័ន្ធទូរស័ព្ទចល័តក្នុងសម័យកាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

លើសពីនេះ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាប្រធានបទដែលសំខាន់ក្នុងការចរចាព្រមព្រៀងពាណិជ្ជកម្មនានាក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក គួបផ្សំនឹងស្ថានភាពនៃការលូតលាស់របស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅបណ្តាប្រទេសនានានៅក្នុងអាស៊ាន ក៏ដូចជាប្រទេសជាច្រើនក្នុងពិភពលោក ក្នុងនាមជាសមាជិកនៃអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសកម្ពុជាចាំបាច់ត្រូវរៀបចំខ្លួនដើរឱ្យទាន់ការវិវត្តន៍របស់ពិភពលោកដោយរៀបចំឱ្យមានច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ក្រោយរយៈកាលជាងមួយទសវត្ស ក្រសួងពាណិជ្ជកម្មប្រទេសកម្ពុជាបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយជោគជ័យក្នុងឆ្នាំ២០១៦ ដោយយកគំរូតាមច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ ១៩៩៨ (UNCITRAL Model Law on Electronic Commerce, 1998)។ នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានរដ្ឋសភាអនុម័តជាស្ថាពរ និងប្រកាសឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រឡាយព្រះហស្តលេខានាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានកំណត់និយមន័យ និងប្បញ្ញត្តិអំពីល័ក្ខខ័ណ្ឌសំខាន់ៗអំពីទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងបញ្ជ្រាបពីសញ្ញាណនៃពាណិជ្ជកម្មនេះទៅប្រជាជន។ ជាងនេះទៅទៀត គោលដៅនៃការបង្កើតច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺដើម្បីជាមូលដ្ឋានដ៏សំខាន់មួយក្នុងការជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុង និងក្រៅប្រទេសប្រកបដោយទំនុកចិត្ត តាមរយៈការទទួលស្គាល់សុពលភាព អានុភាព ភាពអាចអនុវត្តបាន និងភាពអាចទទួលយកបាននៃទំនាក់ទំនងអេឡិចត្រូនិក កំណត់ត្រាអេឡិចត្រូនិក និងកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក។ ច្បាប់នេះ នឹងរួមចំណែកក្នុង

ការអភិវឌ្ឍន៍វិស័យឌីជីថលនៅប្រទេសកម្ពុជាប្រកបដោយចីរភាព ស្របពេលដែលកម្ពុជាកំពុងឈានទៅរកបដិវត្តន៍ឧស្សាហកម្ម៤.០ ដែលអាចនាំមកនូវកាលានុវត្តភាពអាជីវកម្មថ្មីៗយ៉ាងច្រើនសម្រាប់សហគ្រិនវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ក្នុងការចូលរួមពង្រីកកំណើនសេដ្ឋកិច្ចជាតិ។

ទោះបីជាមានការយកចិត្តទុកដាក់ក្នុងការតាក់តែងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកយ៉ាងណាក្តី បញ្ហាប្រឈមនៅតែត្រូវបានគេមើលឃើញ ដូចនេះហើយទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធព្រមទាំងតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលសមស្របមួយដើម្បីធានាឱ្យបានថា អាចដើរទាន់បណ្តាប្រទេសដទៃទៀតនៅក្នុងពិភពលោកដែលមានប្រព័ន្ធគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកយ៉ាងជឿនលឿន ដូចជាប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូងជាដើម។ មួយវិញទៀតថ្វីត្បិតតែមានការដុះដាលយ៉ាងឆាប់រហ័សនៃសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្តី របត់ពាណិជ្ជកម្មនេះនៅជាគំនិតមួយដែលថ្មីនៅឡើយ ហើយការយល់ដឹងអំពីច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅមានកម្រិតក្នុងចំណោមប្រជាជនទូទៅ ដែលចាំបាច់ទាមទារការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវខ្លឹមសារ និងវិធាននានាដែលបានចែងនៅក្នុងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីធានាថាការអនុវត្តច្បាប់នេះមានប្រសិទ្ធភាព។

អាស្រ័យដូចបានរៀបរាប់ខាងលើ សារណាស្តីពីវិធានគតិយុត្តស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា នឹងសិក្សាឱ្យបានស៊ីជម្រៅទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ថាតើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាមានប្រវត្តិកកើតយ៉ាងដូចម្តេច តើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមាននិយមន័យដូចម្តេច របបគតិយុត្តនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានលក្ខណៈយ៉ាងណាខ្លះ ហើយតើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានអត្ថប្រយោជន៍ និងបញ្ហាប្រឈមយ៉ាងដូចម្តេចខ្លះ?

ការសិក្សាក្នុងសារណានេះ មិនរំពឹងថានឹងអាចសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ ដោយសារតែពេលវេលាក្នុងការស្រាវជ្រាវមានកំណត់ ម្យ៉ាងទៀតឯកសារស្រាវជ្រាវទៀតសោតក៏មិនមានភាពទូលំទូលាយ។ ដូចនេះសារណានេះត្រូវបានរៀបរៀងជាបីជំពូក ដោយជំពូកទី១រៀបរាប់ពីសញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រួមមានបកស្រាយអំពីប្រវត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងនិយមន័យ ភាពខុសគ្នារវាងពាណិជ្ជកម្មតាមបែបប្រពៃណី និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងលិខិតបទដ្ឋានផ្សេងៗដែលទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ជំពូកទី២សិក្សាស៊ីជម្រៅអំពីរបបគតិយុត្តិទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក ដោយផ្តោតសំខាន់ទៅលើសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក ទំនាក់ទំនងពត៌មានក្នុងពាណិជ្ជកម្មអេឡិចត្រូនិក និងការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក។ ជំពូកទី៣ ពិភាក្សាអំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ដោយសិក្សាលើអត្ថប្រយោជន៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងកង្វល់របស់អ្នកប្រើប្រាស់ ព្រមទាំងមានលើកយកពីបទល្មើសដែលកើតមានឡើងក្នុងពាណិជ្ជកម្មអេឡិចត្រូនិក និងលទ្ធផលដែលសម្រេចបានឆ្នាំ ២០២០ និងគោលដៅយុទ្ធសាស្ត្រឆ្នាំ២០២១ របស់ក្រសួងពាណិជ្ជកម្ម។

# ជំពូកទី១
# សញ្ញាណទូទៅ នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា ៦០ បានបញ្ញត្តិថា ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី។ ក្នុងបញ្ញត្តិនេះបានសឱ្យឃើញថា កម្ពុជាប្រកាន់លើគោលការណ៍ទីផ្សារសេរីដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើពាណិជ្ជកម្មដោយសេរី។ ជាក់ស្តែង ក្នុងរយៈពេលមួយទសវត្សកន្លងទៅការរីកដុះដាលនៃទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសន្ទុះលឿនគួរឱ្យកត់សម្គាល់។ វត្តមាននិងការរាតត្បាតនៃជំងឺកូវីដ-១៩ ទូទាំងសកលលោកទៀតសោតបានពន្លឿនសន្ទុះនេះកាន់តែខ្លាំងឡើងទាំងក្នុងទីផ្សារប្រទេសកម្ពុជា និងអន្តរជាតិ ជាពិសេសនៅក្នុងវិស័យឯកជន។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានទម្រង់បែបបទមិនខុសគ្នាប៉ុន្មានទេនៅក្នុងពិភពលោក តែច្បាប់ដែលគ្រប់គ្រងពាណិជ្ជកម្មប្រភេទនេះមានលក្ខណៈខុសគ្នាទៅតាមបរិបទនៃប្រទេសនីមួយៗ។ នៅក្នុងជំពូកនេះ យើងនឹងសិក្សាអំពីប្រវត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងនិយមន័យ (១.១) ភាពខុសគ្នារវាងពាណិជ្ជកម្មតាមបែបប្រពៃណី និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១.២) និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក (១.៣)។

## ១.១ ប្រវត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងនិយមន័យ

### ១.១.១ ប្រវត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានលេចរូបរាងឡើងដំបូង នាពាក់កណ្តាលសតវត្សទី១៨ ស្របពេលទៅនឹងការបង្កើតកិច្ចសន្យាដំបូងបំផុតដោយប្រើប្រាស់ម៉ាស៊ីនទូរលេខ និងទូរស័ព្ទ។ ក្រោយមកនៅឆ្នាំ ១៩៥០ ប្រព័ន្ធអ៊ីធើណែតបានក្លាយជាវិធីដែលសមស្របមួយដែលជំរុញឱ្យមានប្រតិបត្តិការនៃទំនិញ សេវា និងផ្ទេរទិន្នន័យព័ត៌មាន។ នៅឆ្នាំ ១៩៦០ កិច្ចប្រតិបត្តិការធនាគារតាមប្រព័ន្ធអេឡិចត្រូនិកក៏កើតមានឡើង។

នៅឆ្នាំ១៩៩៦ គណៈកម្មការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ (United Nations Commission on International Trade Law "UNCITRAL") បានអនុម័តច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Electronic Commerce) ក្នុងគោលបំណងដើម្បីសម្រួលដល់មធ្យោបាយទំនើបក្នុងការទំនាក់ទំនង និងការផ្ទុកនូវព័ត៌មាន ដូចជាការផ្លាស់ប្តូរទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Data Exchange) ដោយសារអេឡិចត្រូនិកដោយអាចប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ឬមិនប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត។ គោលការណ៍ចម្បងដែលមានក្នុងច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺ មាត្រា ៥ ដែលចែងអំពី "ភាពស្មើគ្នានៃទម្រង់អេឡិចត្រូនិក (Electronic equivalence)"។ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០០ ក្រុមការងារនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់គណៈកម្មការច្បាប់ពាណិជ្ជកម្ម

អន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNCITRAL Working Group on Electronic Commerce) បានឯកភាពលើច្បាប់គំរូស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Signatures) នៅក្នុងកិច្ចប្រជុំលើកទី៣៧ របស់ខ្លួននៅក្នុងទីក្រុងហ្សឺណែវ។ ច្បាប់គំរូស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិកចូលជាធរមាននៅក្នុងឆ្នាំ២០០១។ បន្ថែមពីនេះ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥ មហាសន្និបាតរបស់អង្គការសហប្រជាជាតិ (United Nations General Assembly) បានអនុម័តសន្និសញ្ញាស្តីពីការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកនៅក្នុងកិច្ចសន្យាអន្តរជាតិ (The United Nations Convention on the Use of Electronic Communications in International Contracts 'The Electronic Communications Convention" or "ECC") ដែលរៀបចំឡើងដោយគណៈកម្មការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNCITRAL) ក្នុងគោលបំណងសម្រួលដល់ការប្រើប្រាស់ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងពាណិជ្ជកម្មអន្តរជាតិ។ សន្និសញ្ញានេះត្រូវបានបង្កើតឡើងពីព្រោះទោះបីជា ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Electronic Commerce) និងច្បាប់គំរូស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Signatures) ត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៦ និងឆ្នាំ១៩៩៨ ប៉ុន្តែបញ្ហាមួយចំនួននៅតែមិនទាន់ត្រូវបានដោះស្រាយ។ ហេតុនេះហើយ សន្និសញ្ញាមួយទៀតក៏ត្រូវបានអនុម័តគឺសន្និសញ្ញាស្តីពីការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកនៅក្នុងកិច្ចសន្យាអន្តរជាតិ (The United Nations Convention on the Use of Electronic Communications in International Contracts)។

ប្រទេសកម្ពុជា បានដាក់ពាក្យស្នើសុំចូលជាសមាជិកនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកជាដំបូងនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៤ ។ ក្រុមការងារពិនិត្យការចូលជាសមាជិករបស់កម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ។ រហូតដល់ឆ្នាំ១៩៩៧ ទើបយើងអាចនៅធ្វើកិច្ចការចាំបាច់មួយចំនួនដើម្បីកំណត់ដំណើរការចរចារនៃការសុំចូលជាសមាជិកបាន។ រដ្ឋមន្ត្រីមកពីសមាជិកចំនួន ១៤៧ របស់អង្គការពាណិជ្ជកម្មពិភពលោក បានទទួលយកល័ក្ខខ័ណ្ឌនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជានៅក្នុងខែកញ្ញា ឆ្នាំ២០០៣។ រយៈពេល ៩ឆ្នាំគិតចាប់ពីការដាក់ពាក្យដំបូងកម្ពុជាបានអនុម័តរាល់ល័ក្ខខ័ណ្ឌទាំងអស់ហើយសមាជិកភាពជាក់ស្តែងគ្រាន់តែតម្រូវឱ្យមានការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ ពីរដ្ឋសភាកម្ពុជាតែប៉ុណ្ណោះ។ កម្ពុជាបានទទួសច្ចាប័ននេះកាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ ហើយកម្ពុជាបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកជាផ្លូវការក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីការទទួលបានសច្ចាប័ននេះ ពោលគឺនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។

ដំណើរការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក គឺជាដំណើរការដែលមានរយៈពេលវែង និងស្មុគស្មាញ។ ការចូលជាសមាជិកនេះ គឺជាកិច្ចសន្យាដែលមានចំណងច្បាប់ជាផ្លូវការរវាងសមាជិកទាំង

អស់ជាមួយសមាជិកថ្មី។ កិច្ចសន្យានេះបញ្ជាក់អំពីល័ក្ខខ័ណ្ឌលម្អិតនៃពាណិជ្ជកម្មរវាងសមាជិកនានា និង បញ្ជាក់អំពីការយល់ដឹងលើទិដ្ឋភាពជាច្រើននៃច្បាប់ នីតិកម្ម ដំណើរការតុលាការ និងល័ក្ខខ័ណ្ឌវិនិយោគ។ សមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោកតម្រូវឱ្យកម្ពុជាបំពេញការងារជាច្រើន ក្នុងការបង្កើតឱ្យមាននូវ ក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងពាណិជ្ជកម្មឱ្យបានគ្រប់គ្រាន់។ រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមយ៉ាងសកម្ម ក្នុងការបង្កើត និងដាក់ជូនសភាជាតិនូវច្បាប់សំខាន់ៗ ដែលមានលក្ខណៈទំនើបសេរី និងត្រឹមត្រូវសម្រាប់ គ្រប់គ្រងការធ្វើពាណិជ្ជកម្ម។ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ប្រទេសមួយត្រូវតែមានច្បាប់ គ្រប់គ្រងការធ្វើពាណិជ្ជកម្មស្របជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក។ កម្ពុជាយល់ស្រប ជាមួយលក្ខណៈបែបនេះ និងយល់ថាជាការចាំបាច់ហើយបានស្វាគមន៍តម្រូវការទាំងឡាយ និងជំរុញឱ្យកម្ពុជា បង្កើនល្បឿនក្នុងការបង្កើតឱ្យមាននូវក្របខណ្ឌច្បាប់មួយសម្រាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម ដែលសមស្រប តាមស្តង់ដារអន្តរជាតិ។ កិច្ចសន្យានេះបានផ្តល់ឱ្យកម្ពុជានូវប្រយោជន៍ ព្រមទាំងសុវត្ថិភាពទាក់ទងទៅនឹងវិធាន និងវិន័យដែលបង្កើតជាប្រព័ន្ធច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកដែលចែងអំពីសកម្មភាពរបស់សមាជិក ទាំងអស់របស់ខ្លួន។

ងាកមកមើលស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាវិញ ប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាល អភិវឌ្ឍមួយដែលសន្ទុះនៃការប្រើប្រាស់បច្ចេកវិទ្យាដូចជាទូរស័ព្ទចល័តទំនើប និងអ៊ិនធឺណិតមានការកើនឡើង ក្នុងមួយទសវត្សកន្លងទៅនេះ។ ស្របពេលដែលទំហំពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាកំពុងតែ កើនឡើង សហគ្រាស និងអ្នកប្រើប្រាស់បានទាមទារឱ្យមានក្របខ័ណ្ឌច្បាប់ជាក់លាក់ដែលកំណត់នូវសិទ្ធិ និង ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ដូចជា ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន (Cyber Law) កិច្ចការពារអ្នកប្រើប្រាស់ កិច្ចការពារទិន្នន័យ ការប្រកួតប្រជែងជាដើម។

មុននឹងមានច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រទេសកម្ពុជាមានសេចក្តីព្រាងច្បាប់ពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលសេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំតាំងពីឆ្នាំ២០០៤ មកដោយ ក្រសួងពាណិជ្ជកម្មដែលទទួលបានថវិកាឧបត្ថម្ភពីកម្មវិធីគាំទ្រកិច្ចអភិវឌ្ឍពាណិជ្ជកម្ម (TDSP)[1] ផ្តល់ដោយ ម្ចាស់ជំនួយពហុភាគី។ សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើងដើម្បីជួយសម្រួល និងគ្រប់គ្រងប្រតិបត្តិការ ពាណិជ្ជកម្មតាមប្រព័ន្ធអ៊ិនធឺណិតដោយយកតាមលំនាំតាមច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់

[1] ព្រះរាជាណាចក្រកម្ពុជា បានទទួលមូលនិធិក្នុងចំនួនទឹកប្រាក់ ១៥.៤៥លាន ដុល្លារសហរដ្ឋអាមេរិក ពីមូលនិធិម្ចាស់ជំនួយ ពហុភាគី (Multi Donor Trust Fund) (វិភាគទានរបស់គណៈកម្មការ អឺរ៉ុប DANIDA និងUNIDO)។ មូលនិធិនេះគ្រប់គ្រង ដោយធនាគារពិភព លោក (WB) ដែលជា "ភាគីទីបីគ្រប់គ្រងមូលនិធិ (Trustee)" ដើម្បីគាំទ្រដល់កម្មវិធីTDSP។ គោលដៅអភិវឌ្ឍន៍ នៃកម្មវិធី TDSP គឺ ដើម្បីគាំទ្រយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្សព្វផ្សាយអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp)។

គណៈកម្មការអង្គការអន្តរជាតិ (UNCITRAL, ១៩៩៦) និងអនុសញ្ញាសហប្រជាជាតិស្តីពីការប្រើទំនាក់ទំនងអេឡិចត្រូនិកនៅក្នុងកិច្ចសន្យាអន្តរជាតិ (២០០៥)។ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាផ្នែកមួយនៃភាពជោគជ័យរបស់កម្មវិធី TDSP អនុវត្តដោយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) នៃក្រសួងពាណិជ្ជកម្ម។

ក្រោយមក ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ត្រូវបានរៀបចំតាក់តែងឡើង។ ច្បាប់នេះត្រូវបានរៀបចំតាក់តែងក្រោមការដឹកនាំយ៉ាងសកម្មរបស់ក្រសួងពាណិជ្ជកម្ម និងត្រូវបានរដ្ឋសភាអនុម័តជាស្ថាពរក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ យល់ព្រមដោយព្រឹទ្ធសភានៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ហើយត្រូវបានព្រះមហាក្សត្រទ្បាយព្រះហស្តលេខាឱ្យប្រើប្រាស់កាលពីថ្ងៃទី០២ វិច្ឆិកា ឆ្នាំ២០១៩។ ការប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានជួយបំពេញចន្លោះខ្វះខាតផ្នែកច្បាប់ដែលមានសារៈសំខាន់បំផុតក្នុងការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា។

### ១.១.២ និយមន័យពាណិជ្ជកម្មអេឡិចត្រូនិក

មុននឹងឈានដល់ការបកស្រាយស៊ីជម្រៅជាងនេះ យើងគប្បីយល់អំពីនិយមន័យនៃពាក្យគន្លឹះ ពោលគឺនិយមន័យនៃពាក្យ "ពាណិជ្ជកម្មអេឡិចត្រូនិក" ជាមុនសិន។ ដោយយោងតាមវចនានុក្រមភាសាអង់គ្លេសអន្តរជាតិ ពាក្យ *ពាណិជ្ជកម្ម (Commerce)* មានថ្នាក់ពាក្យជានាម មានន័យថា ជាការទិញ និងលក់ទំនិញ និងសេវា។ រីឯពាក្យ *អេឡិចត្រូនិក (Electronic)* មានថ្នាក់ពាក្យជាគុណនាម មានន័យថាជាឧបករណ៍អេឡិចត្រូនិកដែលប្រើបន្ទះឈីប ដែលអាចឆ្លងចរន្តអគ្គីសនីបាន។ បើយោងតាមគេហទំព័រ Investopedia ពាក្យ *ពាណិជ្ជកម្មអេឡិចត្រូនិក (E-commerce)* គឺជា"ការទិញ និងលក់ទំនិញ និងសេវាកម្មតាមអ៊ីនធឺណិតដែលអាចត្រូវបានធ្វើឡើងតាមរយៈកុំព្យូទ័រ ថេប្លេត ឬស្មាតហ្វូន"។[2] ផ្នែកនេះនឹងសិក្សាអំពីនិយមន័យនៃពាក្យពាណិជ្ជកម្មអេឡិចត្រូនិកដោយផ្អែកតាមលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ។

#### ក. និយមន័យតាមច្បាប់អន្តរជាតិ

តាមច្បាប់អន្តរជាតិ *ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* ត្រូវបានគេឱ្យនិយមន័យយ៉ាងទូលំទូលាយផ្សេងៗគ្នាជាច្រើន។ យោងតាមអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ ១៩៩៧ (OECD, 1997) បានកំណត់និយមន័យនៃពាណិជ្ជកម្មអេឡិចត្រូនិកថា ជាគ្រប់ទម្រង់នៃប្រតិបត្តិការពាណិជ្ជកម្មទាំងអស់ដែលជាប់ទាក់ទងទៅនឹងសកម្មភាពជំនួញដោយផ្អែកទៅលើដំណើរការ និងការបញ្ជូនទិន្នន័យឌីជីថលមានទាំងឯកសារសម្លេង និងរូបភាព។

[2] និមយន័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមគេហទំព័រហិរញ្ញវត្ថុ Investopedia

ចំណែកឯនៅក្នុងក្របខ័ណ្ឌអ៊ីអាស៊ាន (E-ASEAN) ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺសំដៅទៅលើប្រតិបត្តិការអេឡិចត្រូនិកនៅលើបណ្តាញអ៊ិនធឺណិត ឬនៅលើបណ្តាញបើកទូលាយផ្សេងទៀត។ ក្របខ័ណ្ឌអ៊ីអាស៊ាន (E-ASEAN) បានបែងចែកប្រតិបត្តិការអេឡិចត្រូនិកទៅជា២ប្រភេទគឺ៖

- ប្រតិបត្តិការទី១៖ ប្រតិបត្តិការដែលពាក់ព័ន្ធទៅនឹងការលក់ទំនិញ ឬសេវារូបិយ។ ក្នុងប្រតិបត្តិការនេះ បណ្តាញអ៊ិនធឺណិត ឬបណ្តាញបើកទូលាយផ្សេងទៀតត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ដាក់បញ្ជាទិញទំនិញ ឬសេវា និងការបង់ប្រាក់។ ប៉ុន្តែសម្រាប់ការបញ្ជូនទំនិញ ឬសេវាទៅកាន់អតិថិជនត្រូវធ្វើឡើងជាធម្មតាដូចពាណិជ្ជកម្មទូទៅដែរ ដែលជាក់ស្តែងគឺបញ្ជូនតាមមធ្យោបាយដឹកជញ្ជូនទំនិញដូចជា រថយន្តជាដើម។
- ប្រតិបត្តិការទី២៖ ប្រតិបត្តិការដែលពាក់ព័ន្ធទៅនឹងការផ្ទេរដោយផ្ទាល់នៅលើបណ្តាញអ៊ិនធឺណិតនូវព័ត៌មានព្រមទាំងទំនិញ និងសេវាដែលមានលក្ខណៈឌីជីថល ឧទាហរណ៍ដូចជា៖ សូហ្វវែរ បទភ្លេង វីដេអូ។ ក្នុងប្រតិបត្តិការនេះបណ្តាញអ៊ិនធឺណិត ឬបណ្តាញបើកទូលាយផ្សេងទៀតត្រូវបានប្រើប្រាស់ជាមធ្យោបាយទំនាក់ទំនង ក៏ដូចជាមធ្យោបាយដោះដូរព័ត៌មាន ទំនិញ និងសេវាក្នុងលក្ខណៈឌីជីថល។ ឧទាហរណ៍ ការជាវបទភ្លេង ឬវីដេអូរបស់ក្រុមហ៊ុន Spotify, Apple Music និង Netflix ដែលតម្រូវឱ្យអតិថិជនបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រើប្រាស់អ៊ិនធើណែត ហើយបន្ទាប់ពីបង់ប្រាក់រួចអតិថិជនអាចស្តាប់ ឬមើលវីដេអូបាននៅពេលតភ្ជាប់នឹងអ៊ិនធឺណិត។

បើយោងតាមច្បាប់ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រទេសជប៉ុនវិញ និយមន័យនៃវាក្យសព្ទ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានឃើញមានកំណត់និយមន័យច្បាស់លាស់ទេ គ្រាន់តែមានចង្អុលបង្ហាញជាទូទៅថា គឺជាការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ឬកុំព្យូទ័រ ឬបណ្តាញប្រព័ន្ធផ្សេងៗក្នុងការទិញលក់ទំនិញ និងសេវាជាដើម ហើយក៏ជាសកម្មភាពសេដ្ឋកិច្ចដែលធ្វើការផ្ទេរ ឬបញ្ជូនប្រាក់ ឬទិន្នន័យ។

**ខ. និយមន័យតាមច្បាប់ជាតិ**

មុនច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនបានផ្តល់និយមន័យន័យជាក់លាក់ណាមួយចំពោះវាក្យសព្ទ *ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* ទេ។ ដោយឡែក គេអាចឱ្យនិយមន័យ *ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* បានដោយបំបែកពាក្យជាពីរ គឺពាក្យ *ពាណិជ្ជកម្ម* និង *ប្រព័ន្ធអេឡិចត្រូនិក*។ គេអាចឱ្យនិយមន័យពាក្យ *ពាណិជ្ជកម្ម* ដោយផ្អែកតាមច្បាប់ស្តីពីមជ្ឈត្តការផ្អែកពាណិជ្ជកម្ម និងកំណត់និយមន័យពាក្យថា *ប្រព័ន្ធអេឡិចត្រូនិក* ដោយផ្អែកលើនិយមន័យដែលមាននៅក្នុងឧបសម្ព័ន្ធសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទំព័រទី ៣២។

ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ បានផ្ដល់និយមន័យចំពោះពាក្យ *ពាណិជ្ជកម្ម* ដោយចែងថា៖

> "ពាក្យថា *ពាណិជ្ជកម្ម* ត្រូវបានបកស្រាយឱ្យបានទូលំទូលាយដើម្បីគ្របដណ្ដប់លើធុរកិច្ចដែលមានប្រភេទពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទិ៍ : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ឬការផ្លាស់ប្ដូរទំនិញ ឬសេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬសម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់វិស្វកម្ម ការចេញអាជ្ញាបណ្ណ ការវិនិយោគទុន ការផ្ដល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក"។[3]

យោងតាមច្បាប់នេះគេអាចសន្និដ្ឋានបានដោយខ្លីថា *ពាណិជ្ជកម្ម* សំដៅទៅដល់សកម្មភាពរបស់បុគ្គល ឬសហគ្រាសក្នុងការផ្គត់ផ្គង់ ឬការផ្លាស់ប្ដូរទំនិញ ឬសេវាផ្សេងៗ ការទិញ លក់ឬជួល ការពិគ្រោះយោបល់ ការផ្ដល់ហិរញ្ញវត្ថុ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្មដូចជា ការដឹកជញ្ជូននានា។

យោងតាមឧបសម្ព័ន្ធនៃសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពាក្យ *ប្រព័ន្ធអេឡិចត្រូនិក (Electronic System)* "សំដៅដល់ឧបករណ៍អេឡិចត្រូនិក ឬទាក់ទងគ្នាតាមរយៈកម្មវិធីអេឡិចត្រូនិកអាចធ្វើឱ្យមានដំណើរការស្វ័យប្រវត្តិនៃទិន្នន័យ និងរួមបញ្ចូលទាំងឧបករណ៍រក្សាទុកបែបអេឡិចត្រូនិក"។[4] *ប្រព័ន្ធអេឡិចត្រូនិក* អាចត្រូវបានពន្យល់ក្នុងន័យសាមញ្ញថា ជាប្រព័ន្ធមួយដែលផ្គុំដោយឧបករណ៍អេឡិចត្រូនិកតភ្ជាប់គ្នា ទាក់ទងគ្នាតាមកម្មវិធីអេឡិចត្រូនិក ក្នុងទម្រង់ម៉ាញេទិច អុបទិច ក្នុងអង្គចងចាំរបស់កុំព្យូទ័រ មីក្រូហ្វីលជាដើម ដើម្បីបង្កើតឱ្យមានដំណើរការស្វ័យប្រវត្តិ និងការរក្សាទុកនៃទិន្នន័យ។

ដូចនេះ តាមនិយមន័យនៃពាក្យខាងលើគេអាចពន្យល់បានថា *ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* ជាការផ្គត់ផ្គង់ ឬការផ្លាស់ប្ដូរទំនិញឬសេវាផ្សេងៗ ការទិញ ការលក់ឬជួល ការពិគ្រោះយោបល់ ការផ្ដល់ហិរញ្ញវត្ថុ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្មផ្សេងៗ ដែលត្រូវបានធ្វើឡើងតាមប្រព័ន្ធមួយដែលផ្គុំដោយឧបករណ៍អេឡិចត្រូនិកតភ្ជាប់គ្នា ហើយទាក់ទងគ្នាតាមកម្មវិធីអេឡិចត្រូនិក ក្នុងទម្រង់ម៉ាញេទិច អុបទិច ក្នុងអង្គចងចាំរបស់កុំព្យូទ័រជាដើម ដើម្បីបង្កើតឱ្យមានដំណើរការស្វ័យប្រវត្តិ និងការរក្សាទុកទិន្នន័យ។

---

[3] មាត្រា ២ ចំណុច ឈ នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[4] ឧបសម្ព័ន្ធសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទំព័រ៣២

ចំណែកឯច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកវិញបានកំណត់និយមន័យនៃពាក្យ *ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* យ៉ាងច្បាស់លាស់នៅក្នុងឧបសម្ព័ន្ធថា "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកៈ សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណី ព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក"។[5] ក្នុងច្បាប់នេះផងដែរក៏បានកំណត់ពីនិយមន័យបន្ថែមសម្រាប់ពាក្យ *ប្រព័ន្ធអេឡិចត្រូនិក* យ៉ាងច្បាស់ផងដែរដូចតទៅ "សំដៅដល់ឧបករណ៍អេឡិចត្រូនិក ឬបណ្តុំឧបករណ៍តភ្ជាប់គ្នា ឬទាក់ទងគ្នា តាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកនៃទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។[6]

ឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏បានពន្យល់ពីពាក្យមួយទៀតដើម្បីពន្យល់ពីអត្ថន័យរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺ *ទម្រង់អេឡិចត្រូនិក* ថា "ទាក់ទងនឹងព័ត៌មាន សំដៅដល់ព័ត៌មានដែលបង្កើត ដែលបានបញ្ជូន ដែលបានទទួល ឬដែលរក្សាទុកក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងទម្រង់ម៉ាញេទិច ក្នុងទម្រង់អុបទិច ក្នុងអង្គចងចាំរបស់កុំព្យូទ័រ ក្នុងមីក្រូហ្វីល ក្នុងកុំព្យូទ័រ ឬឧបករណ៍ដែលមានមុខងារស្រដៀងគ្នា"។

## ១.២ ភាពខុសគ្នារវាងពាណិជ្ជកម្មបែបប្រពៃណី និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ក្រោយពីបានយល់អំពីនិយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមក គេក៏ចាំបាច់ដឹងអំពីភាពខុសគ្នារវាងពាណិជ្ជកម្មតាមបែបប្រពៃណី និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ផ្នែកនេះនឹងសិក្សាអំពីភាពខុសគ្នារវាងពាណិជ្ជកម្មទាំងពីរបែបនេះដោយផ្តោតសំខាន់លើដំណើរប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។

### ១.២.១ ពាណិជ្ជកម្មបែបប្រពៃណី

ពាណិជ្ជកម្មទូទៅត្រូវបានធ្វើឡើងដោយផ្ទាល់រវាងអ្នកលក់ និងអ្នកទិញ ដោយអ្នកលក់ និងអ្នកទិញធ្វើការចរចារពីតម្លៃ ពិនិត្យគុណភាពទំនិញជាក់ស្តែងមុននឹងជាវ ឬបង្ហាញឆន្ទៈដោយឃើញមុខគ្នា។ សម្រាប់ពាណិជ្ជកម្មទូទៅ ដូចដែលមនុស្សគ្រប់គ្នាតែងតែអនុវត្តកន្លងមកទាមទារឱ្យអតិថិជន ឬអ្នកប្រើប្រាស់ធ្វើការបន្លាស់ទីពីហាងមួយទៅហាងមួយបើសិនអតិថិជន ឬអ្នកប្រើប្រាស់ចង់ធ្វើការប្រៀបធៀបតម្លៃ។

### ១.២.២ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

#### ក.ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

[5] ឧបសម្ព័ន្ធច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទំព័រ ii វាក្យស័ព្ទទី១៣

[6] ឧបសម្ព័ន្ធច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទំព័រ iii វាក្យស័ព្ទទី២៣

រូបវន្តបុគ្គល សហគ្រាសឯកបុគ្គលដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។[7] នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ត្រូវដាក់ពាក្យស្នើសុំដូចគ្នាដែរ ដោយត្រូវផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចក្នុងប្រការនៃប្រកាសស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។[8] ពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានក្នុងឧបសម្ព័ន្ធ។

### ខ.ដំណើរការបញ្ជាទិញទំនិញតាមប្រព័ន្ធអេឡិចត្រូនិក

សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកវិញ ការជ្រើសរើសទំនិញ ការចរចារពីតម្លៃ និងការបង្ហាញឆន្ទៈ ពោលគឺសកម្មភាពទាំងឡាយដែលអតិថិជនត្រូវធ្វើដើម្បីទទួលបានទំនិញ ត្រូវបានធ្វើឡើងដោយឆ្លងកាត់តាមប្រព័ន្ធអេឡិចត្រូនិក។ ដើម្បីឱ្យកាន់តែច្បាស់ យើងនឹងលើកយកទម្រង់នៃសកម្មភាព ឬប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីរមកបង្ហាញពីដំណើរការៈ

- **ទំនិញរូបី** ៖ អតិថិជនជ្រើសរើសទំនិញរូបីក្នុងបញ្ជីមុខទំនិញតាមអ៊ិនធឺណិត និងបញ្ជាទិញទំនិញនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ ហើយទំនិញរូបីបានបញ្ជូនទៅអតិថិជនតាមមធ្យោបាយផ្សេងៗ។
- **ការបញ្ជាទិញ និងការទាញយកទំនិញឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក** ៖ អតិថិជនជ្រើសរើសសូហ្វែរក្នុងបញ្ជីមុខទំនិញតាមអ៊ីនធឺណិត ឬផលិតផលឌីជីថលផ្សេងៗទៀត និងបញ្ជាទិញទំនិញទាំងនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ហើយទំនិញឌីជីថលត្រូវបានទាញយកដាក់ក្នុងឧបករណ៍ទិន្នន័យ (Hard Disk) របស់អតិថិជន ឬតាមមធ្យបាយផ្សេងទៀត។

### គ.ស្ថានភាពជាក់ស្តែងនៃដំណើរការពាណិជ្ជកម្មប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

ជាទូទៅប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចាប់ផ្តើមដោយអតិថិជនស្វែងយល់ព័ត៌មានពីទំនិញ ជ្រើសរើសទំនិញ បញ្ជាទិញទំនិញ បន្ទាប់មកមានការទូទាត់ប្រាក់ និងដឹកជញ្ជូនពីអ្នកលក់។ ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនត្រូវបានអនុវត្តទាំងស្រុងដោយផ្អែកលើប្រព័ន្ធអ៊ិនធឺណិតទេ ដោយការដឹកជញ្ជូនទំនិញ មិនរាប់បញ្ចូលប្រភេទឌីជីថលដូចជា សូហ្វវែរ បទភ្លេង វីដេអូជាដើម ធ្វើតាមរយៈសេវាដឹកជញ្ជូន ដោយឡែកការទូទាត់ប្រាក់ពេលខ្លះធ្វើតាមការប្រគល់ប្រាក់ផ្ទាល់មុខ ឬធ្វើតាមរយៈអ្នកដឹកជញ្ជូន។ ជាក់

[7] ប្រការ៣ នៃប្រកាសស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

[8] ប្រការ៥ នៃប្រកាសស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ស្តែង នៅក្នុងសង្គមពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបច្ចុប្បន្នអ្នកប្រើប្រាស់អាចបង់ប្រាក់តាមអ្នកផ្តល់សេវាទូទាត់ប្រាក់ ដែលសហការជាមួយដៃគូ គឺតាមធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ។ សព្វថ្ងៃគ្រឹះស្ថានហិរញ្ញវត្ថុដែលមានផ្តត់ផ្គង់សេវាការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកមានដូចជា អ៊ីម៉ាន់នី (e-money) ស្មាតលុយ (SmartLuy) ផេហ្គូ (PayGo) ផាយផេ (Pi-Pay) ក្រុមហ៊ុនវីង (Wing) ធនាគារអេស៊ីលីដា ធនាគារ ABA ជាដើម។ ធនាគារជាតិនៃកម្ពុជាមានការទទួលខុសត្រូវដែលកំណត់ដោយច្បាប់ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់។ ធនាគារជាតិបានចេញនូវបទបញ្ញាដែលណែនាំអំពីអាជ្ញាបណ្ណនៃអ្នកផ្តល់សេវាទូទាត់ គឺតម្រូវឱ្យមានដើមទុនចុះបញ្ជីអប្បបរមាសម្រាប់ធ្វើប្រតិបត្តិការចំនួន ៨.០០០.០០០.០០០ (ប្រាំបីពាន់លានរៀល) ជាសាច់ប្រាក់។ គួរឱ្យកត់សម្គាល់ផងដែរថា បច្ចុប្បន្ននេះធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលើការអភិវឌ្ឍន៍ប្រព័ន្ធ National Shared Switch ដែលជាប្រព័ន្ធរួមបញ្ចូលគ្នាមួយដើម្បីសម្រួលដល់ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដូចជា ការដកសាច់ប្រាក់តាមរយៈ ម៉ាស៊ីន ATM ការទូទាត់សងប្រាក់ដោយម៉ាស៊ីន POS និងការទូទាត់សងប្រាក់ចល័តនិងតាមរយៈអ៊ិនធឺណិត ក្នុងគោលបំណងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសេវាទូទាត់សងប្រាក់ និងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន។

ចំពោះការដឹកជញ្ជូនវិញ គេឃើញមានការប្រើប្រាស់សេវាដឹកជញ្ជូនរបស់សហគ្រាសឯកជនបរទេសដូចជា DHL FEDEX ហើយក្នុងករណីខ្លះក៏មានការប្រើប្រាស់ម៉ូតូឌុប ម៉ូតូកង់បី ការប្រើប្រាស់សេវារបស់ Grab ជាដើមដែលនេះជាការរៀបចំរបស់អ្នកលក់ក្នុងការដឹកជញ្ជូនទំនិញទៅកាន់អ្នកទិញ។ ចំពោះការដឹកជញ្ជូនទៅតាមបណ្តាខេត្ត-ក្រុងនានាគេឃើញមានប្រើប្រាស់រថយន្តក្រុង រថយន្តតាក់ស៊ីជាដើម ហើយ ការចំណាយទៅលើសេវាដឹកជញ្ជូនជាបន្ទុករបស់អ្នកទិញ។

ដូចនេះតាមលំដាប់លំដោយដែលបានរៀបរាប់ខាងលើ កិច្ចសន្យាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវធ្វើឡើងតាមរយៈការចង្អុលបង្ហាញទៅតាមប្រព័ន្ធកុំព្យូទ័រដែលបានបង្ហាញនៅលើអេក្រង់កុំព្យូទ័រ។ ដោយសារតែមូលហេតុនេះ គេពិបាកក្នុងការកំណត់ពីសមត្ថភាពរបស់ភាគីម្ខាងទៀត (អ្នកទិញ) ណាស់ព្រោះមិនបានជួបគ្នាផ្ទាល់មុខ។ ក្រៅពីនេះក៏មានការលំបាកក្នុងការកំណត់ពីឆន្ទៈពិតប្រាកដរបស់បុគ្គលព្រោះវាមិនត្រូវបានបង្ហាញចេញមកក្រៅ ដោយហេតុថាភាគីម្ខាងទៀតជាប្រព័ន្ធស្វ័យប្រវត្តិ ឬកុំព្យូទ័រ។ ការបង្កើតកិច្ចសន្យាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានពិភាក្សាបន្ថែមដោយស៊ីជម្រៅនៅ ក្នុងចំណុច *២.៣ ការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក*។

### ឃ.អន្តរការីនិងបុគ្គលផ្តល់សេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

តាមលំដាប់លំដោយដែលបានរៀបរាប់នេះគេសង្កេតឃើញថាក្រៅពីអ្នកទិញ និងអ្នកលក់ ក៏មានអន្តរការីនិងក្រុមហ៊ុនដឹកជញ្ជូន និងអ្នកផ្គត់ផ្គង់ទំនិញដែលចូលរួមក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ប្រតិបត្តិការអេឡិចត្រូនិកមួយពិតជាមិនអាចកើតមានឡើងបាននោះទេបើសិនជាគ្មានអន្តរការី។ យោងតាមនិយមន័យក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក *អន្តរការី (Intermediary)* សំដៅដល់បុគ្គលដែលផ្តល់សេវា ផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិកមានដូចជាបុគ្គលដូចខាងក្រោម៖

- បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក
- បុគ្គលផ្តល់សេវាទូរគមនាគមន៍
- បុគ្គលផ្តល់សេវាបណ្តាញនានា
- បុគ្គលផ្តល់អ៊ិនធឺណិត
- បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក
- បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ
- បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ
- បុគ្គលផ្តល់សេវាទីផ្សារអនឡាញ និងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធឺណិត។

បុគ្គលទាំងនេះត្រូវស្នើសុំការអនុញ្ញាត ឬអាជ្ញាបណ្ណពីក្រសួង២ពោលគឺក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណផ្តល់ដោយក្រសួងពាណិជ្ជកម្មរួមមានលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូពិកសម្រាប់រូបវន្តបុគ្គល និងអាជ្ញាបណ្ណឱ្យប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់នីតិបុគ្គល។ ចំណែកឯ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ផ្តល់វិញ្ញាបនបត្រសេវាអនឡាញ។

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏បានចែងពីការទទួលខុសត្រូវរបស់អន្តរការីនិងបុគ្គលផ្តល់សេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក[9]ផងដែរ។ ដូចមានចែងនៅក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃណីយ៍និងទូរគមនាគមន៍។ ក្រមសីលធម៌វិជ្ជាជីវៈគួរតែរួមបញ្ចូលការការពារទិន្នន័យ និងល័ក្ខខ័ណ្ឌស្តីពីកាតព្វកិច្ចសុវត្ថិភាព និងតម្លាភាពរបស់បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើព្រឹត្តិកម្មទិន្នន័យ (Data Controllers and Processors) និងកំណត់មូលដ្ឋានច្បាប់

[9] មាត្រា ២៤ និង មាត្រា ២៥នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩

សម្រាប់ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន និងការផ្ដល់សិទ្ធិជាក់លាក់ដល់ម្ចាស់ទិន្នន័យក្នុងការចូលយកទិន្នន័យ កែទិន្នន័យ និងលុបទិន្នន័យ។ល។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកំពុងតែទទួលការពេញនិយម ព្រោះការប្រៀបធៀបតម្លៃមានភាពងាយស្រួល ដោយអតិថិជន ឬអ្នកប្រើប្រាស់អាចប្រៀបធៀបតម្លៃនៃទំនិញរាប់រយបានដោយគ្រាន់តែចូលទៅកាន់គេហទំព័រទំនិញ ជ្រើសរើសមុខទំនិញណាមួយ ហើយថែមទាំងអាចពិនិត្យមើលការវាយតម្លៃលើទំនិញរបស់អតិថិជនដែលធ្លាប់ទិញទំនិញនោះរួច ដែលទាំងអស់នេះអតិថិជន ឬអ្នកប្រើប្រាស់អាចធ្វើបានដោយមិនចាំបាច់ចេញពីផ្ទះឡើយ។

## ១.៣ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក

ក្រៅពីច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏មានច្បាប់ផ្សេងៗទៀតដូចជា ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងច្បាប់ស្តីពីការប្រកួតប្រជែងដែលមានសារៈសំខាន់ក្នុងការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងចូលរួមបំពេញបន្ថែមទៅលើច្បាប់ទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យកាន់តែមានលក្ខណៈពេញលេញ។

– **ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មាន១២ជំពូក និង៦៧មាត្រា។ គោលបំណងរបស់ច្បាប់នេះមានដូចជា៖

- គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអន្តរជាតិ
- បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងរដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិក
- ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក

គួរកត់សម្គាល់ថាច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹងការបង្កើត ឬការអនុវត្តលិខិតប្រគល់សិទ្ធិ ការបង្កើតឬចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម និងរាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យ ឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះទេ។

ការបង្ហាញយ៉ាងសង្ខេបពីបទប្បញ្ញត្តិនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានដូចខាងក្រោម៖

- ជំពូកទី១ បទប្បញ្ញត្តិទូទៅ មានចំនួន ៤ មាត្រា (មាត្រា ១ ដល់មាត្រា ៤) បញ្ញត្តិអំពី គោលបំណង គោលដៅ វិសាលភាព និងនិយមន័យនៃវាក្យសព្ទសំខាន់ៗដែលមានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ
- ជំពូកទី២ សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក មានចំនួន ១០ មាត្រា (មាត្រា ៥ ដល់មាត្រា ១៤) បញ្ញត្តិអំពីការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងរួមមាន ល័ក្ខខ័ណ្ឌតម្រូវ ការបង្កើតកិច្ចសន្យាអេឡិចត្រូនិក និងអានុភាពរវាងគូភាគីនៃទំនាក់ទំនងអេឡិចត្រូនិក
- ជំពូកទី៣ ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក មានចំនួន ៤ មាត្រា (មាត្រា ១៥ ដល់មាត្រា ១៨) បញ្ញត្តិលម្អិតអំពីដំណើរប្រព្រឹត្តទៅនៃទំនាក់ទំនងអេឡិចត្រូនិក ដោយរួមបញ្ចូលទាំងពេលវេលា ទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មាន ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ និងកំហុសឆ្គងនៃការបញ្ចូលព័ត៌មាន
- ជំពូកទី៤ កំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព មានចំនួន ៥ មាត្រា (មាត្រា ១៩ ដល់ មាត្រា ២៣) បញ្ញត្តិអំពីលក្ខណ្ឌដែលធ្វើឱ្យកំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិកមានសុវត្ថិភាព និងស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងនីតិវិធីសុវត្ថិភាព
- ជំពូកទី៥ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានចំនួន ៥ មាត្រា (មាត្រា ២៤ ដល់មាត្រា ២៨) បញ្ញត្តិអំពី ការទទួលខុសត្រូវ ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ក្រមសីលធម៌អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កាតព្វកិច្ច ការលើកទឹកចិត្ត និងការអនុគ្រោះដែលអាចទទួលបាន
- ជំពូកទី៦ កិច្ចការពារអ្នកប្រើប្រាស់ មានចំនួន ៥ មាត្រា (ពីមាត្រា ២៩ ដល់មាត្រា ៣៣) បញ្ញត្តិអំពីការការពារមួយចំនួនចំពោះអ្នកប្រើប្រាស់ ដូចជាការផ្តល់ព័ត៌មានអប្បបរមា ទំនាក់ទំនងដែលមិនបានស្នើសុំ ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំនិងកូដព្យាបាទ និងការការពារទិន្នន័យ។ ប៉ុន្តែប្បញ្ញត្តិនៅក្នុងជំពូកនេះ មិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ការពារអ្នកប្រើប្រាស់នោះទេ ពោលគឺត្រូវយោងទៅលើប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់បន្ថែមទៀត
- ជំពូកទី៧ សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក មានចំនួន ១ មាត្រា បញ្ញត្តិអំពីការទទួលយកការទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិកដោយក្រសួង និងស្ថាប័នរដ្ឋាភិបាលនានា
- ជំពូកទី៨ ភស្តុតាងអេឡិចត្រូនិក មាន ១១ មាត្រា (ពីមាត្រា ៣៥ ដល់មាត្រា ៤៥) បញ្ញត្តិបន្ថែមលើជំពូក២ អំពីភាពអាចទទួលយកបាននៃភស្តុតាងអេឡិចត្រូនិក និងសុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក

ព័ត៌មាន នីតិវិធីក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក និងការទទួលស្គាល់ព័ត៌មានអេឡិចត្រូនិកមកពីបរទេស

- ជំពូកទី៩ ការទូទាត់និង-ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក មាន ៣ មាត្រា (មាត្រា ៤៦ ដល់មាត្រា ៤៨) បញ្ញត្តិអំពីប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់ និងអតិថិជន
- ជំពូកទី១០ សមត្ថកិច្ច ការប្តឹងតវ៉ា និងនីតិវិធីនៃការដាក់ពិន័យ មាន ៣ មាត្រា (មាត្រា ៤៩ ដល់មាត្រា ៥១) ដែលបញ្ញត្តិអំពីសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ នីតិវិធីរដ្ឋបាល និងពិន័យ
- ជំពូកទី១១ ទោសប្បញ្ញត្តិ មាន ១៤ មាត្រា (មាត្រា ៥២ ដល់មាត្រា ៦៥) បញ្ញត្តិអំពីអំពើល្មើសនានាបទល្មើសប្រឆាំងនឹងប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ កំណត់និយន័យ ព្រមទាំងទោសទណ្ឌនៃបទល្មើសទាំងនោះ
- ជំពូកទី១២ អវសានប្បញ្ញត្តិ មាន ២ មាត្រា (មាត្រា ៦៦ ដល់មាត្រា ៦៧) បញ្ញត្តិអំពី ការនិរាករណ៍នៃបទប្បញ្ញត្តិដែលផ្ទុយនឹងច្បាប់នេះ និងបញ្ញត្តិពីការដាក់ឱ្យអនុវត្តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ការអនុវត្តច្បាប់នេះត្រូវបានរំពឹងថានឹងជំរុញឱ្យមានការបង្កើនការវិនិយោគ និងសកម្មភាពក្នុងវិស័យឯកជន ព្រមទាំងមានការនាំមកនូវនវានុវត្តន៍ដូចជា ប្រព័ន្ធទូទាត់ ប្រព័ន្ធថ្នាលបច្ចេកវិទ្យាដែលមានភាពទំនើប ក៏ដូចជាការលូតលាស់នៃការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនផងដែរ។ មិនតែប៉ុណ្ណោះ វត្តមាននៃជំងឺកូវីដ-១៩បានធ្វើឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកាន់តែមានប្រជាប្រិយភាព។ សក្តានុពលនៃការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសារៈសំខាន់ណាស់ក្នុងការធានាពិពិធកម្មសេដ្ឋកិច្ច ការបង្កើតការងារថ្មី ការបង្កើតចំណូលបន្ថែម ក៏ដូចជាការរួមចំណែកក្នុងការធ្វើឱ្យជីវភាពរបស់ប្រជាជនកម្ពុជាមានភាពប្រសើរឡើង។ ជាងនេះទៅទៀត ច្បាប់នេះផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូចនិងមធ្យម (SMEs) នៅកម្ពុជាអាចភ្ជាប់ខ្លួននៅនឹងខ្សែសង្វាក់ផលិតកម្មទីផ្សារក្នុងស្រុក និងអន្តរជាតិ ក៏ដូចជាជំរុញឱ្យមានការច្នៃប្រឌិត និងការបង្កើតទំនិញ និងសេវាថ្មីៗបន្ថែមទៀត។ សេចក្តីព្រាងច្បាប់នេះ រួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចឌីជីថលនៅកម្ពុជា ដោយហេតុថាក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលគាំទ្រដល់សកម្មភាព និងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក និងឌីជីថលចាំបាច់ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពដើម្បីអាចបង្កើតសេដ្ឋកិច្ចឌីជីថលរឹងមាំមួយព្រមទាំងត្រៀមទទួលយកការឈានមកដល់នៃបដិវត្តន៍ឧស្សាហកម្ម៤.០។

- **ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់**

ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ បានផ្តល់នូវបញ្ញត្តិមួយនៅក្នុងមាត្រា ២៧ ដែលកំណត់ដោយផ្ទាល់នូវបទដ្ឋាននិយ័តកម្មកិច្ចការពារអ្នកប្រើប្រាស់ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ច្បាប់នេះបានតម្រូវឱ្យបុគ្គលទាំងអស់ដែលធ្វើអាជីវកម្មនៅកម្ពុជា ត្រូវបង្ហាញព័ត៌មានអប្បបរមាដល់អ្នកប្រើប្រាស់។ នៅក្នុងមាត្រា ៣៣ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តម្រូវឱ្យបុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ ចាំបាច់អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់។

- **សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន**

បើទោះបីជាច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានចែងពីទោសប្បញ្ញត្តិ និងការផ្តន្ទាទោសចំពោះបទល្មើសមួយចំនួនដែលពាក់ព័ន្ធនិងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់សម្រាប់ទប់ស្កាត់រាល់បទល្មើសដែលនឹងកើតមានឡើងបានឡើយ ដូចនេះត្រូវការច្បាប់ផ្សេងៗទៀតសម្រាប់ជួយបំពេញបន្ថែម ហេតុនេះទើបគេបង្កើតសេចក្តីព្រៀងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ សេចក្តីព្រាងច្បាប់នេះស្នើឱ្យបង្កើតគណៈកម្មាធិការថ្នាក់ជាតិប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលមានតួនាទីទទួលខុសត្រូវតាមដាន និងអនុវត្តច្បាប់។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានចែងពីបទល្មើសនានាដូចជាការចូលយកដោយពុំស្របច្បាប់ ចោរកម្មទិន្នន័យ ការស្ទាក់យកពុំស្របច្បាប់នៃការបញ្ជូនទិន្នន័យឯកជន ការជ្រៀតជ្រែកទិន្នន័យ ការផ្ទេរទិន្នន័យដោយពុំមានការអនុញ្ញាត ការជ្រៀតជ្រែកប្រព័ន្ធ (ដូចជាការបញ្ចូលបញ្ជូន ការកែប្រែ ការលុបចោល ឬការធ្វើឱ្យខូចខាតទិន្នន័យកុំព្យូទ័រ ឬការរិតត្បិតនូវការយកទិន្នន័យ) ការឆបោកនិងក្លែងបន្លំទាក់ទងនឹងកុំព្យូទ័រ និងការប្រើប្រាស់ពុំត្រឹមត្រូវនូវឧបករណ៍ និងឧបសាធនសម្រាប់បទល្មើសបច្ចេកវិទ្យានានា ហើយក៏បានយោងទៅក្រមព្រហ្មទណ្ឌសម្រាប់បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាដូចមានចែងក្នុងមាត្រា ៤២៧ ៤២៨ ៤២៩ និង មាត្រា ៤៣០ ផងដែរ។

- **អនុក្រឹត្យលេខ ២៤៦ ស្តីពីហត្ថលេខាឌីជីថល**

អនុក្រឹត្យលេខ ២៤៦ ស្តីពីហត្ថលេខាឌីជីថល មានចែងក្នុងមាត្រា៤ បានកំណត់ថា ហត្ថលេខាឌីជីថលជាទិន្នន័យដែលភ្ជាប់ទៅនឹងសារអេឡិចត្រូនិកសម្រាប់កំណត់អត្តសញ្ញាណរបស់ហត្ថលេខី និងពិនិត្យផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិចត្រូនិក។ មាត្រា៩ កំណត់ល័ក្ខខ័ណ្ឌដែលហត្ថលេខាឌីជីថល អាចកំណត់អត្តសញ្ញាណរបស់ហត្ថលេខី ដោយពិនិត្យផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិចត្រូនិក ពិនិត្យផ្ទៀងផ្ទាត់កាលបរិច្ឆេទ និងពេលវេលានៃហត្ថលេខាឌីជីថលនោះ។ មាត្រានេះក៏ចែងដែរថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អាចកំណត់ល័ក្ខខ័ណ្ឌផ្សេងទៀតតាមករណីចាំបាច់។ អនុក្រឹត្យលេខ ២៤៦ ក៏ទទួលស្គាល់នូវ

សុពលភាពនៃសារអេឡិចត្រូនិកដែលភ្ជាប់ដោយហត្ថលេខាឌីជីថលដែលត្រូវបានពិនិត្យ និងផ្ទៀងផ្ទាត់ដោយអាជ្ញាធរមានការបញ្ជាក់ដែលទទួលស្គាល់ដោយក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍។ គួរកត់សម្គាល់ថា បុគ្គលទាំងអស់អាចស្នើសុំអាជ្ញាប័ណ្ណអាជ្ញាធរមានការបញ្ជាក់ទៅកាន់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសុពលភាពអាចបន្តរយៈពេល១០ឆ្នាំ។ វិញ្ញាបនបត្រហត្ថលេខាឌីជីថល មានសក្តានុពលក្នុងការយកទៅប្រើប្រាស់សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មក្នុងដំណើរការប្រព័ន្ធបញ្ជរតែមួយជាតិ ការបង់ពន្ធ និងក្នុងប្រតិបត្តិការពាណិជ្ជកម្មអេឡិចត្រូនិក។ មាត្រា ១១ នៃអនុក្រឹត្យលេខ ២៤៦ ក៏បានចែងផងដែរថា ប្រតិបត្តិការហិរញ្ញវត្ថុអនឡាញទាំងអស់ត្រូវប្រើប្រាស់ហត្ថលេខាឌីជីថលស្របទៅតាមអនុក្រឹត្យនេះ លើកលែងតែមានការអនុម័តផ្សេងទៀតដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា។

- **អនុក្រឹត្យ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ អគ្គនាយកដ្ឋានពន្ធដារ ចេញសេចក្តីប្រកាសព័ត៌មាន ដោយបញ្ជាក់ថា រាជរដ្ឋាភិបាលបានសម្រេចដាក់ ឱ្យអនុវត្តអាករលើតម្លៃបន្ថែម ចំពោះទំនិញឌីជីថល និងសេវាឌីជីថល ដែលត្រូវបានផ្គត់ផ្គង់ និងប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក ដោយអ្នកផ្គត់ផ្គង់អនិវាសនជន ដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅកម្ពុជា។ អនុក្រឹត្យ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានវិសាលភាពគ្របដណ្តប់ក្រុមហ៊ុនបរទេស ដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍ (ទីតាំងស្នាក់ការ) នៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ដូចជាក្រុមហ៊ុនណាមួយ ដែលមិនមានទីតាំងក្រុមហ៊ុនរបស់ខ្លួននៅកម្ពុជា ប៉ុន្តែក្រុមហ៊ុននោះ មានអតិថិជនរបស់ខ្លួននៅកម្ពុជា ដូច្នេះអនុក្រឹត្យថ្មីនេះ មានវិសាលភាពគ្របដណ្តប់ទៅលើក្រុមហ៊ុនប្រភេទនេះ។ នៅពេលអតិថិជនក្នុងស្រុក ទិញសេវា ឬផលិតឌីជីថល ពីក្រុមហ៊ុនដែលមិនមានទីតាំងក្នុងស្រុកខ្មែរ ក្រុមហ៊ុននោះត្រូវកាត់ទុក VAT ចំនួន១០% ហើយពន្ធ VAT នេះជាពន្ធដែលយើងមានស្រាប់ តែយើងទើបអាចអនុវត្តបានតាមរយៈច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ ការដាក់ឱ្យអនុវត្តអាករលើតម្លៃបន្ថែម ចំពោះទំនិញឌីជីថល និងសេវាឌីជីថល ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់ស្តីពីសារពើពន្ធប៉ុណ្ណោះ ហើយក៏ស្របតាមនិយាមអន្តរជាតិផងដែរ។[10]

[10] សារព័ត៌មាន Fresh News ក្រសួងសេដ្ឋកិច្ច៖ អនុក្រឹត្យ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនជាការបង្កើតពន្ធថ្មីនោះទេ http://m.freshnewsasia.com/index.php/en/localnews/193880-2021-04-14-05-02-17.html

# ជំពូកទី២
# របបគតិយុត្តទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចាំបាច់តម្រូវឱ្យមានច្បាប់សម្រាប់គ្រប់គ្រងរាល់ប្រតិបត្តិការជួញដូរ ដើម្បីធានាបាននូវសុក្រឹតភាព និងសុវត្ថិភាពដល់គ្រប់ភាគីពាក់ព័ន្ធ។ ជំពូកនេះ សិក្សាលម្អិតអំពីសុពលភាពទំនាក់ទំនងអេឡិចត្រូនិក (២.១) ទំនាក់ទំនងព័ត៌មានក្នុងពាណិជ្ជកម្មអេឡិចត្រូនិក (២.២) ដោយផ្តោតសំខាន់លើការបញ្ជូនចេញនៃព័ត៌មាន និងការទទួលព័ត៌មាន និងការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក (២.៣) ដោយផ្អែកលើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងគោលការណ៍ដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

## ២.១ សុពលភាពទំនាក់ទំនងពាណិជ្ជកម្មអេឡិចត្រូនិក

គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត ភាពអាចទទួលយកបាន ឬភាពដែលអាចយកអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។[11] ដូចនេះ លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិកត្រូវបានគេទទួលស្គាល់ ដូចជា នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរត្រូវចាត់ទុកថាល័ក្ខខ័ណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់និងទាញយកនៅពេលក្រោយបាន។ នៅពេលដែលល័ក្ខខ័ណ្ឌក្នុងប្បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តល័ក្ខខ័ណ្ឌតម្រូវតាមច្បាប់ដែលទាមទារឱ្យបុគ្គលណាមួយ ផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីពីព័ត៌មានណាមួយទៅឱ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញល័ក្ខខ័ណ្ឌនេះដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់បាន។

ដូចគ្នាដែរ នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យបុគ្គលមានចុះហត្ថលេខា ល័ក្ខខ័ណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះ ត្រូវបានបង្កើតឡើងតាមរយៈមធ្យោបាយដែល អាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញការឯកភាពរបស់បុគ្គលនោះលើព័ត៌មាន ឬកំណត់ត្រាដែលមានក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ ហើយអាចជឿជាក់បានស្របទៅតាមចរិកលក្ខណៈ គោលបំណង និងកាលៈទេសៈ ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើត

[11] មាត្រា ៥ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩

ឡើង ឬប្រាស្រ័យទាក់ទង។ ទោះបីជាប្បញ្ញត្តិណាមួយកំណត់អំពីល័ក្ខខ័ណ្ឌតម្រូវឱ្យមានចុះហត្ថលេខា ឬគ្រាន់តែកំណត់អំពីផលវិបាកនៃការមិនចុះហត្ថលេខាក៏ដោយ ក៏ប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើយកមកអនុវត្តដែរ។

ល័ក្ខខ័ណ្ឌគតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើក្នុងទម្រង់អេឡិចត្រូនិក អាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ ហើយព័ត៌មាននោះអាចទទួលយកបានយ៉ាងងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

ក្រៅពីនេះ ច្បាប់ស្តីពីពាណិជ្ជកម្មស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏អនុញ្ញាតឱ្យជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន នៅពេលដែលប្បញ្ញត្តិណាមួយតម្រូវឱ្យព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយដែលល័ក្ខខ័ណ្ឌតម្រូវ នៅពេលដែលទម្រង់អេឡិចត្រូនិកនោះ មានព័ត៌មានដូចគ្នា ឬដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់ អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ ហើយអាចឱ្យបុគ្គលដែលទទួលព័ត៌មាននោះទាញយកមករក្សាទុកបាន។ ជាងនេះផងដែរ នៅពេលដែលប្បញ្ញត្តិណាមួយតម្រូវឱ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ ល័ក្ខខ័ណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញប្រសិនបើ ការរក្សាទុកនោះបំពេញល័ក្ខខ័ណ្ឌទាំងអស់ដូចខាងក្រោម៖

- ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកប្រើប្រាស់នាពេលអនាគត
- ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រឹតភាពនៃព័ត៌មាននោះ
- ព័ត៌មានទាំងនោះត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិចនោះបានផ្ញើ ឬបានទទួល។

## ២.២ ទំនាក់ទំនងព័ត៌មានក្នុងពាណិជ្ជកម្មអេឡិចត្រូនិក

### ២.២.១ ការបញ្ជូនចេញនៃព័ត៌មាន

ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានចាត់ទុកថាបានបញ្ជូនចេញនៅពេលដែល ព័ត៌មាននោះបានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ ឬភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ។ ក្នុងករណីដែលព័ត៌មាននោះត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ ឬភាគីដែលផ្ញើព័ត៌មានជំនួសត្រូវចាត់ទុកថាបានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះ

ត្រូវបានទទួលក្នុងពេលណាមួយ។ ត្រូវកត់សម្គាល់ថា ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។ ឧទាហរណ៍ថាអ្នកផ្ញើបញ្ជូនព័ត៌មានពីផ្ទះម្តាយរបស់ខ្លួននៅខេត្តតាកែវ ប៉ុន្តែទីតាំងអាជីវកម្មរបស់គាត់ស្ថិតនៅភ្នំពេញ ដូចនេះព័ត៌មាននោះត្រូវសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់ខ្លួននៅភ្នំពេញ។

### ២.២.២ ការទទួលព័ត៌មាន

ពេលវេលានៃការទទួលព័ត៌មាន គឺពេលដែលព័ត៌មាននោះអាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។ ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ដោយអ្នកទទួលនោះពេលពេលវេលាទទួលព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញនិងអាចទាញយកព័ត៌មាននោះ តាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។ ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក ត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិកអ្នកទទួលហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងអាជីវកម្មរបស់អ្នកទទួល។

## ២.៣ ការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏មិនខុសគ្នានឹងពាណិជ្ជកម្មទូទៅដែរ គឺត្រូវតែមានកិច្ចសន្យាជាសំអាងដើម្បីនៅពេលមានអ្វីមួយកើតឡើងគេអាចមានភស្តុតាងដើម្បីអះអាងតាមផ្លូវច្បាប់បាន។ កិច្ចសន្យាមួយកើតមានឡើងនៅពេលដែលសំណើ និងស្វីការត្រូវគ្នា។ មានន័យថានៅពេលដែលសំណើ និងស្វីការត្រូវគ្នានោះកិច្ចសន្យានឹងមានអានុភាព[12]ដែលបង្កើតឱ្យមានសិទ្ធិ និងកាតព្វកិច្ចរវាងគូភាគី។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានចែងថា សំណើ ស្វីការ និងកិច្ចសន្យាអាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិក។ កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកមានសុពលភាព អានុភាពគតិយុត្ត និងភាពអាចនៅពេលដែលសំណើនិងស្វីការត្រូវគ្នា។[13] អ្នកផ្ញើ និងអ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិក មិនត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬសេចក្តីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។[14] យ៉ាងណាក្តី ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអនុញ្ញាតឱ្យគូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយអនុវត្តមិនប្រើប្រាស់កំណត់

[12] មាត្រា៣៣៦ កថាខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[13] មាត្រា ១២ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩
[14] មាត្រា ១៣ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩

ត្រាអេឡិចត្រូនិក ទំនាក់ទំនងអេឡិចត្រូនិក ហត្ថលេខាអេឡិចត្រូនិកក្នុងកិច្ចសន្យា ឬដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗបានតាមការព្រមព្រៀងរវាងគូភាគី។[15]

### ២.៣.១ សញ្ញាណទូទៅនៃការបង្កើតកិច្ចសន្យា

#### ក. សំណើ

សំណើ គឺជាការស៊ុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត (ចំណងច្បាប់) ក្នុងករណីដែលមានស្វីការ (ការទទួលយកសំណើ) របស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[16] ហើយសំណើត្រូវមានអានុភាព នៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត ពោលបើសំណើនោះទៅដល់ភាគីណាម្នាក់ហើយទើបច្បាប់ចាត់ទុកថាពិតជាមានសំណើពិតប្រាកដមែន។ ប៉ុន្តែប្រសិនបើមានការដកសំណើវិញនោះហើយដំណឹងនោះបានមកដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នានឹងពេលសំណើដល់ ឬមុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតមានឡើយ។

ឧទាហរណ៍ លោក ក មានបំណងចង់លក់ឡានក្នុងតម្លៃ ៣០០០០ ដុល្លារ ទៅឱ្យលោក ខ។ ប៉ុន្តែក្រោយមកក៏ជូនដំណឹងថានឹងមិនលក់ឡានវិញ ហើយដំណឹងទាំងពីរនេះបានមកដល់លោក ខ ស្របពេលគ្នា។ លោក ក លក់ឡានក្នុងតម្លៃ ៣០០០០ ដុល្លារ គឺជាសំណើ ប៉ុន្តែក្រោយមកក៏ជូនដំណឹងថានឹងមិនលក់ឡានវិញ ដោយដំណឹងទាំងពីរនេះបានមកដល់ពេលស្របគ្នា ដូចនេះគេមិនចាត់ទុកថាសំណើបានកើតឡើងនោះទេ ប៉ុន្តែផ្ទុយទៅវិញបើការដកសំណើររបស់គាត់បានមកដល់ក្រោយនោះគេចាត់ទុកថាសំណើរនោះបានកើតឡើង។

សំណើអាចធ្វើឡើងដោយកំណត់រយៈពេលសម្រាប់ស្វីការក៏បាន ហើយដោយមិនមានកំណត់រយៈពេលក៏បាន។ ក្នុងករណីដែលសំណើមានកំណត់រយៈពេល ហើយរយៈពេលនៃការធ្វើសំណើគឺចាប់គិតពីថ្ងៃជូនដំណឹងអំពីសំណើ។ លើសពីនេះ កំឡុងពេលនៃការធ្វើសំណើដែលមានកំណត់ពេលគឺអ្នកស្នើមិនអាចដកសំណើនោះមកវិញបានទេ។ ប៉ុន្តែសំណើនោះនឹងផុតរលត់ដោយស្វ័យប្រវត្តិប្រសិន បើផុតកំណត់យៈពេលដែលបានកំណត់សម្រាប់ស្វីការដោយឡែកក្នុងករណីដែលសំណើមិនមានរយៈពេលវិញ គូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាព ដែលអាចឆ្លើយភ្លាមៗបាន សំណើនោះនឹងបាត់បង់អានុភាព ប្រសិនបើអ្នកធ្វើស្វីការមិនបានឆ្លើយភ្លាមៗទេនោះ។ ប៉ុន្តែប្រសិនបើសំណើនោះ មិនមែនធ្វើឡើងក្នុងស្ថានភាពដែលភាគីមិនអាចឆ្លើយតបបានភ្លាមៗទេ គឺអ្នកស្នើមិនអាចដកសំណើនោះដោយមិនទុកពេលវេលាសមរម្យបានទេ ហើយប្រសិនបើចង់ដកសំណើវិញ លុះត្រាតែភាគីម្ខាងទៀតមិនទាន់បានជូនដំណឹងអំពីស្វីការ។

[15] មាត្រា ១៤ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩

[16] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ខ. ស្ទីការ**

ស្ទីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ ស្ទីការត្រូវបានចាត់ទុកថាមានពិតប្រាកដមែន (ពិតជាបានយល់ព្រម) នៅពេលដែលស្ទីការនោះបានដល់ដៃអ្នកស្នើវិញទើបបានស្ទីការនោះមានអានុភាព ។ ដូចគ្នាទៅនឹងសំណើដែរ មិនអាចចាត់ទុកថា មានស្ទីការទេប្រសិនបើដំណឹងដកស្ទីការវិញទៅដល់អ្នកស្នើនៅពេលព្រមគ្នានឹងពេលស្ទីការទៅដល់ ឬមុនពេលស្ទីការដល់អ្នកស្នើ (មាត្រា៣៣៧ នៃក្រមរដ្ឋប្បវេណី)។ ចាត់ទុកថាបានធ្វើស្ទីការដែរប្រសិនបើស្ទីការនោះធ្វើចំពោះសំណើដែលមានរយៈពេលដោយគ្រាន់តែមានការយឺតយ៉ាវក្នុងការធ្វើស្ទីការ ក្រោយពេលដែលរយៈពេលនៃសំណើនោះបានផុតរលត់ទៅហើយអ្នកស្នើមានការធ្វេសប្រហែសដោយមិនបានកំណត់ជូនដំណឹងភាពយឺតយ៉ាវនោះ ហើយប្រសិនបើអ្នកស្នើបានដឹងអំពីស្ថានភាពថាភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះ នោះស្ទីការដែលមកដល់មានភាពយឺតយ៉ាវនោះមានសុពលភាព។ ហើយអ្នកស្នើអាចចាត់ទុកថាស្ទីការដែលមកដល់ក្រោយពេលផុតរយៈពេល សម្រាប់ធ្វើស្ទីការជាសំណើថ្មី (មាត្រា ៣៤១ នៃក្រមរដ្ឋប្បវេណី)។ ស្ទីការ ក៏អាចមានបន្ថែមការកែប្រែបានដែរទៅលើល័ក្ខខ័ណ្ឌសំណើ ឬកែប្រែសារធាតុផ្សេងៗនៃសំណើ តែស្ទីការ នោះមិនអាចយកជាការបានទេប្រសិនបើអ្នកធ្វើសំណើមិនយល់ព្រម ហើយចាត់ទុកអ្នកធ្វើស្ទីការដែលកែប្រែនោះថាជាអ្នកធ្វើសំណើជាថ្មីទៀតផង។ កិច្ចសន្យាកើតមាននៅពេលដែលអ្នកធ្វើសំណើដើម្បីធ្វើស្ទីការទៅអ្នកធ្វើសំណើដែលកែប្រែនេះវិញ។ ប្រសិនបើមិនមានការតវ៉ាភ្លាមៗទេ ស្ទីការដែល មានការកែប្រែល័ក្ខខ័ណ្ឌ ឬការកែប្រែនោះនឹងមានសុពលភាព (មាត្រា ៣៤២ នៃក្រមរដ្ឋប្បវេណី)។ សកម្មភាពមួយចំនួនក៏ត្រូវបានចាត់ទុកជាស្ទីការដែរ ក្នុងករណីមិនចាំបាច់ឱ្យមានដំណឹងអំពីស្ទីការដោយសារឆន្ទៈរបស់អ្នកស្នើ ឬដោយសារទំនៀមទំលាប់នៃកិច្ចការជំនួញ (មាត្រា ៣៤៣ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើសំណើនោះធ្វើឡើងជាសាធារណៈដោយមិនបានកំណត់ទៅលើបុគ្គលណាមួយទេ ការដកសំណើនោះក៏ធ្វើឡើងជាសាធារណៈដូចគ្នាដែរ (មាត្រា ៣៤៤ នៃក្រមរដ្ឋប្បវេណី)។

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នកទិញមានករណីកិច្ចចេញថ្លៃជាប្រាក់ឲ្យអ្នកលក់ (នៅក្នុងករណីដែលតម្លៃថ្នូរមិនមែនជាប្រាក់ទេគេហៅថាការដូរ) ។ អ្នកលក់ និងអ្នកទិញមានករណីយកិច្ចចំពោះគ្នាទៅវិញទៅមក។ កិច្ចសន្យាទិញលក់ គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ និងជាកិច្ចសន្យាទ្វេភាគី។ កិច្ចសន្យាទិញលក់អាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ ហើយគូភាគីអាចកំណត់ធ្វើលិខិតយថាភូត ឬលិខិតឯកជនជាល័ក្ខខ័ណ្ឌសម្រាប់បង្កើតកិច្ចសន្យាតាមការជ្រើសរើសរបស់ខ្លួន ប៉ុន្តែមានករណីលើកលែងដែលមានបញ្ញត្តិក្នុងច្បាប់។ ចំណុចសំខាន់ដែលត្រូវតែកត់សម្គាល់នោះគឺ ការចុចមើលរាល់ទំនិញដែលបានដាក់លើប្រព័ន្ធអ៊ិនធឺណិតដែលមិនសំដៅដល់បុគ្គលជាក់លាក់

ត្រូវចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យា ពោលគឺទោះបីជាអ្នកប្រើប្រាស់បានបង្ហាញឆន្ទៈថាចង់ទិញទំនិញមួយក៏ដោយក៏មិនមែនជាស្ទីការដែរ។

### ២.៣.២ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិសម្រាប់បង្កើតកិច្ចសន្យា

មាត្រា ១៧ នៃច្បាប់ស្តីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានចែងថា៖ "កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តិរបស់បុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាប្រព័ន្ធស្វ័យប្រវត្តិនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពី សុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យ ឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តិ ឬក្នុងការបង្កើតកិច្ចសន្យា"។ ប្រព័ន្ធស្វ័យប្រវត្តិ សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិក ផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹង ឬឆ្លើយតបដោយស្វ័យប្រវត្តិដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

ក្នុងករណីដែលមានកំហុសឆ្គង នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស បុគ្គល ឬភាគីដែលជំនួសមុខឱ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះមានសិទ្ធិកែតម្រូវ ឬដកចេញព័ត៌មានដែលខុសនោះក្នុងករណី៖

- បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានឆាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ និង
- បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀតហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ឬតតិយជនណាមួយ។

គួរកត់សម្គាល់ថាប្បញ្ញត្តិដែលមានចែងក្នុងមាត្រានេះមិនអនុវត្តចំពោះវិស័យមូលបត្រឡើយ។

# ជំពូកទី៣
# អត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

គេសង្កេតឃើញថា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អ្នកប្រើប្រាស់ ពោលគឺទាំងអតិថិជន និងពាណិជ្ជករ ហើយថែមទាំងជាវិស័យមួយដែលមានសក្តានុពលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទៀតផង។ ទៅថ្ងៃមុខពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនឹងរីកដុះដាលបន្ថែមទៀត ហើយបញ្ហាដែលប្រឈមក៏មិនអាចជៀសផុតដែរ។ នៅក្នុងជំពូកនេះ យើងនឹងសិក្សាអំពីអត្ថប្រយោជន៍ (៣.១) បញ្ហាប្រឈមទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (៣.២) និងលទ្ធផលសម្រេចបានឆ្នាំ២០២០ និងគោលដៅយុទ្ធសាស្ត្រឆ្នាំ២០២១ របស់ក្រសួងពាណិជ្ជកម្ម។

## ៣.១ អត្ថប្រយោជន៍

ត្រឹមខែមករា ឆ្នាំ២០២១ ប្រជាជនសរុបចំនួន ៤.៦៦ ពាន់លាននាក់ស្មើនឹង ៥៩.៥% នៃចំនួនប្រជាជនសរុបជាអ្នកប្រើប្រាស់សេវាអ៊ិនធឺណិតសកម្ម។ ក្នុងចំណោមចំនួននេះ ៩២.៦% ចូលប្រើអ៊ិនធឺណិតតាមរយៈឧបករណ៍ចល័ត។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ដោយសារតែការប្រើប្រាស់សេវាអ៊ិនធឺណិតកាន់តែមានភាពងាយស្រួល តម្លៃសមរម្យ ចំនួនប្រជាជនដែលប្រើប្រាស់អ៊ិនធឺណិតមានដល់ ៨.៨៦ លាននាក់ក្នុងខែមករា ឆ្នាំ២០២១ កើនឡើងចំនួន ១.១ លាននាក់ (+១៤%) នៅចន្លោះឆ្នាំ២០២០ ដល់ឆ្នាំ២០២១[17]។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទូទាំងពិភពលោកមានការកើនឡើង ១៤០% ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ដែលមានចិនដីគោក និងសហរដ្ឋអាមេរិកគឺជាទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកធំបំផុតដែលស្មើនឹង ៥៧% នៃការលក់អនឡាញទូទាំងពិភពលោក។

ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះផ្តល់សារៈប្រយោជន៍ដូចជា៖

- សម្រួល និងជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាំងក្នុងប្រទេស និងអន្តរជាតិដើម្បីធានាទាំងផ្នែកច្បាប់ សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក និងទំនាក់ទំនងអេឡិចត្រូនិកសម្រាប់ការធ្វើពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា និងជាមួយអន្តរជាតិ
- បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ពីសំណាក់ក្រសួងស្ថាប័នរដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក និងសម្រួលដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជី ការបង្កើត ឬការរក្សាទុកក្នុង

[17] គេហទំព័រDATAREPORTAL ឌីជីថល ២០២១៖ កម្ពុជា (ចូលទស្សនាចុងក្រោយថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០២១) https://datareportal.com/reports/digital--2021cambodia

ទម្រង់អេឡិចត្រូនិកជាមួយក្រសួងស្ថាប័នរដ្ឋតាមរយៈការទទួលស្គាល់សកម្មភាព និងប្រព័ន្ធអេឡិចត្រូនិក

- លើកកំពស់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាព និងប្រតិបត្តិការនានា តាមរយៈការទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាននៃទម្រង់អេឡិចត្រូនិក កំណត់ត្រាអេឡិចត្រូនិក ភស្តុតាងអេឡិចត្រូនិក ហត្ថលេខាអេឡិចត្រូនិក និងធានាដល់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកបានឆាប់រហ័ស និងមានសុវត្ថិភាព
- លើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការការពារព័ត៌មានឯកជនដល់អ្នកប្រើប្រាស់ និងការទទួលបានព័ត៌មានច្បាស់លាស់ និងគ្រប់គ្រាន់អំពីទំនិញ ឬសេវាដាក់លក់តាមប្រព័ន្ធអេឡិចត្រូនិក
- ទប់ស្កាត់រាល់សកម្មភាពដែលបង្កឱ្យមានការប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព និងទំនុកចិត្ត។

### ៣.១.១ ចំពោះអតិថិជន

ជាការពិតណាស់ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានអត្ថប្រយោជន៍ដល់អតិថិជនដូចជា៖

- ទីផ្សារទូលំទូលាយ៖ អតិថិជនមានភាពងាយស្រួលក្នុងការស្វែងរកទំនិញ នឹងអាចប្រៀបធៀបពីតម្លៃ និងគុណភាពនៃទំនិញបានច្រើនប្រភេទ។ ហាងជាច្រើនផ្តល់ជូននូវផលិតផលផ្តាច់មុខដែលមិនអាចរកបាននៅកន្លែងផ្សេងទៀត។
- ចំណេញពេលវេលា៖ ជាទូទៅបើយើងចំណាយពេលដើរទិញផ្ទាល់វាត្រូវប្រើពេលវេលាច្រើន។ ពាណិជ្ជកម្មអេឡិចត្រូនិចអាចកើតឡើង ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តាហ៍ ហើយអតិថិជនអាចធ្វើប្រតិបត្តិការដើម្បីទទួលបានផលិតផល ឬការឆ្លើយតបចំពោះសំណួរអ្វីមួយពាក់ព័ន្ធនឹងផលិតផល ឬសេវាដែលផ្គត់ផ្គង់ដោយក្រុមហ៊ុន ឬសហគ្រាសណាមួយនៅគ្រប់ពេលវេលាទោះបីជាអតិថិជននោះមានទីតាំងនៅទីណាក៏ដោយ។

### ៣.១.២ ចំពោះពាណិជ្ជករ

ពាណិជ្ជករអាចទាក់ទាញអតិថិជនបានច្រើនជាងមុន ហើយអស់ដើមទុនតិច ដោយមិនចាំបាច់ចំណាយថ្លៃទិញតូប ឬជួលតូប ធ្វើឱ្យដំនួញដំណើរការទៅដោយមានភាពរហ័ស ព្រមទាំងបង្កើនផលិតភាពដោយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគាំទ្រនូវការគ្រប់គ្រងមួយដែលធ្វើដោយឆ្លើយតបនឹងការបញ្ជាទិញរបស់អតិថិជន ហើយប្រើប្រាស់ពេលវេលាសមរម្យ។

### ៣.១.៣ ចំពោះសេដ្ឋកិច្ច

ការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនាំមកនូវការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា ដោយសារក្រុមហ៊ុនអន្តរជាតិដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចបង្កើតបណ្តាញចែកចាយសម្រាប់អ្នកផ្គត់ផ្គង់ ក៏ដូចជាជ្រើសរើសកម្មករ និយោជិតផងដែរ។

គេឃើញមានកាលានុវត្តភាពច្រើនសំរាប់កម្ពុជាក្នុងការកាត់បន្ថយថ្លៃចំនាយពាណិជ្ជកម្ម និងកែលម្អភាពប្រកួតប្រជែងរបស់ខ្លួន តាមរយៈការបង្កើនល្បឿននៃកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការសម្រួល និងធ្វើឌីជីថលភាវូបនីយកម្មនីតិវិធីពាណិជ្ជកម្ម។ ការសម្រេចបានពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាមអាចជួយកម្ពុជាសន្សំប្រាក់បានជាង ២០០ លានដុល្លាអាមេរិកក្នុងមួយឆ្នាំ លើថ្លៃចំណាយប្រតិបត្តិការពាណិជ្ជកម្ម។

## ៣.២ បញ្ហាប្រឈមទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការប្រែក្លាយនៃរបត់ពាណិជ្ជកម្មបែបប្រពៃណីមកជាការធ្វើពាណិជ្ជកម្មបែបទំនើបតាមបច្ចេកវិទ្យា ថ្វីត្បិតតែនាំមកនូវកាលានុវត្តភាព តែក៏នាំមកនូវភាពប្រឈមព្រមៗគ្នាក្នុងពេលតែមួយដែរ។ ក្នុងពេលបច្ចុប្បន្ននេះ ពាណិជ្ជកម្មអេឡិចត្រូនិកក្នុងប្រទេសកម្ពុជាគឺកំពុងតែរីកចំរើនឆ្ពោះទៅមុខ ហើយចំនួនអ្នកប្រើប្រាស់គឺកាន់តែកើនឡើង ប៉ុន្តែដោយសារនៅមិនទាន់មានការគ្រប់គ្រង់ល្អប្រសើរនៅឡើយ ការយល់ដឹងលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់អ្នកប្រើប្រាស់ និងវិស័យឯកជនរួមទាំងវិនិយោគិននៅមានកម្រិតនៅឡើយ ជាហេតុនាំឱ្យមានបញ្ហាមួយចំនួនដូចជាបទល្មើសដែលកើតឡើង ហើយក៏បង្កើតឱ្យមានជាកង្វល់ក្នុងចំណោមសហគ្រាសធុនតូច និងមធ្យម និងវិនិយោគិនទាក់ទងនឹងការអនុលោមតាមច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

### ៣.២.១ បទល្មើសផ្សេងៗដែលកើតមានក្នុងពាណិជ្ជកម្មអេឡិចត្រូនិក

#### ក. ការលួចប្រើប្រាស់អត្តសញ្ញាណ

ការលួចប្រើប្រាស់អត្តសញ្ញាណ គឺជាការលួចយកទិន្នន័យ ឬព័ត៌មានផ្ទាល់ខ្លួនសំខាន់ៗ ដូចជាលេខអត្តសញ្ញាណប័ណ្ណ លេខសម្ងាត់ អាសយដ្ឋាន លេខគណនី ហើយប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីបន្លំខ្លួនធ្វើជារូបអ្នកផ្សេង ក្នុងគោលបំណងបោកប្រាស់អ្នកដ៏ទៃ ឬប្រព្រឹត្តបទល្មើសផ្សេងៗ។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មាត្រា ២២ បានប្បញ្ញត្តិថា បុគ្គលទាំងឡាយមិនត្រូវប្រើប្រាស់អត្តសញ្ញាណ កំណត់ត្រាហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ភិនភាគសម្គាល់របស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬមិនមែនតាមប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ អំពើល្មើសលើការលួចប្រើប្រាស់អត្តសញ្ញាណត្រូវផ្តន្ទាទោសដាក់

ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិមាត្រា ២២។[18]

**ខ. ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំ និងកូដព្យាបាទ**

ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំ គឺជាការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្នុងគោលបំណងក្លែងបន្លំ ឬបង្កការភាន់ច្រឡំ ដើម្បីទាយយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឱ្យមានការប្រើប្រាស់ ឬប្រតិបត្តិការ ហើយនាំឱ្យមានព្យសនកម្មដល់បុគ្គលប្រើប្រាស់នោះ ឬតតិយជន។ ចំណែកឯការបង្កើតកូដព្យាបាទវិញគឺជាលេខកូដដែលបង្កើតឡើង ឬចែកចាយក្នុងគោលបំណងទុច្ចរិតដើម្បីចម្លងមេរោគតាមប្រព័ន្ធអេឡិចត្រូនិក ទៅក្នុងឧបករណ៍ ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលផ្សេងទៀត។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបញ្ញត្តិអំពី ការបង្កើតប្រព័ន្ធអេឡិកត្រូនិកក្លែងបន្លំ និងកូដព្យាបាទ ថាបុគ្គលទាំងឡាយមិនត្រូវបង្កើតប្រព័ន្ធអេឡិចត្រូនិកក្នុងគោលបំណងក្លែងបន្លំ ឬបង្កការភាន់ច្រលំដើម្បីទាយយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឱ្យមានការប្រើប្រាស់ ឬប្រតិបត្តិការហើយនាំឱ្យមានព្យសនកម្មដល់បុគ្គលប្រើប្រាស់នោះ ឬតតិយជនឡើយ។ បុគ្គលទាំងឡាយមិនត្រូវបង្កើត ផ្តល់ បង្ករលទ្ធភាព ចែកចាយ ឬបញ្ជូននូវលេខកូដចម្លងមេរោគតាមប្រព័ន្ធអេឡិចត្រូនិក ទៅក្នុងឧបករណ៍ ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលផ្សេងទៀតឡើយ។[19] អំពើល្មើសលើការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំ និងកូដព្យាបាទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ៣ (បី) ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។[20]

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបញ្ញត្តិអំពីអំពើល្មើសផ្សេងៗ ដូចជា អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ អំពើល្មើសលើការការបំពានកូដនីយកម្ម។ល។[21]

## ៣.២.២ បញ្ហាប្រឈម និងកង្វល់របស់សហគ្រាស និងភាគីពាក់ព័ន្ធ

### ក. បញ្ហាប្រឈមរបស់សហគ្រាស

បើទោះបីជា មជ្ឈដ្ឋានពាណិជ្ជកម្មទូទៅមានការរីចម្រើនក៏ដោយ ប៉ុន្តែសហគ្រាសធនតូច និងមធ្យមមួយចំនួនធំក៏ជួបបញ្ហាច្រើនដែលមានដូចជា ៖

- ពុំទាន់មានក្របខ័ណ្ឌរួមសម្រាប់អភិវឌ្ឍសហគ្រាសធនតូច និងមធ្យមដែលបណ្តាលឱ្យយន្តការជំនួយសម្រាប់សហគ្រាសធនតូច និងមធ្យមមានភាពយឺតបន្តិច និងអាចបង្កើតហានិភ័យក្នុងការ

[18] មាត្រា ៥៣ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩
[19] មាត្រា ៣១ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩
[20] មាត្រា ៥៩ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩
[21] មើលជំពូកទី ១១ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩

រៀបចំគោលនយោបាយមិនចំគោលដៅ។ នាពេលបច្ចុប្បន្នកម្ពុជាមិនទាន់មានក្របខ័ណ្ឌរួមដើម្បីអភិវឌ្ឍសហគ្រាសធនតូច និងមធ្យមច្បាស់លាស់នៅឡើយទេ ដោយសារតែការអនុវត្តសកម្មភាពគោលនយោបាយមានលក្ខណៈដាច់ៗពីគ្នាក្នុងក្រសួងស្ថាប័ននីមួយៗ។

- គោលការណ៍អភិវឌ្ឍន៍សហគ្រាសធនតូច និងមធ្យមកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ ដែលដឹកនាំដោយក្រសួងឧស្សាហកម្ម និងវិទ្យាសាស្ត្រ និងនវានុវត្តន៍ ហើយគោលការណ៍នេះមានភាពស្រពិចស្រពិលទាក់ទងនឹងទំនួលខុសត្រូវរបស់ទីភ្នាក់ងារផ្សេងៗ ដោយសារតែចន្លោះប្រហោងក្នុងការផ្តល់ព័ត៌មានតាមគេហទំព័ររួមមួយ ដែលអាចបណ្តោយឱ្យមានភាពទន់ខ្សោយក្នុងការអនុវត្តន៍ និងសម្របសម្រួលគោលនយោបាយ ព្រមទាំងវិធានការផ្សេងៗឱ្យមានប្រសិទ្ធិភាព។
- សហគ្រាសធនតូច និងមធ្យមដែលនៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិស័យបច្ចេកវិទ្យា គឺមិនទាន់មានការយល់ដឹង និងគាំទ្រទូលំទូលាយដូចវិស័យផ្សេងទៀតនៅឡើយ។
- ការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិកតែម៉្យាង គឺមិនគ្រប់គ្រាន់ក្នុងការធ្វើឱ្យស្ថានភាពសហគ្រាសធនតូច និងមធ្យមកាន់តែល្អប្រសើរនោះទេ។ វិស័យឯកជនគូសបញ្ជាក់ថាដំណើរការចុះបញ្ជីក្រុមហ៊ុនមានលក្ខណៈល្អប្រសើរច្រើន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយក្រសួងពាណិជ្ជកម្មទទួលបានការកោតសរសើរសម្រាប់ធ្វើឱ្យដំណើការនេះមានលក្ខណៈល្អប្រសើរ។ ប៉ុន្តែនៅតែមានបញ្ហាអូសបន្លាយពេលវេលា និងបញ្ហាពាក់ព័ន្ធមួយចំនួនបន្ទាប់ពីការចុះបញ្ជីសម្រាប់ក្រុមហ៊ុនដែលមានសកម្មភាពក្នុងវិស័យច្រើនលើសពីមួយ។ ឧទាហរណ៍ ៖ ក្នុងករណីសហគ្រាសពាណិជ្ជកម្មក្នុងប្រព័ន្ធអេឡិចត្រូនិកធ្វើការលើវិស័យថែទាំសុខភាពតាមប្រព័ន្ធអេឡិចត្រូនិក ការចុះបញ្ជីសហគ្រាសធនតូច ឬមធ្យមជាមួយតែក្រសួងពាណិជ្ជកម្មនៅមិនទាន់គ្រប់គ្រងនៅទេ គឺតម្រូវឱ្យមានអាជ្ញាបណ្ណពីក្រសួងសុខាភិបាលផងដែរ។

### ខ. គង្វល់របស់ភាគីពាក់ព័ន្ធ

អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ជាកង្វល់ដ៏ធំមួយរបស់ភាគីពាក់ព័ន្ធក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ជាទូទៅត្រូវបានគេស្គាល់ថាជាអំពើដែលផ្ទុយនឹងការអនុវត្តសុចរិតទៀងត្រង់នៅក្នុងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម។[22] ទង្វើដែលចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់មានដូចជា៖

[22] មាត្រា ២២ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

- ការបង្កើតឱ្យមានការភាន់ច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ឬទំនិញ ឬក៏សកម្មភាព ឬសេវាកម្មនៃដៃគូការប្រកួតប្រជែង។
- ការពោលអះអាងមិនត្រឹមត្រូវដែលក្នុងពាណិជ្ជកម្មដែលធ្វើឱ្យខូចឈ្មោះសហគ្រាស ឬទំនិញ ឬក៏សកម្មភាព ឬសេវាកម្មនៃដៃគូការប្រកួតប្រជែង។
- ការបញ្ជាក់ ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឱ្យសាធារណៈជនភាន់ច្រលំអំពីប្រភេទ ដំណើរការផលិត លក្ខណៈ ភាពសមស្រប សម្រាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ។[23]

ជាការពិតណាស់អំពើនេះការប្រកួតប្រជែងមិនស្មោះត្រង់គឺ ជាបញ្ហាប្រឈមមួយក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយសារតែពាណិជ្ជករមួយចំនួនមានគំនិតទុច្ចរិតគិតថា ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកងាយស្រួលក្នុងការក្លែងបន្លំទំនិញ ឬសេវាកម្ម ដោយសាតែអតិថិជនមិនអាចពិនិត្យមើលទំនិញផ្ទាល់មុនធ្វើការបញ្ជាទិញបាន។

សម្រាប់សហគ្រាស និងវិនិយោគិនបរទេស ការព្រួយបារម្ភគឺទាក់ទងនឹងភាពមិនច្បាស់លាស់ទាក់ទងនឹងថ្លៃដើមនៃការអនុលោមតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ។ សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានលើកឡើងពីការព្រួយបារម្ភថា ការអនុលោមតាមតម្រូវការស្តីពីការកត់ត្រាប្រតិបត្តិការតាមសៀវភៅ អាចធ្វើឱ្យក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្ថិតក្នុងស្ថានភាពប្រកួតប្រជែងទាបជាងអ្នកលក់រាយតាមបែបប្រពៃណី ដោយសារការអនុវត្តគណនេយ្យមិនមានស្តង់ដា និងការកត់ត្រាប្រតិបត្តិការមិនត្រឹមត្រូវជាដើម។ តម្លៃនៃការអនុលោមតាមបទដ្ឋានសន្តិសុខអ៊ិនធឺណិត និងបទដ្ឋានផ្សេងទៀតក៏ជាការព្រួយបារម្ភមួយផងដែរ។

## ៣.៣ លទ្ធផលសម្រេចបានឆ្នាំ២០២០ និងគោលដៅយុទ្ធសាស្ត្រឆ្នាំ២០២១ របស់ក្រសួងពាណិជ្ជកម្ម

### ៣.៣.១ លទ្ធផលសម្រេចបានឆ្នាំ២០២០

របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២០ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២១ ក៏បានរៀបរាប់អំពីលទ្ធផលការងារពាណិជ្ជកម្មដែលសម្រេចបានកាលពីឆ្នាំ២០២០ កន្លងទៅទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែរ។ លទ្ធផលសម្រេចបានដែលទាក់ទាងជាពិសេសនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានដូចតទៅ៖

[23] មាត្រា ២៣ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

- បានបង្កើនគុណភាពសេវាសាធារណៈ ដោយបានកែទម្រង់ការងារចុះបញ្ជីពាណិជ្ជកម្មដោយបង្កើតប្រព័ន្ធចុះបញ្ជីថ្មីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់រាជរដ្ឋាភិបាល (CamDX) ដែលអាចសម្រួលការចុះបញ្ជីពាណិជ្ជកម្មបានលឿនជាងមុន និងបានតភ្ជាប់ព័ត៌មាន ជាមួយអគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធស្វ័យប្រវត្តកម្មរដ្ឋបាលកម្មសិទ្ធបញ្ញា ការដាក់ពាក្យស្នើសុំ និងការបង់កម្រៃសេវាតាមប្រព័ន្ធអនឡាញ
- បានរៀបចំមជ្ឈមណ្ឌលទិន្នន័យថ្មីមួយសម្រាប់ផ្ទុកព័ត៌មាន និងដំណើរការប្រព័ន្ធស្វ័យប្រវត្តកម្មចុះបញ្ជីពាណិជ្ជកម្ម ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ទិន្នន័យកម្មសិទ្ធិបញ្ញា និងព័ត៌មានផ្សេងៗទៀត
- បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងរដ្ឋបាលកម្មសិទ្ធិឧស្សាហកម្មជំនាន់ទី៤ ដើម្បីសម្រួលការងារចុះបញ្ជីម៉ាក និងផ្តល់សេវាកម្មតាមអនឡាញ
- បានបញ្ចប់ជាស្ថាពរអនុក្រឹត្យ ស្តីពី ការកំនត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអេឡិចត្រូនិក និងការលើកលែង។[24]

ក្រៅពីនេះ របាយការណ៍នេះបានរៀបរាប់អំពី ការផ្តល់សេវាពាណិជ្ជកម្ម ការសម្រេចការងារពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផលទំនិញ ការធ្វើប្រតិបត្តិការសេដ្ឋកិច្ច និងសមាហរណកម្មសេដ្ឋកិច្ចជាមួយអន្តរជាតិ ព្រមទាំងសកម្មភាពការបណ្តុះបណ្តាលធនធានមនុស្សពីការយល់ដឹងបន្ថែមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលសុទ្ធសឹងតែជាសកម្មភាពដែលជួយពង្រឹងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

### ៣.៣.២ គោលដៅយុទ្ធសាស្ត្រឆ្នាំ២០២១

ពាណិជ្ជកម្មអេឡិចត្រូនិកបានរីកចម្រើនយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោកក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ ដោយសារជំងឺកូវីដ-១៩ ការលក់តាមអ៊ិនធឺណិតនៅតាមទីផ្សារភាគច្រើននៃប្រទេសនានានៅលើពិភពលោកបានកើនឡើងយ៉ាងឆាប់រហ័សនៅឆ្នាំ២០២០ ហើយគេជឿជាក់ថាឥទ្ធិពលនេះនឹងស្ថិតនៅយូរអង្វែង។ តាមការប៉ានស្មានក្នុងរយៈពេល ៥ ឆ្នាំខាងមុខការលក់តាមប្រព័ន្ធអេឡិចត្រូនិកនឹងកើនឡើង ១.៥ ទ្រីលានដុល្លារ (២.៤ ទ្រីលាននៅឆ្នាំ២០២០)។ ការជ្រៀតចូលនៃពាណិជ្ជកម្មអេឡិចត្រូនិកនឹងបន្តលូតលាស់ ហេតុនេះដើម្បីគាំទ្រដល់ការរីកចម្រើននៃពាណិជ្ជកម្មអេឡិចត្រូនិកចាំបាច់ត្រូវពង្រឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន

[24] របាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២០ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២១ របស់ក្រសួងពាណិជ្ជកម្ម

និងគមនាគមន៍។ សកម្មភាពដ៏ផុសផុលរបស់វិស័យឯកជននៅក្នុងប្រព័ន្ធអេកូឡូហ្ស៊ីនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងយល់ដល់បញ្ហាប្រឈមព្រមទាំងកង្វល់របស់ភាគីពាក់ព័ន្ធ បានជំរុញឱ្យរាជរដ្ឋាភិបាលរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមានភាពប្រទាក់ក្រឡា និងសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់វិស័យនេះនៅក្នុងប្រទេសកម្ពុជា។ ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងកម្រិតជាតិនិងអន្តរជាតិ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយធ្វើការសម្របសម្រួលជាមួយនឹង ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ។[25] ក្នុងគោលបំណងជំរុញការលូតលាស់ពោរពេញទៅដោយចីរភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្រសួងពាណិជ្ជកម្មក្រោមការឧបត្ថម្ភហិរញ្ញប្បទានពីស្ថាប័នក្របខ័ណ្ឌពង្រឹងសមាហរណកម្មពាណិជ្ជកម្ម (Enhanced Integrated Framework - EIF) បានរៀបចំឯកសារយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីជាផែនទីបង្ហាញផ្លូវដល់ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងក្របខ័ណ្ឌរួមមួយ ដោយវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាវិស័យថ្មីដែលទើបតែផុសផុលក្នុងប្រទេសកម្ពុជា ប៉ុន្តែវិស័យនេះជាវិស័យមួយដែលពោរពេញទៅដោយសក្តានុពលក្នុងការបង្កើតប្រភពកំណើនថ្មីដល់សេដ្ឋកិច្ចប្រទេសកម្ពុជា។[26]

ដើម្បីទាញយកកាលានុវត្តភាព ក៏ដូចជាដោះស្រាយបញ្ហាប្រឈមក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា គោលដៅយុទ្ធសាស្ត្រជាន់ខ្ពស់ចំនួន ៥ ត្រូវបានស្នើឡើង ដែលគោលដៅយុទ្ធសាស្ត្រទាំងនោះមានដូចតទៅៈ

- គោលដៅយុទ្ធសាស្ត្រទី១ៈ លើកកម្ពស់បរិយាកាសធុរកិច្ច ក្របខ័ណ្ឌបទប្បញ្ញត្តិ និងការសម្របសម្រួលស្ថាប័ន
- គោលដៅយុទ្ធសាស្ត្រទី២ៈ បង្កើនសមត្ថភាពសហគ្រាសធុនតូច និងមធ្យម និងបង្កើនការសម្របសម្រួលនៅក្នុងខ្សែចង្វាក់តម្លៃ
- គោលដៅយុទ្ធសាស្ត្រទី៣ៈ លើកកម្ពស់ការដឹកជញ្ជូនក្នុងស្រុក និងឆ្លងកាត់ព្រំដែន
- គោលដៅយុទ្ធសាស្ត្រទី៤ៈ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ការទទួលបានហិរញ្ញប្បទានដោយបរិយាប័ន្ន និងអក្ខរកម្មឌីជីថលដើម្បីឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករីកដុះដាលទូទាំងប្រទេស

[25] មាត្រា ៤ អនុក្រឹត្យស្តីពីការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង

[26] យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ២០២០ ដឹកនាំរៀបចំដោយក្រសួងពាណិជ្ជកម្ម

- គោលដៅយុទ្ធសាស្ត្រទី៥៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជំនាញដែលមានភាពឆ្លើយតបសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។[27]

[27] យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ២០២០ ដឹកនាំរៀបចំដោយក្រសួងពាណិជ្ជកម្ម

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការបកស្រាយទៅលើប្រធានបទស្តីពី វិធានគតិយុត្តស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចមក ក្រុមយើងខ្ញុំយល់ថាប្រធានបទនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់យើងខ្ញុំជានិស្សិត អ្នកស្រាវជ្រាវក្នុងការពង្រីកចំណេះដឹងទៅលើច្បាប់ដែលទើបតែអនុវត្តក្នុងពេលថ្មីៗនេះ និងក្នុងនាមជាបុគ្គលម្នាក់ដែលជាអតិថិជន និងអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ស្របពេលដែលប្រទេសកម្ពុជាកំពុងស្ថិតក្នុងរបត់មួយដែលប្រជាជនភាគច្រើនកំពុងចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើពាណិជ្ជកម្មប្រភេទនេះ មិនថាក្នុងនាមជាពាណិជ្ជករក្តី ឬជាអ្នកប្រើប្រាស់ក្តី។

ក្នុងរយៈពេលដែលយើងខ្ញុំសិក្សាស្រាវជ្រាវបង្កើតឱ្យចេញជាសារណានេះឡើង យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពោលគឺបានស្គាល់ស៊ីជម្រៅទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អំពីប្រវត្តិព្រមទាំងការរីករាលដាលយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជា និងដំណើរប្រតិបត្តិការពាណិជ្ជកម្មអេឡិចត្រូនិក ក៏បានយល់ពីបញ្ហាប្រឈមនៃពាណិជ្ជកម្មអេឡិចត្រូនិក ហើយក៏ដូចជាគោលដៅយុទ្ធសាស្ត្រវិស័យនៃពាណិជ្ជកម្មអេឡិចត្រូនិកទៅថ្ងៃអនាគត។

គេសង្កេតឃើញថា ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានវិសាលភាពធំទូលាយ គ្របដណ្តប់លើសកម្មភាពប្រតិបត្តិការផ្នែករដ្ឋប្បវេណី និងពាណិជ្ជកម្ម និងរបស់រាជរដ្ឋាភិបាល ហើយមានចែងពីល័ក្ខខ័ណ្ឌតម្រូវការបង្កើតកិច្ចសន្យាអេឡិចត្រូនិក ដំណើរប្រព្រឹត្តទៅនៃទំនាក់ទំនងអេឡិចត្រូនិក ការទទួលខុសត្រូវអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កិច្ចការពារអ្នកប្រើប្រាស់ ការទូទាត់និង-ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក នីតិវិធីនៃការផាកពិន័យ និងទោសប្បញ្ញត្តិនានាទាក់ទងបទល្មើសប្រឆាំងនឹងប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ កំណត់និយមន័យព្រមទាំងទោសទណ្ឌនៃបទល្មើសទាំងនោះ។

ក្នុងឱកាសដែលសេដ្ឋកិច្ចរបស់ប្រទេសកាន់តែរីកចម្រើន ព្រមទាំងលក្ខណៈអំណោយផលកាន់តែប្រសើរឡើងនៃប្រព័ន្ធអ៊ិនធឺណិត និងបច្ចេកវិទ្យាទំនើប ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសក្តានុពលយ៉ាងធំធេងក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិបន្ថែមទៀតស្របពេលកម្ពុជាកំពុងឈានទៅរកបដិវត្តន៍ឧស្សាហកម្ម៤.០ ។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនឹងផ្តល់នូវមធ្យោបាយសម្រាប់អាជីវកម្មកម្ពុជាជាពិសេស សហគ្រាសធនតូច និងមធ្យមដើម្បីផ្សព្វផ្សាយ និងឈានដល់មូលដ្ឋានអតិថិជនកាន់តែទូលំទូលាយ ហើយថែមទាំងលើកកម្ពស់ការប្រកួតប្រជែង និងជំរុញកំណើនវិស័យឯកជន ដែលជាលទ្ធផលបង្កើតឱ្យមានការងារ និងការធ្វើសមាហរណកម្មប្រកបដោយអត្ថន័យដល់យុវជន និងស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច។ ដូចនេះការខិតខំប្រឹងប្រែងរបស់ស្ថាប័នជំនាញ និងក្រសួងពាក់ព័ន្ធក្នុងការរៀបចំតាក់តែង ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដើម្បីគ្រប់គ្រងទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនឹងរួមចំណែកធានាបាននូវសុក្រឹតភាព

និងសុវត្ថិភាពដល់គ្រប់ភាគីពាក់ព័ន្ធ។ សមិទ្ធផលទាំងអស់នេះបានមកពីការដឹកនាំ និងការខិតខំប្រឹងប្រែងយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នជំនាញនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មអេឡិចត្រូនិក ទើបសេដ្ឋកិច្ចកម្ពុជាមិនមានការកកស្ទះទាំងស្រុងក្នុងសម័យរីករាលដាលនៃជំងឺកូវីដ-១៩។ ម្យ៉ាងទៀតនៅពេលដែលស្ថានភាពជំងឺនេះបានធូរស្បើយ យើងអាចរំពឹងបានថាសេដ្ឋកិច្ចជាតិនឹងកាន់តែរីកចម្រើនដោយសារតែរបត់ពាណិជ្ជកម្មបែបទំនើបនេះ។

# អនុសាសន៍

តាមរយៈការស្រាវជ្រាវលើសារណានេះ ក្រុមយើងខ្ញុំសង្កេតឃើញថា ថ្វីត្បិតតែច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានក្រសួងជំនាញព្រិតព្រាងក្នុងការតាក់តែងយ៉ាងណាក្តី ក៏ភាពខ្វះចន្លោះត្រូវបានគេមើលឃើញ ហើយបញ្ហាប្រឈមទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិកក៏មិនអាចជៀសវាងបាន។ មូលដ្ឋានច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅមិនទាន់មានលក្ខណៈពេញលេញនូវឡើយ ដែលចាំបាច់ត្រូវតែពង្រឹង និងបំពេញបន្ថែម។ ដើម្បីចូលរួមបំពេញបន្ថែមទៅលើច្បាប់ទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យកាន់តែមានលក្ខណៈពេញលេញជាងនេះត្រូវមានច្បាប់ផ្សេងៗទៀតដូចជា ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងច្បាប់ស្តីពីការប្រកួតប្រជែងជាដើម ហើយច្បាប់ទាំងនេះក៏ទាមទារឱ្យមានការសិក្សាយល់ដឹងស៊ីជម្រៅ ទើបការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសុក្រឹតភាព។ ដើម្បីចូលរួមជាចំណែកមួយក្នុងការជំរុញឱ្យការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងអនុវត្តនៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកឱ្យកាន់តែមានប្រសិទ្ធិភាព និងភាពរីកចម្រើនលើសពីនេះ យើងខ្ញុំទាំងពីរសូមចូលរួមជាមួយនឹងគំនិតបន្តិចបន្តួចជាយោបល់ ដោយសូមសំណូមពរទៅដល់រាជរដ្ឋាភិបាល និងសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ៖

១. បំពេញក្របខ័ណ្ឌច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានរបស់កម្ពុជា ដោយបញ្ចូលចំណុចពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទៅក្នុងសេចក្តីព្រាងច្បាប់នេះឱ្យបានឆាប់រហ័ស

២. ធានាឱ្យបានការអនុវត្តច្បាប់ផ្សេងៗទៀតដូចជា ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងច្បាប់ស្តីពីការប្រកួតប្រជែងដែលមានសារៈសំខាន់ក្នុងការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីបង្កើនទំនុកចិត្តកាន់តែខ្លាំងក្នុងការបង្កើត និងប្រើប្រាស់កម្មវិធីតាមអ៊ីនធឺណិត

៣. បញ្ជ្រាបការយល់ដឹងដល់អ្នកប្រើប្រាស់ និងវិស័យឯកជនរួមទាំងវិនិយោគិន លើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៤. ធានាបន្ថែមនូវការបណ្តុះបណ្តាលការយល់ដឹង និងលើកកម្ពស់ការយល់ដឹងទៅភាគីពាក់ព័ន្ធ ដើម្បីឱ្យយល់ច្បាស់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ដែលអាចធ្វើឡើងតាមរយៈការពិគ្រោះយោបល់ផ្ទាល់ ក៏ដូចជាធ្វើឱ្យទាន់សម័យនូវព័ត៌មាននានាដែលត្រូវបានផ្សព្វនៅលើគេហទំព័រផ្លូវការ

៥. ធានាកិច្ចសហប្រតិបត្តិការរួមគ្នារវាងវិស័យសាធារណៈ វិស័យឯកជន និងតួអង្គគាំទ្រដែលរួមមានស្ថាប័នហិរញ្ញវត្ថុ អ្នកបណ្តុះបណ្តាលជំនាញ ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ អ្នកវិនិយោគ និយ័តករទូរគមនាគមន៍ និងហរិញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍

៦. ធានាការអនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្មអេឡិចត្រូនិកបន្ថែមទៀត ប្រកបដោយការយកចិត្តទុកដាក់ និងមានទំនួលខុសត្រូវខ្ពស់បំផុត ដើម្បីធានាប្រសិទ្ធិភាពនៃយុទ្ធសាស្ត្រដែលដាក់ចេញ

យើងខ្ញុំទាំងពីរសង្ឃឹមថា សំណូមពរខាងលើនេះនឹងអាចជួយដល់ការប្រព្រឹត្តិទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសកម្ពុជាយើងកាន់តែល្អប្រសើរ ហើយដើម្បីការអនុវត្តន៍នៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកនឹងមានប្រសិទ្ធិភាពលើសពីនេះទៀត ពីព្រោះវានឹងផ្តល់ជាប្រយោជន៍ដល់ការអភិវឌ្ឍន៍កាន់តែខ្លាំងជាងនេះនាពេលអនាគត។ ក្រុមយើងខ្ញុំសង្ឃឹមថាសំណូមពរទាំងនេះនឹងត្រូវបានយកទៅពិចារណា និងត្រួតពិនិត្យដោយអាជ្ញាធរពាក់ព័ន្ធទាំងអស់។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០០៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩
- ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦
- ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩
- ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
- ច្បាប់ស្តីពីច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០១
- អនុក្រឹត្យលេខ ២៤៦ ស្តីពីហត្ថលេខាឌីជីថល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧
- អនុក្រឹត្យស្តីពីការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០
- អនុក្រឹត្យ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១
- ប្រកាសស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៧
- ប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧
- សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

- ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៨ (UNCITRAL Model Law on Electronic Economic) (ចូលទស្សនាចុងក្រោយថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១)

https://uncitral.un.org/sites/uncitral.un.org/files/media-documents/uncitral/en/19-04970_ebook.pdf

- ច្បាប់ស្តីពីហត្ថលេខាអេឡិចត្រូនិក (ឆ្នាំ២០០០)

## សៀវភៅ និងអត្ថបទផ្សេងៗ

- វចនានុក្រមជួនណាត បោះពុម្ពលើកទី៥ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត ឆ្នាំ១៩៦៧

- វចនានុក្រម Longman បោះពុម្ពលើកទី៣ ទំព័រ២៦៥ និង ៤៤៥
- សន្ទានុក្រមពាក្យច្បាប់ពាណិជ្ជកម្ម (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១)

https://drive.google.com/file/d/1mycp0AAs7X8TDNi6ipZdj36H5oosM7sW/view?fbclid=IwAR0tua6faf9cJZKFXMCyVIWUv9ybwOXY4jX2lbiAdX5s17ISuAN29auf1bc

- កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក ដោយឯកឧត្តម ចម ប្រសិទ្ធ បោះពុម្ពខែសីហា ឆ្នាំ២០០៤
- យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដឹកនាំរៀបចំក្រសួងពាណិជ្ជកម្ម គាំទ្រដោយស្ថាប័នក្របខ័ណ្ឌពង្រឹងសមាហរណកម្មពាណិជ្ជកម្ម
- អនុសាសន៍របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ស្តីពីការការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ២០១៦) (Consumer Protection in E-Commerce, OECD Recommendations, 2016) (ចូលទស្សនាចុងក្រោយថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២១)

https://www.oecd.org/sti/consumer/ECommerce-Recommendation-2016.pdf

- ការវាយតម្លៃភាពត្រៀមខ្លួនរួចរាល់សម្រាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាមៈ កម្ពុជា បោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិ ឆ្នាំ២០១៩
- ការវាយតម្លៃភាពត្រៀមខ្លួនរួចរាល់សម្រាប់ការធ្វើជំនួញតាមប្រព័ន្ធអេឡិចត្រូនិក Cambodia Rapid eTrade Readiness Assessment (ចូលទស្សនាចុងក្រោយថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២១)

https://unctad.org/system/files/official-document/dtlstict2017d2_en.pdf

- របាយការណ៍បូកសរុបលទ្ធផលពាណិជ្ជកម្មឆ្នាំ២០២០ និងទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២១ របស់ក្រសួងពាណិជ្ជកម្ម (ចូលទស្សនាចុងក្រោយថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២១)

http://www.moc.gov.kh/Portals/0/Docs/TradeInfo/ARanual%20Report%202020%20to%202021-20210401071236323.pdf

- សារណាបញ្ចប់ការសិក្សា សរសេរដោយ យ៉េន វណ្ណីដា និងអ៊ឹង ហ៊ុយគង់ ដឹកនាំដោយសាស្ត្រាចារ្យ ប៉ូលី បញ្ញា ឆ្នាំ២០១៧ (ចូលទស្សនាចុងក្រោយថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១)

http://www.elibrary-rule.com/ViewerJS/#../public/images/sarana_file/2017Thesis(134).pdf

- ក្របខ័ណ្ឌយោងអ៊ី-អាស៊ានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក (ចូលទស្សនាចុងក្រោយថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១)

https://asean.org/wp-content/uploads/images/2012/Economic/TELMIN/e-Asean%20Reference%20Framework.pdf

- ចក្ខុវិស័យពាណិជ្ជកម្មអេឡិចត្រូនិកសកលរបស់ CBRE ឆ្នាំ ២021 (ចូលទស្សនាចុងក្រោយថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២១)

https://www.cbre.com/research-and-reports/Global-E-Commerce-Outlook-2021

- សារណាបញ្ចប់ថ្នាក់អនុបណ្ឌិតអំពីបទដ្ឋានច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅអាស៊ាន៖ ច្បាប់គំរូ ឆ្នាំ២០០៦ (E-commerce legal framework for ASEAN: A Model Code) (ចូលទស្សនាចុងក្រោយថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២១)

https://scholarbank.nus.edu.sg/handle/10635/15500

**គេហទំព័រ**

- គេហទំព័រហិរញ្ញវត្ថុInvestopedia (ចូលទស្សនាចុងក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១)

https://www.investopedia.com/terms/c/commerce.asp

- គេហទំព័រធនាគារជាតិនៃកម្ពុជា (ចូលទស្សនាចុងក្រោយថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០២១)

https://www.nbc.org.kh/english/payment_systems/role_of_nbc_in_payment_systems.php

- គេហទំព័រDATAREPORTAL ឌីជីថល ២០២១៖ កម្ពុជា (ចូលទស្សនាចុងក្រោយថ្ងៃទី ១៨ខែមិថុនា ឆ្នាំ២០២១)

https://datareportal.com/reports/digital-2021-cambodia

- គេហទំព័រក្រសួងពាណិជ្ជកម្ម (ចូលទស្សនាចុងក្រោយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១)

http://www.moc.gov.kh/en-us/projects/year/2009/name/3

- គេហទំព័រអង្គការពាណិជ្ជកម្មពិភពលោក (ចូលទស្សនាចុងក្រោយថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១)

https://www.wto.org/

**សារព័ត៌មាន**

- កម្ពុជាដាក់ចេញយុទ្ធសាស្ត្រពាណិជ្ជកម្មអេឡិចត្រូនិក (Cambodia Launches E-Commerce Strategy) (ចូលទស្សនាចុងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១)

https://www.b2b-cambodia.com/articles/cambodia-launches-e-commerce-strategy/?fbclid=IwAR1MWJ6-O-8N3kwXuzlhlc99l9D3IwAZV_WoCiXwwst77JcoCE-D44pDWCs

- រដ្ឋសភា អនុម័តទាំងស្រុងលើ សេចក្តីព្រាងច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច (ចូលទស្សនា ចុងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១)

https://www.cambodia4point0.org/kh/asdfasjdfasdfasdg#.YR7AnIgzbOh

- ច្បាប់ស្តីពីការប្រកួតប្រជែង អាចនឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗនេះ (ចូលទស្សនាចុងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១)

https://www.postkhmer.com/សេដ្ឋកិច្ច/ច្បាប់ស្តីពីច្បាប់ស្តីពីការប្រកួតប្រជែង-អាចនឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗនេះ

- ក្រសួងសេដ្ឋកិច្ច៖ អនុក្រឹត្យ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនជាការបង្កើតពន្ធថ្មីនោះទេ

http://m.freshnewsasia.com/index.php/en/localnews/193880-2021-04-14-05-02-17.html

# ឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ១** | **គំរូឯកសារ** |
| ឧបសម្ព័ន្ធ១.ក | ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (សម្រាប់រូបវន្តបុគ្គល) |
| ឧបសម្ព័ន្ធ១.ខ | ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (សម្រាប់សហគ្រាសឯកបុគ្គល) |
| ឧបសម្ព័ន្ធ១.គ | ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (សម្រាប់នីតិបុគ្គលសាខាក្រុមហ៊ុនបរទេស) |
| **ឧបសម្ព័ន្ធ២** | **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ** |
| ឧបសម្ព័ន្ធ២.ក | ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| ឧបសម្ព័ន្ធ២.ខ | អនុក្រឹត្យស្តីពីការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម |
| ឧបសម្ព័ន្ធ២.គ | ប្រកាសស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |

# ឧបសម្ព័ន្ធ១

# គំរូឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

*ឧបសម្ព័ន្ធទី១*

# ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
## (សម្រាប់រូបវន្តបុគ្គល)

| ព័ត៌មានស្នើសុំលិខិតអនុញ្ញាត | | | | | |
|---|---|---|---|---|---|
| ១. ឈ្មោះអាជីវកម្ម | | | | | |
| ជាភាសាខ្មែរ | | | | | |
| ជាភាសាអង់គ្លេស | | | | | |
| ២. កម្មវត្ថុអាជីវកម្ម | | | | | |
| កម្មវត្ថុអាជីវកម្មចម្បង | | | | | |
| កម្មវត្ថុអាជីវកម្មបន្ទាប់ (ប្រសិនបើមាន) | | | | | |
| | | | | | |
| | | | | | |
| ៣. ទីតាំងអាជីវកម្ម | | | | | |
| ផ្ទះលេខ/អគារ | | ផ្លូវ | | ភូមិ | |
| ឃុំ/សង្កាត់ | | ស្រុក/ខណ្ឌ/ក្រុង | | រាជធានី/ខេត្ត | |
| លេខទូរស័ព្ទ (ដែលបានចុះបញ្ជី) | | | | | |
| អ៊ីមែល (E-mail) | | | | | |
| ៤. អត្តសញ្ញាណរបស់រូបវន្តបុគ្គល | | | | | |
| ឈ្មោះពេញ (ភាសាខ្មែរ) | | | | | |
| គោត្តនាម | | នាម | | | |
| ឈ្មោះ (ភាសាអង់គ្លេស) | | | | | |
| Family Name | | First Name | | | |

| | | | | | |
|---|---|---|---|---|---|
| ថ្ងៃ/ខែ/ឆ្នាំកំណើត | | សញ្ជាតិ | | ភេទ | |
| លេខអត្តសញ្ញាណប័ណ្ណ | | | | | |
| ថ្ងៃខែឆ្នាំផ្តល់ | | ថ្ងៃខែឆ្នាំផុតកំណត់ | | | |
| អាសយដ្ឋានបច្ចុប្បន្ន | | | | | |
| ផ្ទះលេខ/អគារ | | ផ្លូវ | | ភូមិ | |
| ឃុំ/សង្កាត់ | | ស្រុក/ខណ្ឌ/ក្រុង | | រាជធានី/ខេត្ត | |
| ប្រទេស | | | | | |

**៥. មធ្យោបាយអេឡិចត្រូនិកសម្រាប់ធ្វើអាជីវកម្ម**

**៥.១. មធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងជាមួយអតិថិជន**

| | | |
|---|---|---|
| វេបសាយ (Website) | | |
| បណ្តាញទំនាក់ទំនងសង្គម៖ | ☐ Facebook ☐ Instagram ☐ Youtube<br>☐ Line, Other.................................... | ឈ្មោះគណនី<br>........................................................................ |
| កម្មវិធីអេឡិចត្រូនិក<br>(Electronic Application) | | |

| | |
|---|---|
| ៥.២.មធ្យោបាយទូទាត់ប្រាក់ | ☐ ភ្នាក់ងារផ្ទេរប្រាក់ ☐ ធនាគារ ☐ទូទាត់ប្រាក់តាមរយៈភ្នាក់ងារប្រគល់ទំនិញ<br>☐ ផ្សេងៗ៖........................................................................ |
| ឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់ | |
| ឈ្មោះគណនីសម្រាប់ទូទាត់ | |
| លេខគណនីសម្រាប់ទូទាត់ | |

**៥.៣. មធ្យោបាយបញ្ជូនទំនិញជូនអតិថិជន**

| | |
|---|---|
| តាមរយៈ | ☐ បុគ្គលិកផ្ទាល់ខ្លួន<br>☐ ភ្នាក់ងារបញ្ជូនទំនិញ<br>☐ តាមប្រៃសណីយ៍<br>☐ ផ្សេងៗ........................................................................ |

**៥.៤. ទម្រង់កិច្ចការពារអ្នកប្រើប្រាស់**

| | |
|---|---|
| បរិយាយអំពីលក្ខខណ្ឌ និងខចែងអំពី៖<br>១. ទំនិញដាក់ស្តែងនិងប្រភពដើមផលិត<br>២.ការដកឬលុបចោលការបញ្ជាទំនិញដោយអ្នកទិញ<br>៣.ការបញ្ឈប់ដោយមានការព្រមព្រៀងរវាងអ្នកទិញនិងអ្នកលក់<br>៤.ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់វិញ(Refund)<br>៥.លក្ខខណ្ឌផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន | (អ្នកស្នើសុំអាចភ្ជាប់ឯកសារបន្ថែមត្រង់ចំនុចនេះ) |

សេចក្តីប្រកាសដោយសុទ្ធចិត្ត

☐ ខ្ញុំសូមប្រកាសថា ពុំមានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណីឬព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងករណីខ្ញុំជាមន្ត្រីរាជការក្នុងក្រសួង ឬស្ថាប័នរដ្ឋណាមួយនោះ សូមសន្យាថានឹងមិនយកម៉ោងរដ្ឋបាលទៅប្រកបមុខរបរនេះឡើយ ។

☐ ខ្ញុំសូមសន្យាថារាល់ព័ត៌មាន និងឯកសារដែលផ្តល់ជូន ពិតជាត្រឹមត្រូវ និងមិនក្លែងបន្លំ។

| កាលបរិច្ឆេទ | D | D | M | M | Y | Y | Y | Y |
|---|---|---|---|---|---|---|---|---|

ហត្ថលេខា ឬស្នាមមេដៃ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

*ឧបសម្ព័ន្ធទី២*

## ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
## (សម្រាប់សហគ្រាសឯកបុគ្គល)

| **ព័ត៌មានស្នើសុំលិខិតអនុញ្ញាត** | | |
|---|---|---|
| ១. នាមករណ៍សហគ្រាស | | |
| ជាភាសាខ្មែរ | | |
| ជាភាសាអង់គ្លេស | | |
| ២. អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | | |
| ៣. កម្មវត្ថុអាជីវកម្ម | | |
| កម្មវត្ថុអាជីវកម្មចម្បង | | |
| កម្មវត្ថុអាជីវកម្មបន្ទាប់ (បើមាន) | | |
| | | |
| | | |
| ៤. មធ្យោបាយអេឡិចត្រូនិកសម្រាប់ធ្វើអាជីវកម្ម | | |
| ៤.១. មធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងជាមួយអតិថិជន | | |
| វេបសាយ (Website) | | |
| បណ្តាញទំនាក់ទំនងសង្គម៖ | ☐ Facebook ☐ Instagram ☐ Youtube ☐ Line, Other ……………… | ឈ្មោះគណនី ……………… |
| កម្មវិធីអេឡិចត្រូនិក (Electronic Application) | | |
| ៤.២.មធ្យោបាយទូទាត់ប្រាក់ | ☐ ភ្នាក់ងារផ្ទេរប្រាក់ ☐ ធនាគារ ☐ទូទាត់ប្រាក់តាមរយៈភ្នាក់ងារប្រគល់ទំនិញ ☐ ផ្សេងៗ៖……………… | |
| ឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់ | | |
| ឈ្មោះគណនីសម្រាប់ទូទាត់ | | |

| | |
|---|---|
| លេខគណនីសម្រាប់ទូទាត់ | |

**៤.៣. មធ្យោបាយបញ្ជូនទំនិញជូនអតិថិជន**

| | |
|---|---|
| តាមរយៈ | ☐ បុគ្គលិកផ្ទាល់ខ្លួន<br>☐ ភ្នាក់ងារបញ្ជូនទំនិញ<br>☐ តាមប្រៃសណីយ៍<br>☐ ផ្សេងៗ.................... |

**៤.៤. ទម្រង់កិច្ចការពារអ្នកប្រើប្រាស់**

| | |
|---|---|
| បរិយាយអំពីលក្ខខណ្ឌ និងខចែងអំពី៖<br>១. ទំនិញជាក់ស្តែងនិងប្រភពដើមផលិត<br>២.ការដកឬលុបចោលការបញ្ជាទំនិញដោយអ្នកទិញ<br>៣.ការបញ្ឈប់ដោយមានការព្រមព្រៀងរវាងអ្នកទិញនិងអ្នកលក់<br>៤.ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់វិញ(Refund)<br>៥.លក្ខខណ្ឌផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន | (អ្នកស្នើសុំអាចភ្ជាប់ឯកសារបន្ថែមត្រង់ចំនុចនេះ) |

☐ ខ្ញុំសូមសន្យាថារាល់ព័ត៌មាន និងឯកសារដែលផ្តល់ជូន ពិតជាត្រឹមត្រូវ និងមិនក្លែងបន្លំ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| កាលបរិច្ឆេទ | D | D | M | M | Y | Y | Y | Y |

ហត្ថលេខាម្ចាស់សហគ្រាស និងត្រា

ក្រសួងពាណិជ្ជកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ឧបសម្ព័ន្ធទី៤*

# ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
# ( សម្រាប់នីតិបុគ្គល សាខាក្រុមហ៊ុនបរទេស )

| **ព័ត៌មានស្នើសុំអាជ្ញាបណ្ណ** | | |
|---|---|---|
| ១. នាមករណ៍ក្រុមហ៊ុន | | |
| ជាភាសាខ្មែរ | | |
| ជាភាសាអង់គ្លេស | | |
| ២. អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | | |
| ៣. កម្មវត្ថុអាជីវកម្ម | | |
| កម្មវត្ថុអាជីវកម្មចម្បង | | |
| កម្មវត្ថុអាជីវកម្មបន្ទាប់ ( ប្រសិនបើមាន ) | | |
| | | |
| | | |
| ៤. មធ្យោបាយអេឡិចត្រូនិកសម្រាប់ធ្វើអាជីវកម្ម | | |
| ៤.១. មធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងជាមួយអតិថិជន | | |
| គេហទំព័រ ( Website ) | | |
| បណ្ដាញទំនាក់ទំនងសង្គម៖ | ☐ Facebook ☐ Instagram ☐ Youtube ☐ Line, Other ................................ | ឈ្មោះគណនី ................................ |
| កម្មវិធីអេឡិចត្រូនិក ( Electronic Application ) | | |
| ៤.២.មធ្យោបាយទូទាត់ប្រាក់៖ | ☐ ភ្នាក់ងារផ្ទេរប្រាក់ ☐ ធនាគារ ☐ទូទាត់ប្រាក់តាមរយៈភ្នាក់ងារប្រគល់ទំនិញ ☐ ផ្សេងៗ៖ ................................ | |
| ឈ្មោះគ្រឹះស្ថានផ្ដល់សេវាទូទាត់ | | |
| ឈ្មោះគណនីសម្រាប់ទូទាត់ | | |
| លេខគណនីសម្រាប់ទូទាត់ | | |

## ៤.៣.មធ្យោបាយបញ្ជូនទំនិញជូនអតិថិជន

| តាមរយៈ | ☐ បុគ្គលិកផ្ទាល់ខ្លួន<br>☐ ភ្នាក់ងារបញ្ជូនទំនិញ<br>☐ តាមប្រៃសណីយ៍<br>☐ ផ្សេងៗ៖........................................................................................................ |
|---|---|

## ៥. ទម្រង់កិច្ចការពារអ្នកប្រើប្រាស់

| បរិយាយអំពីលក្ខខណ្ឌ និងខចែងអំពី៖<br>១. ទំនិញជាក់ស្តែងនិងប្រភពដើមផលិត<br>២.ការដកឬលុបចោលការបញ្ជាទំនិញដោយអ្នកទិញ<br>៣.ការបញ្ឈប់ដោយមានការព្រមព្រៀងរវាងអ្នកទិញនិងអ្នកលក់<br>៤.ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់វិញ (Refund)<br>៥.លក្ខខណ្ឌផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន | (អ្នកស្នើសុំអាចភ្ជាប់ឯកសារបន្ថែមត្រង់ចំនុចនេះ) |
|---|---|

## ៦. ព័ត៌មានអភិបាលដែលជាអ្នកស្នើសុំ

| ឈ្មោះ | |
|---|---|
| លេខទូរស័ព្ទ | |
| អ៊ីមែល (E-mail) | |

☐ ខ្ញុំសូមសន្យាថារាល់ព័ត៌មាន ដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវ និងមិនក្លែងបន្លំ។

កាលបរិច្ឆេទ | D | D | M | M | Y | Y | Y | Y |

ហត្ថលេខាអភិបាលក្រុមហ៊ុន និងត្រា

# ឧបសម្ព័ន្ធ២

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៧

# យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្តីពី

## ពាណិជ្ជកម្មតាមប្រព័ន្ធ
## អេឡិចត្រូនិក

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះមានគោលបំណង៖

១. គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអន្តរជាតិ។

២. បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណី តាមប្រព័ន្ធអេឡិចត្រូនិក។

៣. ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក។

**មាត្រា២ .- គោលដៅ**

ច្បាប់នេះមានគោលដៅដូចខាងក្រោម៖

១. កំណត់អំពីយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក។

២. ជំរុញការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តនិងធុរកិច្ច ដើម្បីអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។

៣. បង្ការនិងបង្ក្រាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យនិងប្រព័ន្ធព័ត៌មាន។

៤. លុបបំបាត់ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតជាលាយលក្ខណ៍អក្សរនិងហត្ថលេខា។

៥. សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នសាធារណៈ និងលើកកម្ពស់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈ តាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាន។

៦. បង្កើតវិធាន បទប្បញ្ញត្តិ និងស្តង់ដា ដែលទាក់ទងនឹងយថាភូតភាពនិងសុក្រឹតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៣ .- វិសាលភាព**

ច្បាប់នេះត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណីទាំងអស់ដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង៖

១. ការបង្កើតឬការអនុវត្តលិខិតប្រគល់សិទ្ធិ។

២. ការបង្កើតឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម។

៣. រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។

៤. ការផ្ទេរអចលនវត្ថុឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។

៥. ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤ .- និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រម ដែលមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា៥ .- ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក**

គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត ភាពអាចទទួលយកបានឬភាពដែលអាចយកទៅអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។

**មាត្រា៦ .- លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។

២. នៅពេលដែលលក្ខខណ្ឌក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តលក្ខខណ្ឌតម្រូវតាមច្បាប់ដែលទាមទារឱ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីអំពីព័ត៌មានណាមួយឬកិច្ចការណាមួយទៅឱ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញលក្ខខណ្ឌនេះដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់បាន។

**មាត្រា៧ .- លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

១. នៅពេលដែលមានបទប្បញ្ញត្តិណាមួយតម្រូវឱ្យមានហត្ថលេខារបស់បុគ្គលណាមួយ លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះ ត្រូវបានបង្កើតឡើងតាមរយៈមធ្យោបាយដែលៈ

ក. អាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញការឯកភាពរបស់បុគ្គលនោះលើព័ត៌មាន ឬកំណត់ត្រាដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

ខ. អាចជឿជាក់បាន ស្របតាមចរិតលក្ខណៈ គោលបំណង និងកាលៈទេសៈ ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើងឬត្រូវបានប្រាស្រ័យទាក់ទង។

២. ទោះបីជាបទប្បញ្ញត្តិណាមួយកំណត់អំពីលក្ខខណ្ឌតម្រូវឱ្យមានចុះហត្ថលេខា ឬគ្រាន់តែកំណត់អំពីផលវិបាកនៃការមិនចុះហត្ថលេខាក៏ដោយ ក៏បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវយកមកអនុវត្តផងដែរ។

**មាត្រា៨ ._ លក្ខខណ្ឌតម្រូវសម្រាប់រក្សាព័ត៌មានតាមទម្រង់ដើម**

លក្ខខណ្ឌតតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក អាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ៖

១. ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ។ និង

២. ព័ត៌មាននោះអាចចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

**មាត្រា៩ ._ ទម្រង់បែបបទដែលកំណត់**

នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនោះត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១. មានផ្ទុកព័ត៌មានដូចគ្នាឬដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់។

២. អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ។ និង

៣. អាចឱ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។

**មាត្រា១០ ._ លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញ ប្រសិនបើ ការរក្សាទុកនោះបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកទៅប្រើប្រាស់នាពេលអនាគត។

ខ. ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រឹតភាពនៃព័ត៌មាននោះ។ និង

គ. ព័ត៌មានទាំងនោះត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានផ្ញើឬទទួល។

២. កាតព្វកិច្ចក្នុងការរក្សាឯកសារ កំណត់ត្រា ឬព័ត៌មានស្របតាមកថាខណ្ឌ១ មិនរាប់បញ្ចូលព័ត៌មានណាមួយ សម្រាប់តែធ្វើការបញ្ជូនឬទទួលសារនោះឡើយ។

**មាត្រា១១ ._ លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង**

គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្តីពីភស្តុតាង អាចជំទាស់ការទទួលយកទំនាក់ទំនងអេឡិចត្រូនិកជាភស្តុតាង ដោយគ្រាន់តែឈរលើមូលដ្ឋានដែលថា៖

១. ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក។ ឬ

២. ភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**មាត្រា១២ .- ការបង្កើតកិច្ចសន្យានិងសុពលភាពកិច្ចសន្យា**

១. សំណើ ស្នើការ និងកិច្ចសន្យា អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន។

២. កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន នៅពេលដែលសំណើនិងស្នើការត្រូវគ្នា។

**មាត្រា១៣ .- អានុភាពរវាងគូភាគី**

អ្នកផ្ញើនិងអ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិក មិនត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬសេចក្តីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។

**មាត្រា១៤ .- ការអនុវត្តដោយឡែកតាមការព្រមព្រៀងរបស់គូភាគី**

១. តាមការព្រមព្រៀង គូភាគីដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬ ដំណើរការទំនាក់ទំនងអេឡិចត្រូនិក អាចអនុវត្តផ្សេងពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី២ នៃច្បាប់នេះ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

២. ទោះជាមានបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី២ គូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយអាចៈ

ក. មិនប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិក ទំនាក់ទំនងអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកក្នុងកិច្ចសន្យា ឬប្រតិបត្តិការណាមួយតាមការព្រមព្រៀងគ្នា។ ឬ

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមការព្រមព្រៀងគ្នា។

## ជំពូកទី៣
## ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា១៥ .- ពេលវេលានិងទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

១. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលៈ

ក. ព័ត៌មាននោះ បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ។ ឬ

ខ. ក្នុងករណីដែលព័ត៌មាននោះ ត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសព័ត៌មាន ត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេលណាមួយ។

២. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។

៣. ពេលវេលានៃការទទួលព័ត៌មានគឺពេលដែលព័ត៌មាននោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៤. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញនិងអាចទាញយកព័ត៌មាននោះ តាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៥. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

**មាត្រា១៦ .- សំណើបង្កើតកិច្ចសន្យា**

រាល់ការស្នើសុំចុះកិច្ចសន្យា តាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំចុះកិច្ចសន្យានោះ នឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្វីការពីភាគីម្ខាងទៀត។

**មាត្រា១៧ .- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា**

កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តឬក្នុងការបង្កើតកិច្ចសន្យា។

**មាត្រា១៨ .- កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស បុគ្គលឬភាគីដែលជំនួសមុខឱ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះមានសិទ្ធិកែតម្រូវ ឬដកចេញនូវព័ត៌មានដែលខុសនោះបាន ក្នុងករណី៖

១. បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានឆាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ និង

២. បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតឬតតិយជនណាមួយ។

បញ្ញត្តិដែលមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះវិស័យមូលបត្រឡើយ។

## ជំពូកទី៤

## កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

**មាត្រា១៩ .-** កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព

កំណត់ត្រាអេឡិចត្រូនិកមួយត្រូវបានចាត់ទុកថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែបានអនុវត្តស្របតាមនីតិវិធីសុវត្ថិភាពត្រឹមត្រូវ ដែលធានាបានថាកំណត់ត្រាអេឡិចត្រូនិកនោះ មិនត្រូវបានកែប្រែ គិតចាប់ពីពេលវេលាកំណត់ជាក់លាក់ណាមួយរហូតដល់ពេលធ្វើការពិនិត្យផ្ទៀងផ្ទាត់។

**មាត្រា២០ .-** ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

១. ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែគោរពទៅតាមលក្ខខណ្ឌខាងក្រោម៖

ក. ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់។

ខ. កំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី។

គ. ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី។

ឃ. បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខា។ និង

ង. បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ។

២. បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ ក្នុងការ៖

ក. កំណត់លក្ខខណ្ឌបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក។ ឬ

ខ. លើកភស្តុតាងអំពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិក។

**មាត្រា២១ .-** ការសន្មតទាក់ទងនឹងកំណត់ត្រានិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

១. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការដែលពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតថាជាកំណត់ត្រាអេឡិចត្រូនិកដែលមិនត្រូវបានកែប្រែចាប់តាំងពីពេលជាក់លាក់ណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការពាក់ព័ន្ធនឹងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតដូចខាងក្រោម៖

ក. ហត្ថលេខាអេឡិចត្រូនិកនោះ គឺជាហត្ថលេខារបស់បុគ្គលពាក់ព័ន្ធ។ និង

ខ. ហត្ថលេខាអេឡិចត្រូនិកនោះ ត្រូវបានចុះហត្ថលេខាដោយបុគ្គលមានឆន្ទៈក្នុងការចុះហត្ថលេខា ឬបានឯកភាពលើកំណត់ត្រាអេឡិចត្រូនិកនោះ។

៣. ក្នុងករណីដែលគ្មានកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព ឬហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាព គ្មានបញ្ញត្តិណាមួយនៅក្នុងជំពូកទី៤ អាចសន្មតបានជាមុនអំពីយថាភូតភាព ឬសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកនោះឡើយ។

**មាត្រា២២ .- ការលួចប្រើប្រាស់អត្តសញ្ញាណ**

បុគ្គលទាំងឡាយមិនត្រូវប្រើប្រាស់អត្តសញ្ញាណ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគសម្គាល់របស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ក្នុងប្រតិបត្តិការពាណិជ្ជកម្ម ឬមិនមែនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា២៣ .- ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងនីតិវិធីសុវត្ថិភាព**

១. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនីតិវិធីសុវត្ថិភាព សម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិក។

២. ការគ្រប់គ្រងនីតិវិធីសុវត្ថិភាពសម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។

## ជំពូកទី៥
## អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា២៤ .- ការទទួលខុសត្រូវរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពាក់ព័ន្ធនឹងព័ត៌មានដែលមានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងការផ្តល់សេវារបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះឡើយ ក្នុងករណីដែលខ្លួនមិនមែនជាអ្នកធ្វើកំណត់ត្រានោះ និងក្នុងករណីដែល៖

ក. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងថាព័ត៌មានដែលបានផ្ញើនោះបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។

ខ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងអំពីអង្គហេតុឬកាលៈទេសៈដែលអាចឱ្យស្មានទុកថាព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។ ឬ

គ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងនាពេលក្រោយថាព័ត៌មាន ឬអង្គហេតុ ឬកាលៈទេសៈដែលអាចឱ្យស្មានទុកថា ព័ត៌មាននោះ

អាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍ដូចមានចែងក្នុងមាត្រា២៥ខាងក្រោម។

២. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យតាមដានត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួននោះឡើយ ទោះបីជាដំណើរការនៃកំណត់ត្រាអេឡិចត្រូនិកនោះអាចបង្កើតជាបទល្មើស ឬនាំឱ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីក៏ដោយ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៣. បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តដើម្បីឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចផុតពី៖

ក. កាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា។

ខ. កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬសេចក្តីបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ ឬ

គ. កាតព្វកិច្ចតាមកិច្ចសន្យា។

**មាត្រា២៥ .- ការទទួលខុសត្រូវផ្នែកព័ត៌មានឬហេតុការណ៍**

១. ក្នុងករណីដែលអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងថាព័ត៌មានក្នុងកំណត់ត្រាអាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ។

ខ. រក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាអំពីអង្គហេតុនិងអត្តសញ្ញាណនៃជនសង្ស័យ។

២. ក្នុងករណីដែលអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដឹងអំពីហេតុការណ៍ណាមួយ ឬស្ថានភាពណាមួយដែលអាចបណ្តាលឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវរក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា។

៣. នៅពេលបានដឹងឬទទួលដំណឹងពាក់ព័ន្ធនឹងព័ត៌មានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ ក្រសួងប្រៃសណីយ៍និង

ទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបញ្ជាឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកៈ

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ខ. ផ្អាកឬឈប់ផ្តល់សេវាដល់បុគ្គលនោះ។ ឬ

គ. ផ្អាកឬឈប់ផ្តល់សេវាពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិក។

៤. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិកមិនត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តាមកិច្ចសន្យាឬក្រៅកិច្ចសន្យា ឬកំណត់ដោយច្បាប់ ចំពោះការអនុវត្តដោយសុទ្ធចិត្តតាមបញ្ជារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥. បុគ្គលដែលជូនដំណឹងអំពីសកម្មភាពខុសច្បាប់ទៅដល់អន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយដឹងថាការជូនដំណឹងនោះខុសពីការពិតឬមានលក្ខណៈបោកបញ្ឆោត ត្រូវទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពីអំពើនោះ។

**មាត្រា២៦ .- ការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណ**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណពីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រសួងពាណិជ្ជកម្មផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណរួមមានៈ

ក. លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់រូបវន្តបុគ្គល។

ខ. អាជ្ញាបណ្ណឱ្យប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់នីតិបុគ្គល។

៣. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ផ្តល់វិញ្ញាបនបត្រសេវាអនឡាញ។

៤. ការលើកលែង ការកំណត់ប្រភេទអាជ្ញាបណ្ណ បែបបទ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតឬអាជ្ញាបណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៧ .- ក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិសម្រាប់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានលើកឡើងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវកំណត់និងរៀបរៀងឡើងដោយក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ដោយសហការជាមួយក្រសួង ស្ថាប័ននិងភាគីពាក់ព័ន្ធ។

**មាត្រា២៨ .- កាតព្វកិច្ចពន្ធ ការលើកទឹកចិត្ត និងការអនុគ្រោះ**

អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

# ជំពូកទី៦
# កិច្ចការពារអ្នកប្រើប្រាស់

**មាត្រា២៩ .. ព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញឬសេវាទៅឱ្យអ្នកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មានយ៉ាងតិចដូចខាងក្រោម៖

ក. ឈ្មោះឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងឬលេខទូរសព្ទ។

ខ. ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ. ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដកឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់មកវិញ។ និង

ឃ. ទំនិញនិងសេវាជាក់ស្តែងដែលដាក់លក់។

២. ព័ត៌មានដែលមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ចាំបាច់ត្រូវមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្មនិងរក្សាទុកជាព័ត៌មាន។

៣. បញ្ញត្តិនៃមាត្រានេះមិនយកមកអនុវត្តចំពោះវិស័យមូលបត្រនិងធានារ៉ាប់រងឡើយ។

**មាត្រា៣០ .. ទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តល់ជម្រើសច្បាស់លាស់និងងាយស្រួលសម្រាប់ឱ្យអ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលយកទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។

**មាត្រា៣១ .. ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំនិងកូដព្យាបាទ**

១. បុគ្គលទាំងឡាយមិនត្រូវបង្កើតប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងក្លែងបន្លំឬបង្កការភាន់ច្រឡំ ដើម្បីទាញយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឱ្យមានការប្រើប្រាស់ឬធ្វើប្រតិបត្តិការ ហើយនាំឱ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះឬតតិយជនឡើយ។

២. បុគ្គលទាំងឡាយមិនត្រូវបង្កើត ផ្តល់ បង្កលទ្ធភាព ចែកចាយ ឬបញ្ជូននូវលេខកូដចម្លងមេរោគ ក្នុងគោលបំណងទុច្ចរិត តាមមធ្យោបាយអេឡិចត្រូនិក ទៅក្នុងឧបករណ៍ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលផ្សេងទៀតឡើយ។

**មាត្រា៣២ .- ការការពារទិន្នន័យ**

១. បុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវប្រើគ្រប់មធ្យោបាយដើម្បីធានាថា ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផល ដើម្បីជៀសវាង ការបាត់បង់ ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំងនោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬពីភាគីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

២. បុគ្គលទាំងឡាយមិនត្រូវជ្រៀតជ្រែកក្នុងប្រព័ន្ធអេឡិចត្រូនិក ចូលប្រើប្រាស់ ទាញយកថតចម្លង ស្រង់យក ធ្វើឱ្យបែកធ្លាយ លុបបំបាត់ ឬកែប្រែទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតឡើយ។

**មាត្រា៣៣ .- ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

## ជំពូកទី៧
## សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៣៤ .- ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពនិងប្រតិបត្តិការ ដូចខាងក្រោម៖

ក. ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ។

ខ. ការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាត។

គ. ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់។ ឬ

ឃ. សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២. នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់៖

ក. របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី បង្កើតរក្សាទុក ឬបោះផ្សាយ។

ខ. ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

គ. របៀបនិងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។

ឃ. ដំណើរការគ្រប់គ្រងនិងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាពនិងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ង. លក្ខខណ្ឌកំណត់ផ្សេងទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

## ជំពូកទី៨

## ភស្តុតាងអេឡិចត្រូនិក

**មាត្រា៣៥ .-** ការទទួលយកជាទូទៅនូវភស្តុតាងអេឡិចត្រូនិក

គ្មានបទប្បញ្ញត្តិនៃវិធានស្តីពីភស្តុតាងណាមួយដែលយកមកអនុវត្ត ដើម្បីបដិសេធក្នុងការទទួលយកជាទូទៅនូវកំណត់ត្រាអេឡិចត្រូនិកធ្វើជាភស្តុតាង ដោយហេតុផលគ្រាន់តែសម្អាងលើមូលដ្ឋានថា វាជាកំណត់ត្រាអេឡិចត្រូនិកនោះឡើយ ទោះបីជាភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើមក៏ដោយ។

**មាត្រា៣៦ .-** សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក

១. នៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ សុពលភាពនៃភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបញ្ជាក់តាមរយៈសុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ដែលបានកត់ត្រាឬរក្សាទុកនូវទិន្នន័យណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ប្រព័ន្ធអេឡិចត្រូនិកដែលបានប្រើប្រាស់សម្រាប់កត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ត្រូវបានសន្មតថាមានសុក្រឹតភាព ក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ តាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក. ក្នុងករណីមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកត់ត្រាឬរក្សាទុកឬនៅពេលដែលយកទៅធ្វើជាភស្តុតាង ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង ប៉ុន្តែមិនធ្វើឱ្យប៉ះពាល់ដល់សុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ហើយគ្មានមូលហេតុ សមស្របណាផ្សេងយកមកជំទាស់សុក្រឹតភាពនៃកំណត់ត្រានោះ។

ខ. ក្នុងករណីមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុក ដោយភាគីដែលមានផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀតដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។ ឬ

គ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកជាប្រក្រតីក្នុងគោលបំណងអាជីវកម្មធម្មតាដោយបុគ្គលដែលមិនមែនជាភាគីក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

**មាត្រា៣៧ .- សុក្រឹតភាពនៃព័ត៌មាន**

១. លើកលែងតែមានភស្តុតាងផ្ទុយពីនេះ កំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រាឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិកត្រូវបានសន្មតថាមានសុក្រឹតភាពនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

ក. នៅពេញលេញនិងគ្មានការកែប្រែក្រៅពីការធ្វើបដិលេខបន្ថែមណាមួយ ឬការផ្លាស់ប្តូរដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃទំនាក់ទំនង ការរក្សាទុកឬការបង្ហាញ។

ខ. ត្រូវបានបញ្ជាក់ឬចុះហត្ថលេខានៅក្នុងទម្រង់អេឡិចត្រូនិក តាមរយៈមធ្យោបាយដែលផ្តល់ឱ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

គ. មានសុក្រឹតភាពនិងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

ឃ. ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុកឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិនអនុញ្ញាតឱ្យមានការកែប្រែទៅលើកំណត់ត្រាអេឡិចត្រូនិក។

ង. ត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ពីសុក្រឹតភាព ដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។

ច. នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតបានដំណើរការជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតីឬឈប់ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រាមិនរងការប៉ះពាល់ដោយសារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀតដែលចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ។ ឬ

ឆ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកដោយភាគីដែលចូលរួមនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់នោះ ហើយដែលភាគីមានទំនាស់ផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

២. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកតាមធម្មតានិងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយបុគ្គលដែលមិនមែនជាភាគីនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

៣. នៅពេលដែលរបាយការណ៍ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ត្រាអេឡិចត្រូនិក ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាមទេនោះ របាយការណ៍ទាំងនោះអាចទទួលយកបាន ប្រសិនបើលក្ខខណ្ឌដូចដែលមានចែងនៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ ទាក់ទងនឹងកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានបំពេញ។

**មាត្រា៣៨ .- ឯកសារដែលបានបោះពុម្ពចេញ**

ឯកសារដែលបានបោះពុម្ពចេញត្រឹមត្រូវស្របនឹងខ្លឹមសារដើមចេញពីកំណត់ត្រាអេឡិចត្រូនិក អាចយកមកប្រើប្រាស់ជាភស្តុតាងបានក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

**មាត្រា៣៩ .- បន្ទុកក្នុងការបង្ហាញអំពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

១. បុគ្គលដែលស្នើសុំបង្ហាញកំណត់ត្រាអេឡិចត្រូនិកក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ណាមួយ បុគ្គលនោះត្រូវទទួលបន្ទុកបង្ហាញពីយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកដោយមានភស្តុតាងគាំទ្រដល់កំណត់ត្រាដែលបានបង្ហាញ។

២. ក្នុងករណីមានបទប្បញ្ញត្តិណាមួយការពារបុគ្គលងាយរងគ្រោះដែលរាប់បញ្ចូលទាំងអ្នកប្រើប្រាស់និងកុមារ ហើយដែលមានកំណត់អំពីបន្ទុកនៃការបង្ហាញភស្តុតាងដែលផ្តល់ប្រយោជន៍ដល់បុគ្គលទាំងនោះច្រើនជាងច្បាប់នេះ បទប្បញ្ញត្តិនោះត្រូវមានអាទិភាពជាងមាត្រានេះ។

**មាត្រា៤០ .- បទដ្ឋាននៃការកត់ត្រាឬការរក្សាទុកកំណត់ត្រាអេឡិចត្រូនិក**

ដើម្បីកំណត់បានថាកំណត់ត្រាអេឡិចត្រូនិកត្រូវទទួលយកឬមិនទទួលយកក្នុងបទប្បញ្ញត្តិផ្សេងទៀត ការបង្ហាញភស្តុតាងអាចត្រូវធ្វើឡើងដោយផ្អែកលើបទដ្ឋាន នីតិវិធី ការប្រើឬការអនុវត្តនៃការកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ដោយត្រូវពិនិត្យពិចារណាអំពីប្រភេទអាជីវកម្ម ចរិតលក្ខណៈ និងគោលបំណងនៃកំណត់ត្រាអេឡិចត្រូនិកនោះ។

**មាត្រា៤១ .- ការចេញលិខិតបញ្ជាក់យថាភូតភាព**

១. ក្នុងករណីដែលបុគ្គលណាមួយមានបំណងចង់បង្ហាញយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកមួយដើម្បីធ្វើជាភស្តុតាង បុគ្គលនោះអាចស្នើសុំភស្តុតាងនោះពីអ្នកជំនាញពាក់ព័ន្ធនឹងយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកនោះក្រោមទម្រង់ជាលិខិតបញ្ជាក់។

២. លិខិតបញ្ជាក់យថាភូតភាពដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវចេញដោយ៖

- ក. ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬបុគ្គលដែលទទួលខុសត្រូវពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការគ្រប់គ្រងអ្នកបង្កើតនីតិវិធីសុវត្ថិភាពជាក់លាក់ណាមួយ ឬអ្នកបង្កើតនីតិវិធីសុវត្ថិភាពដែលទទួលស្គាល់ដោយតុលាការ។ ឬ
- ខ. អ្នកជំនាញដែលតែងតាំងឬដែលទទួលស្គាល់ដោយតុលាការ។

៣. បុគ្គលដែលមានសមត្ថកិច្ចក្នុងការចេញលិខិតបញ្ជាក់យថាភូតភាព ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ខាងលើ មិនត្រូវក្លែងឬចេញលិខិតបញ្ជាក់យថាភូតភាពនៃកំណត់ត្រាឬភស្តុតាងអេឡិចត្រូនិកដែលមានលក្ខណៈក្លែងបន្លំឬមិនមែនជាការពិតនោះឡើយ។

**មាត្រា៤២ .- នីតិវិធីផ្សេងទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក**

បន្ថែមលើមធ្យោបាយបង្ហាញភស្តុតាងដូចមានចែងក្នុងច្បាប់នេះ ភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបង្កើតឡើង តាមបច្ចេកទេសនិងនីតិវិធីផ្សេងទៀតដូចជា ការបញ្ជាក់ដោយសារការីឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាក្នុងមធ្យោបាយអេឡិចត្រូនិកដែលមិនអនុញ្ញាតឱ្យមានការកែប្រែបាន និងលទ្ធផលកោសល្យវិច័យលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការតុលាការ។

**មាត្រា៤៣ .- ការបំពានលើកូដនីយកម្ម**

បុគ្គលទាំងឡាយមិនត្រូវដាក់កូដក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬការដាក់កូដលើទិន្នន័យ ឬភស្តុតាងក្នុងប្រព័ន្ធអេឡិចត្រូនិកដែលទាក់ទិននឹងបទល្មើសឡើយ។

**មាត្រា៤៤ .- ការទទួលយកកំណត់ត្រាអេឡិចត្រូនិកពីបរទេស**

ភស្តុតាងអេឡិចត្រូនិកដែលបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ចនៃបណ្តារដ្ឋបរទេសត្រូវបានទទួលយកជាភស្តុតាង ប្រសិនបើប្រព័ន្ធអេឡិចត្រូនិកដែលកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិកនោះមានសុក្រឹតភាពស្របតាមបទដ្ឋាន ដូចមានចែងក្នុងជំពូកទី៨នៃច្បាប់នេះ។

**មាត្រា៤៥ .- ការទទួលយកព័ត៌មានអេឡិចត្រូនិកមកពីបរទេស**

ដើម្បីកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកឬមិនអាចទទួលយកបាន ឬអាចទទួលយកបានត្រឹមកម្រិតណាមួយនោះ មិនត្រូវគិតពីទីតាំងដែលព័ត៌មាននោះត្រូវបានបង្កើតឡើងឬត្រូវបានប្រើប្រាស់ ឬទីតាំងអាជីវកម្មដែលបានបង្កើតឡើងនៅបរទេសនោះឡើយ ឱ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូលនិងទាញយកមកប្រើបាននៅក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩

## ការទូទាត់និង/ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៤៦ .- ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។

២. ធនាគារជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៤៧ .. ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់**

១. បុគ្គលផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេលប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្តូរ។

២. មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្តល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

ក. ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

ខ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

គ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨ខាងក្រោម។

ឃ. ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន។ ឬ

ង. ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

៣. បុគ្គលផ្តល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ។

៤. ក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនឱ្យលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ នូវតម្លៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ការប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនេះដោយ មិនទាន់គិតបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជន។

៥. បុគ្គលទាំងឡាយមិនត្រូវចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឱ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀតឡើយ។

**មាត្រា៤៨ .. ការទទួលខុសត្រូវរបស់អតិថិជន**

១. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត កំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

២. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្ដល់សេវាទូទាត់ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្ដល់សេវាទូទាត់អំពីករណីបាត់បង់ឬអំពើចោរកម្មលើឧបករណ៍/មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរឬតាមមធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលយកដោយបុគ្គលផ្ដល់សេវាទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបានឬមិនឱ្យលើសរយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្មឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣. ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាការបាត់បង់ឬការខូចខាតក្នុងករណីខាងលើជាកំហុសរបស់អតិថិជន បុគ្គលផ្ដល់សេវាទូទាត់មានសិទ្ធិទាមទារឱ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ។

៤. ក្នុងករណីមិនមានភស្តុតាងបញ្ជាក់អំពីកំហុសរបស់អតិថិជនទេ បុគ្គលផ្ដល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ ដោយឥតលក្ខខណ្ឌ។

## ជំពូកទី១០
## សមត្ថកិច្ច ការប្ដឹងតវ៉ា និងនីតិវិធីនៃការផាកពិន័យ

### មាត្រា៤៩ .. សមត្ថកិច្ច

ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការផាកពិន័យ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

ក្នុងករណីដែលបុគ្គលមិនអនុវត្តតាមវិធានការខាងលើ ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ អាចធ្វើបណ្ដឹងទៅតុលាការមានសមត្ថកិច្ច។

### មាត្រា៥០ .. នីតិវិធីនៃការប្ដឹងតវ៉ា

១. បុគ្គលដែលមិនសុខចិត្តនឹងការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការផាកពិន័យរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្ដឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ត្រូវសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

៣. បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងនៃសេចក្ដីសម្រេចនោះ។

**មាត្រា៥១ .- នីតិវិធីនៃការផាកពិន័យ**

នីតិវិធីនៃការផាកពិន័យ ការបង់ប្រាក់ផាកពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និង ការចាត់ចែងប្រាក់ចំណូលដែលបានពីការផាកពិន័យ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី១១
## ទោសប្បញ្ញត្តិ

**មាត្រា៥២ .- ទណ្ឌកម្ម**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាព ឬ ប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ការផាកពិន័យ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

**មាត្រា៥៣ .- អំពើល្មើសលើការលួចប្រើប្រាស់អត្តសញ្ញាណ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែល ប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា២២។

**មាត្រា៥៤ .- អំពើល្មើសលើការមិនរាយការណ៍អំពីព័ត៌មានឬហេតុការណ៍**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះអំពើរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៥។

**មាត្រា៥៥ .- អំពើផ្តល់ពត៌មានមិនពិត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើដូចមានចែង ក្នុងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា២៥។

**មាត្រា៥៦ .- ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត**

ត្រូវបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្មនិងត្រូវទទួលការផាកពិន័យជាប្រាក់មិន លើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិ នៃកថាខណ្ឌទី១នៃមាត្រា២៦។

ក្នុងករណីធ្លាប់ទទួលរងនូវវិធានការដូចមានចែងក្នុងកថាខណ្ឌទី១ជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលពី៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

**មាត្រា៥៧ .- អំពើល្មើសលើការមិនអនុវត្តតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៩។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាបុគ្គលផ្តល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៥៨ .- អំពើល្មើសលើការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣០។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬបិទមិនឱ្យដំណើរការនូវប្រព័ន្ធផ្សព្វផ្សាយឬមធ្យោបាយអេឡិចត្រូនិករបស់អ្នកផ្ញើ។

**មាត្រា៥៩ .- អំពើល្មើសលើការក្លែងប្រព័ន្ធអេឡិចត្រូនិកនិងកូដព្យាបាទ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣១។

**មាត្រា៦០ .- អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៣២។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៣២។

**មាត្រា៦១ .- អំពើល្មើសលើការបំពានលើការចេញលិខិតបញ្ជាក់យថាភូតភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៣នៃមាត្រា៤១។

**មាត្រា៦២ .- អំពើល្មើសលើការបំពានលើគូដនីយកម្ម**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៤៣។

**មាត្រា៦៣ .- អំពើល្មើសលើការធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៤៦។

**មាត្រា៦៤ .- អំពើល្មើសលើការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា៤៧។

**មាត្រា៦៥ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

១. នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៥៣ដល់មាត្រា៥៥ កថាខណ្ឌទី២នៃមាត្រា៥៦និងមាត្រា៥៩ដល់មាត្រា៦៤នៃច្បាប់នេះ។

២. នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះៈ

- ក. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។
- ខ. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។
- គ. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។
- ឃ. ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០ (ការបិទផ្សាយសេចក្ដីសម្រេច)នៃក្រមព្រហ្មទណ្ឌ។
- ង. ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ សារព័ត៌មានអេឡិចត្រូនិក ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៦៦ ..** ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦៧ ..** ការអនុវត្តច្បាប់នេះ

ក្រោយពីចូលជាធរមាន ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល៦(ប្រាំមួយ)ខែ ទើបអនុវត្ត។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

នស.រកម.១១១៩.០១៦

នសីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

# ឧបសម្ព័ន្ធ
# និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

**១. ការចូលប្រើប្រាស់/អាក់សេស(Access)** សំដៅដល់ការចូលទៅប្រើកម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធឬបណ្ដាញអេឡិចត្រូនិក ដើម្បីទាក់ទង បញ្ជូន រក្សាទុក ឬទាញយកនូវទិន្នន័យ ព័ត៌មានឬឯកសារផ្សេងៗទៀតក្នុងប្រព័ន្ធអេឡិចត្រូនិកតាមគ្រប់មធ្យោបាយ។

**២. អ្នកទទួល(Addressee)** សំដៅដល់បុគ្គលដែលទទួលទំនាក់ទំនងអេឡិចត្រូនិក ស្របតាមឆន្ទៈរបស់អ្នកផ្ញើ លើកលែងតែអន្តរការីក្នុងការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក។

**៣. ប្រព័ន្ធស្វ័យប្រវត្តិ(Automated System)** សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធ ឬបណ្ដាញអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹងឬឆ្លើយតបដោយស្វ័យប្រវត្តិដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

**៤. បណ្ណ/កាតទូទាត់(Card)** សំដៅដល់បណ្ណ/កាតធនាគារ បណ្ណឥណទាន/ឥណពន្ធ ស្មាតកាត (Smart Card) ឬបណ្ណ/កាតទូទាត់ ទោះបីក្នុងទម្រង់អេឡិចត្រូនិកដែលផ្ទុកតម្លៃ ហើយមានមុខងារសម្រាប់ទូទាត់។

**៥. កម្មវិធីចម្លងមេរោគ(Contaminant)** សំដៅដល់កម្មវិធីអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដើម្បី៖

(ក) កែប្រែ បំផ្លាញ កត់ត្រា បញ្ជូនទិន្នន័យឬកម្មវិធីនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ

(ខ) ជ្រៀតជ្រែកតាមគ្រប់មធ្យោបាយនូវដំណើរការប្រក្រតីរបស់ប្រព័ន្ធឬបណ្ដាញអេឡិចត្រូនិក។

**៦. ម្ចាស់បណ្ណ/កាតទូទាត់(Cardholder)** សំដៅដល់បុគ្គលដែលមានឈ្មោះចារឹកនៅលើបណ្ណ/កាត និងជាបុគ្គលដែលទទួលប្រយោជន៍ពីបណ្ណ/កាតទូទាត់នោះ។

**៧. ទំនាក់ទំនង(Communication)** សំដៅដល់អំណះអំណាង សេចក្ដីថ្លែងការណ៍ ការទាមទារ សេចក្ដីជូនដំណឹង សំណូមពរ សំណើ ឬស្នើការ ដែលគូភាគីត្រូវធ្វើឬសម្រេចចិត្តធ្វើពាក់ព័ន្ធនឹងការបង្កើតឬការអនុវត្តកិច្ចសន្យា។

**៨. បណ្ណ/កាតទូទាត់ក្លែងក្លាយ(Counterfeit card)** សំដៅដល់បណ្ណ/កាតទូទាត់ទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឬការពិពណ៌នាដែលត្រូវបានប្រឌិតឡើង កែប្រែក្លែងបន្លំ ឬបណ្ណ/កាតទូទាត់ដែលមានសមាសធាតុណាមួយនៃបណ្ណ/កាតទូទាត់នោះមានលក្ខណៈខុសច្បាប់។

**៩. ទិន្នន័យ(Data)** សំដៅដល់បណ្ដុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យឬប្រព័ន្ធអេឡិចត្រូនិក។

១០. **អេឡិចត្រូនិក(Electronic)** សំដៅដល់អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានចរន្តអគ្គិសនី ឌីជីថល ម៉ាញេទិច អុបទិក ជីវមាត្រ អេឡិចត្រូតីមី វ៉ាយអឺឡេស (wireless) អេឡិចត្រូម៉ាញេទិក ឬបច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។

១១. **អាសយដ្ឋានអេឡិចត្រូនិក(Electronic Address)** សំដៅដល់លេខឬអាសយដ្ឋានប្រើប្រាស់សម្រាប់ផ្ញើឬទទួលការជូនដំណឹង ឯកសារ ព័ត៌មាន ឬទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិក។

១២. **យថាភូតភាព(Authenticity)** សំដៅដល់ភាពត្រឹមត្រូវនិងអាចជឿទុកចិត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក។

១៣. **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic Commerce)** សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

១៤. **ឧបករណ៍ទូទាត់អេឡិចត្រូនិក(Electronic Payment Instrument)** សំដៅដល់បណ្ណ/កាតទូទាត់ ឬឧបករណ៍ទូទាត់ទាំងឡាយណាដែលមានទម្រង់ជាអេឡិចត្រូនិក ហើយមានមុខងារសម្រាប់ទូទាត់សងប្រាក់។

១៥. **ទំនាក់ទំនងអេឡិចត្រូនិក(Electronic Communication)** សំដៅដល់ព័ត៌មានដែលត្រូវបានទាក់ទង ដំណើរការ កត់ត្រាទុក បង្ហាញឡើង បង្កើតឡើង រក្សាទុក ទទួលបាន ឬបញ្ជូនតាមមធ្យោបាយអេឡិចត្រូនិក។

១៦. **ឧបករណ៍អេឡិចត្រូនិក(Electronic device)** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលបង្កើតឡើងដើម្បីគ្រប់គ្រង បញ្ជា និងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

១៧. **ភស្តុតាងអេឡិចត្រូនិក(Electronic evidence)** សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារនានាដែលបានបង្កើតឡើង រក្សាទុក ផ្ញើចេញ ឬទទួលក្នុងទម្រង់ឬទំនាក់ទំនងអេឡិចត្រូនិកសម្រាប់ជាសំអាងទាក់ទងនឹងអង្គហេតុណាមួយក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយព័ត៌មាន ទិន្នន័យ ឬឯកសារនោះមានយថាភូតភាពស្របតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

១៨. **ទម្រង់អេឡិចត្រូនិក(Electronic form)** សំដៅដល់ទម្រង់នៃព័ត៌មាន ទិន្នន័យ ឬឯកសារដែលបង្កើត បញ្ជូន ទទួលបាន ឬរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

១៩. **ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក(Electronic fund transfer)** សំដៅដល់ប្រតិបត្តិការទាំងឡាយណាដែលធ្វើឡើងតាមរយៈបញ្ជារផ្ទេរប្រាក់អេឡិចត្រូនិក ឬតាមឧបករណ៍អេឡិចត្រូនិកចល័ត ឬតាមឧបករណ៍អេឡិចត្រូនិកដែលមានមុខងារស្រដៀងគ្នា ដើម្បីបញ្ជាឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើការចុះឥណពន្ធឬឥណទានក្នុងគណនី។

២០. **កំណត់ត្រាអេឡិចត្រូនិក(Electronic record)** សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើតឡើង ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

២១. **បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic-Commerce service provider)** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

២២. **ហត្ថលេខាអេឡិចត្រូនិក(Electronic Signature)** សំដៅដល់រាល់ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលរួមមាន ហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និងហត្ថលេខាដទៃទៀត។

២៣. **ប្រព័ន្ធអេឡិចត្រូនិក(Electronic system)** សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នាឬទាក់ទងគ្នា តាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

២៤. **ប្រព័ន្ធព័ត៌មាន(Information system)** សំដៅដល់ប្រព័ន្ធសម្រាប់បង្កើត ផ្ញើ ទទួល រក្សាទុក ឬដំណើរការកំណត់ត្រាអេឡិចត្រូនិក។

២៥. **អន្តរការី(Intermediary)** សំដៅដល់បុគ្គលដែលផ្តល់សេវា ផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិក រួមបញ្ចូលនូវបុគ្គលដូចខាងក្រោម៖

១. បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក

២. បុគ្គលផ្តល់សេវាទូរគមនាគមន៍

៣. បុគ្គលផ្តល់សេវាបណ្តាញនានា

៤. បុគ្គលផ្តល់សេវាអ៊ិនធឺណិត

៥. បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក

៦. បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ

៧. បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ

៨. បុគ្គលផ្តល់សេវាទីផ្សារអនឡាញនិងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធឺណិត។

២៦. **បុគ្គលចេញបណ្ណ/កាតទូទាត់(Issuer)** សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬបុគ្គលណាមួយដែលបានចេញបណ្ណ/កាតទូទាត់ ដែលបានទទួលការអនុញ្ញាត។

២៧. កូដព្យាបាទ(Malicious code) សំដៅដល់កម្មវិធីឬតួនាទីលាក់មុខនៃកម្មវិធីដែលចម្លងមេរោគដល់ទិន្នន័យ ព័ត៌មាន ឬឯកសារ ដោយមានឬគ្មានបន្សល់ទុកស្លាកស្នាមសម្គាល់នៃមេរោគនោះក្នុងឯកសារអេឡិចត្រូនិកដែលបានឆ្លងមេរោគ ហើយមេរោគនោះអាចចម្លងបន្តក្នុងប្រព័ន្ធដោយឯកឯងឬដោយមានអន្តរាគមន៍ពីមនុស្ស។

២៨. អ្នកផ្ញើ(Originator) សំដៅដល់ភាគីឬអ្នកតំណាងដែលបានផ្តើមប្រតិបត្តិការបង្កើត រក្សាទុក ឬបញ្ជូនទិន្នន័យតាមមធ្យោបាយអេឡិចត្រូនិក ដោយមិនរាប់បញ្ចូលអន្តរការី។

២៩. បុគ្គលផ្តល់សេវាទូទាត់(Payment Service Provider) សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាតឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិកឬមធ្យោបាយទូទាត់ ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់ ជាអេឡិចត្រូនិកដល់សាធារណជន។

៣០. ទីតាំងអាជីវកម្ម(Place of business) សំដៅដល់៖

ក. ទីតាំងដែលអ្នកផ្ញើឬអ្នកទទួលបានចង្អុលបង្ហាញ លើកលែងតែភាគីណាមួយបានបង្ហាញថាអ្នកអះអាងនោះ ពុំមានទីតាំងអាជីវកម្មនៅទីនោះឡើយ។

ខ. ប្រសិនបើភាគីណាមួយមិនបានចង្អុលបង្ហាញទីកន្លែងអាជីវកម្មជាក់លាក់ណាមួយ ហើយភាគីនោះមានទីតាំងអាជីវកម្មច្រើនជាងមួយកន្លែង ទីតាំងអាជីវកម្មត្រូវកំណត់ថាជាទីកន្លែងដែលមានទំនាក់ទំនងជិតស្និទ្ធជាងគេទៅនឹងកិច្ចសន្យាដែលពាក់ព័ន្ធ ដោយត្រូវពិចារណាផងដែរអំពីកាលៈទេសៈដែលបានដឹងឬពិនិត្យដោយភាគីនៅពេលណាមួយមុនឬក្នុងពេលចុះកិច្ចសន្យា។

គ. សម្រាប់រូបវន្តបុគ្គលដែលពុំមានទីតាំងអាជីវកម្មទេនោះ ទីតាំងអាជីវកម្មសំដៅដល់ទីលំនៅអចិន្ត្រៃយ៍របស់បុគ្គលនោះ។

មិនត្រូវចាត់ទុកថាជាទីតាំងអាជីវកម្មរបស់ភាគីដោយគ្រាន់តែជា៖

- ទីតាំងដែលសម្ភារៈឬឧបករណ៍បច្ចេកវិទ្យានៃប្រព័ន្ធព័ត៌មានត្រូវបានប្រើ
- អាសយដ្ឋានអេឡិចត្រូនិកឬឈ្មោះដែនកម្មសិទ្ធិ(Domain Name) ដែលភ្ជាប់ជាមួយនឹងទីតាំងរបស់ភាគី។

៣១. កំណត់ត្រា(Record) សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារដែលត្រូវបានកត់ត្រាចូលរក្សាទុក ឬបញ្ចូលទៅក្នុងទម្រង់រូបី ឬដែលត្រូវបានរក្សាទុកក្នុងទម្រង់អេឡិចត្រូនិក ជាត្រាសស្នាម ឬទម្រង់ប្រភេទផ្សេងទៀត ហើយដែលអាចទាញយកកំណត់ត្រានោះវិញបានក្នុងទម្រង់ជាក់លាក់ដែលអាចមើលបាន។

៣២. បុគ្គលផ្ដល់សេវា( service provider) សំដៅដល់

(ក) បុគ្គលដែលផ្ដល់សេវាព័ត៌មាននិងសេវាទំនាក់ទំនង រួមមាន ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក ឬការផ្ដល់សេវាតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត។

(ខ) បុគ្គលដែលជាម្ចាស់ បុគ្គលកាន់កាប់ បុគ្គលដំណើរការ បុគ្គលគ្រប់គ្រង ឬបុគ្គលត្រួតពិនិត្យបណ្ដាញស្វិចសាធារណ:(Public Switched Network) ឬបុគ្គលដែលផ្ដល់សេវាទូរគមនាគមន៍។ ឬ

(គ) បុគ្គលផ្សេងទៀតដែលប្រតិបត្តិឬរក្សាទុកទិន្នន័យបម្រើឱ្យសេវាទំនាក់ទំនងអេឡិចត្រូនិកនោះ ឬអ្នកប្រើប្រាស់សេវា។

៣៣. **បុគ្គលផ្ដល់នីតិវិធីសុវត្ថិភាព( Security procedure provider)** សំដៅដល់បុគ្គលបង្កើត ឬផ្ដល់នីតិវិធីសុវត្ថិភាព។

៣៤. **នីតិវិធីសុវត្ថិភាព(Security Procedure)** សំដៅដល់នីតិវិធីដែលកំណត់ដោយច្បាប់ ឬកិច្ចសន្យា ឬការសម្រេចដោយភាគីណាមួយ ហើយដែលត្រូវបានប្រើក្នុងគោលបំណង៖

(ក) ផ្ទៀងផ្ទាត់ថាហត្ថលេខា ទំនាក់ទំនង ឬប្រតិបត្តិការក្នុងប្រព័ន្ធអេឡិចត្រូនិក ពិតជារបស់បុគ្គលនោះ។

(ខ) រកឱ្យឃើញកំហុសឆ្គងឬការកែប្រែនៅក្នុងទំនាក់ទំនងឬក្នុងកន្លែងរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ចាប់តាំងពីពេលជាក់ណាមួយ។

នីតិវិធីសុវត្ថិភាពខាងលើអាចតម្រូវឱ្យប្រើរូបមន្តអាល់ហ្គោរីត(algorithms)ឬកូដ ពាក្យឬលេខសម្រាប់ សម្គាល់អត្តសញ្ញាណ កូដនីយកម្ម សំណួរសម្ងាត់ ឬការទទួលស្គាល់នីតិវិធីណាមួយ ឬក៏ឧបករណ៍សុវត្ថិភាពស្រដៀងគ្នាផ្សេងទៀត។

៣៥. **ព័ត៌មានឬកំណត់ត្រាជាលាយលក្ខណ៍អក្សរ(writing/written)** សំដៅដល់ព័ត៌មានឬកំណត់ត្រាផ្សេងៗទៀតដែលត្រូវបានសរសេរ ចារឹក ឬបោះពុម្ពនៅលើក្រដាសឬសម្ភារៈ ផ្សេងៗទៀត។

៣៦. **អ៊ីមែលឬសារអេឡិចត្រូនិក(E-mail or Electronic Message)** សំដៅដល់សារឬព័ត៌មានដែលត្រូវបានបង្កើតឡើង ឬបញ្ជូន ឬទទួលបានពីប្រព័ន្ធអេឡិចត្រូនិក រួមទាំងឯកសារភ្ជាប់ក្នុងអត្ថបទ រូបភាព សំឡេង វីដេអូ និងកំណត់ត្រាអេឡិចត្រូនិកណាមួយផ្សេងទៀតដែលអាចបញ្ជូនជាមួយសារបាន។

៣៧. **សន្តតិកម្ម(Will)** សំដៅដល់ការផ្ទេរនូវសិទ្ធិនិងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។

៣៨. **ស្វីការ**(Acceptance) សំដៅដល់ការសំដែងឆន្ទៈដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឬ អាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការលើកលែង ប្រភេទ បែបបទ និងលក្ខខណ្ឌនៃការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ និងវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងដើម្បីគ្រប់គ្រងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ។

**មាត្រា២ ..**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដែលធ្វើប្រតិបត្តិការនិងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង/ឬផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីព្រះរាជាណាចក្រកម្ពុជាទៅក្រៅប្រទេស ឬពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ..**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណីព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

**២. បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

**៣. អន្តរការី** សំដៅដល់បុគ្គលដែលផ្តល់សេវាផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**៤. បុគ្គលផ្តល់សេវាទូទាត់** សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាត ឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិក ឬមធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថា ជាការផ្តល់ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដល់សាធារណជន។

**៥. ប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នា ឬទាក់ទងគ្នាតាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬ ឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច អាជ្ញាបណ្ណ លិខិតអនុញ្ញាត ការលើកលែង និងវិញ្ញាបនបត្រ

**មាត្រា៤ ..**

១. ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២. ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងកម្រិតជាតិនិងអន្តរជាតិជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយធ្វើការសម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ។

**មាត្រា៥ ._**

១. អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្ដល់ឱ្យនីតិបុគ្គល និង សាខាក្រុមហ៊ុនបរទេសដែលនឹងធ្វើប្រតិបត្តិការនិងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដូចខាងក្រោម៖

ក. សេវាគេហទំព័រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ខ. សេវាផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

គ. សេវាទីផ្សារអនឡាញ។

ឃ. សេវាគេហទំព័រដេញថ្លៃអនឡាញ។

ង. សេវាស្រដៀងគ្នាផ្សេងទៀតដែលផ្ដល់តាមរយៈកម្មវិធីកុំព្យូទ័រឬឧបករណ៍វៃឆ្លាតសម្រាប់ការជំរុញធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២. លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្ដល់ឱ្យរូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គលដែលនឹងប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងរូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គលដែលប្រើប្រាស់បណ្ដាញសង្គមឬប្រព័ន្ធអេឡិចត្រូនិកជាមធ្យោបាយក្នុងការផ្គត់ផ្គង់ឬទិញ-លក់ទំនិញ និង/ឬសេវា។

៣. ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំពោះរូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គលដែលធ្វើសកម្មភាពឬប្រតិបត្តិការដូចខាងក្រោម៖

ក. ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញឬសេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញឬសេវាដែលមិនមែនជាសំណើបង្កើតកិច្ចសន្យា។

ខ. ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬទូទាត់កម្រៃ ដោយអតិថិជនឬអ្នកប្រើប្រាស់។

គ. ការលក់ទំនិញឬសេវារបស់រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល ដែលមានផលរបរនៅក្រោមកម្រិតផលរបរជាអ្នកជាប់ពន្ធតូច។

ឃ. ការលក់ទំនិញ ឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល។

ង. ការលក់ទំនិញ ឬសេវាដែលជាស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ។

ច. ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន។

ឆ. ការបង្ហាត់បង្រៀន ឬអប់រំអំពីសាសនារបស់រដ្ឋ។

ការបង្ហាត់បង្រៀនដោយសមាគមឬអង្គការមិនមែនរដ្ឋាភិបាល ដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ឬប្រយោល និងសកម្មភាពឬប្រតិបត្តិការដោយស្ថាប័នរដ្ឋក្នុងការផ្ដល់សេវាសាធារណៈ ក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតផងដែរ។

៤. ក្នុងគោលបំណងស្រង់ទិន្នន័យ និងការពារអ្នកប្រើប្រាស់ បុគ្គលដែលត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាត ដូចបានកំណត់ក្នុងកថាខណ្ឌទី៣ខាងលើ ត្រូវជូនដំណឹងមកក្រសួងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អំពីព័ត៌មានដូចខាងក្រោម៖

ក. ប្រភេទប្រតិបត្តិការ។

ខ. ឈ្មោះអាជីវកម្ម។

គ. មធ្យោបាយអេឡិចត្រូនិកដែលបានប្រើប្រាស់។

ឃ. មធ្យោបាយទូទាត់របស់ខ្លួន។ និង

ង. អត្តសញ្ញាណម្ចាស់ លេខទូរសព្ទ និងអាសយដ្ឋានសម្រាប់ទំនាក់ទំនង។

គំរូលិខិតជូនដំណឹងមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

៥. បុគ្គលដែលទទួលបានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ដូចបានកំណត់ក្នុងកថាខណ្ឌទី១ និងទី២ខាងលើ អាចស្នើសុំវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម ដើម្បីបញ្ជាក់អំពីអនុលោមភាព សុវត្ថិភាព និងទំនុកចិត្ត។

៦. រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣នៃមាត្រានេះត្រូវស្ថិតក្រោមនីតិវិធីនៃច្បាប់ស្តីពីសារពើពន្ធជាធរមាន។

## ជំពូកទី៣
## ការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៦ .-**

ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់ដូចខាងក្រោម៖

១.រូបវន្តបុគ្គលដែលមានសិទ្ធិស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក លុះត្រាតែទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មឬចុះបញ្ជីពាណិជ្ជកម្ម និងបានចុះបញ្ជីពន្ធដារ ស្របតាមបទប្បញ្ញត្តិជាធរមាន។

២. រូបវន្តបុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ត្រូវស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម មុនពេលចាប់ផ្តើមអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣. ពេលធ្វើអាជីវកម្ម ត្រូវផ្តល់ព័ត៌មានអប្បបរមា ដូចមានចែងក្នុងកថាខណ្ឌទី១និងទី២នៃមាត្រា២៩នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៃព្រះរាជាណាចក្រកម្ពុជា។

៤. សុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានរយៈពេល២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម ហើយអាចស្នើសុំបន្តសុពលភាពបាន។

៥. បែបបទ ឯកសារតម្រូវ ការបន្តសុពលភាព ការកែប្រែព័ត៌មាន និងលក្ខខណ្ឌក្នុងការផ្ទេរលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៧ .-**

១. នីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេស ដែលជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម មុនពេលចាប់ផ្តើមប្រតិបត្តិការ ហើយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក. បានចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ខ. មានវិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនកម្មសិទ្ធិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

គ. ប្រើមធ្យោបាយឬកម្មវិធីអេឡិចត្រូនិក សម្រាប់ធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ឃ. ប្រព័ន្ធអេឡិចត្រូនិកដែលនឹងត្រូវបានប្រើប្រាស់ ត្រូវមានសុក្រឹត្យភាពដូចមានកំណត់ក្នុងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ង. មានការបញ្ជាក់អំពីមធ្យោបាយទូទាត់។

ច. មានគំរូអាជីវកម្មនិងទម្រង់នៃកិច្ចការពារអ្នកប្រើប្រាស់។

ឆ. ក្នុងករណីនីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេសដែលជាអន្តរការី ត្រូវធ្វើកិច្ចសន្យាជាមួយបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវឱ្យផ្តល់ព័ត៌មានអប្បបរមា អនុលោមតាមកថាខណ្ឌទី១និងទី២នៃមាត្រា ២៩ និងមាត្រា៣៣នៃច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៃព្រះរាជាណាចក្រកម្ពុជា។

២. សុពលភាពនៃអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់អាជ្ញាបណ្ណដោយក្រសួងពាណិជ្ជកម្ម ហើយអាចស្នើសុំបន្តសុពលភាពបាន។

៣. បែបបទ ឯកសារតម្រូវ ការបន្តសុពលភាព ការកែប្រែព័ត៌មាន និងលក្ខខណ្ឌក្នុងការផ្ទេរអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៨ ..**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មឬអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចហើយ អាចស្នើសុំវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម តាមការស្ម័គ្រចិត្ត។

២. បែបបទ ឯកសារតម្រូវ លក្ខណៈវិនិច្ឆ័យ កម្រិតអនុលោមភាពនៃគោលការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៩ ..**

បែបបទនិងនីតិវិធីនៃការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា១០ ..**

រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ដែលបានធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ដូចបានកំណត់ក្នុងជំពូកទី៣នៃអនុក្រឹត្យនេះ ក្នុងរយៈពេលយ៉ាងយូរបំផុត៦(ប្រាំមួយ)ខែ ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៩០ ព.ណ.ជ.ឃ.ព.-ប្រក

# ប្រកាស
## ស្តីពី
## ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការកំណត់ប្រភេទបែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់បែបបទ ឯកសារតម្រូវក្នុងការផ្តល់ ការបន្តសុពលភាព ការធ្វើបច្ចុប្បន្នភាព និងការកែប្រែព័ត៌មាន លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីមានតម្លាភាព និងបង្កលក្ខណៈងាយស្រួលដល់ការស្នើសុំ និងផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

១- **លិខិតអនុញ្ញាត** សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣- **បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេស ដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។

៤- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ដែលមានភារកិច្ចទទួល និងពិនិត្យពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។

៥- **បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិក ដើម្បីផ្គត់ផ្គង់ទំនិញ និង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

**ប្រការ៣.-**

បែបបទ និងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាត ត្រូវបានកំណត់ដូចខាងក្រោម៖

១. រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយត្រូវផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

**ក- សម្រាប់រូបវន្តបុគ្គល**

- លិខិតអនុញ្ញាតប្រកបអាជីវកម្មចេញដោយអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត
- ប័ណ្ណប៉ាតង់ (ប្រសិនបើមាន)
- អត្តសញ្ញាណបណ្ណដែលនៅមានសុពលភាពរបស់បុគ្គលស្នើសុំ
- រូបថត ៤x៦ របស់រូបវន្តបុគ្គល ដែលថតមិនលើសពី៣ខែមុន
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញនិងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ខ- សម្រាប់សហគ្រាសឯកបុគ្គល**

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ប័ណ្ណប៉ាតង់
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

២.បន្ទាប់ពីទទួលបានពាក្យស្នើសុំ មន្ត្រីត្រួតពិនិត្យត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវ ព័ត៌មាន និងឯកសារភ្ជាប់ដែលបានបំពេញ ហើយត្រូវឆ្លើយតបដល់បុគ្គលស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ៤.-**

១.ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំពោះរូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គលដែលធ្វើសកម្មភាពឬប្រតិបត្តិការ ដូចខាងក្រោម៖

ក-ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញ ឬសេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញឬសេវាដែលមិនមែនជាសំណើបង្កើតកិច្ចសន្យា។

ខ-ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬទូទាត់កម្រៃ ដោយអតិថិជនឬអ្នកប្រើប្រាស់។

គ-ការលក់ទំនិញ ឬសេវារបស់រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល ដែលមានផលរបប នៅក្រោមកម្រិតផលរបរជាអ្នកជាប់ពន្ធតូច។

ឃ-ការលក់ទំនិញ ឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល។

ង-ការលក់ទំនិញ ឬសេវាដែលជាស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ។

ច-ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន។

ឆ-ការបង្ហាត់បង្រៀន ឬអប់រំអំពីសាសនារបស់រដ្ឋ។

ការបង្ហាត់បង្រៀនដោយសមាគមដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ ឬប្រយោល និងសកម្មភាពប្រតិបត្តិការដោយស្ថាប័នរដ្ឋ ក្នុងការផ្តល់សេវាសាធារណៈក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតផងដែរ។

២.បុគ្គលស្នើសុំ ត្រូវជូនដំណឹងតាមរយៈគេហទំព័រ www.ecommercelicensing.moc.gov.kh ឬបញ្ជូនមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដែលមានព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ៥.-**

១.នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេស ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយត្រូវផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

ក- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ខ- ប័ណ្ណប៉ាតង់

គ- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ឃ- ឯកសារអំពីមធ្យោបាយទូទាត់ប្រាក់ផ្តល់ ដោយបុគ្គលផ្តល់សេវាទូទាត់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា

ង- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ច- គំរូកិច្ចសន្យារវាងអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវការព័ត៌មានអប្បបរមា (សម្រាប់អន្តរការី)

ឆ- បុគ្គលស្នើសុំត្រូវបំពេញព័ត៌មាន នៅក្នុងតារាងនៃពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

២. បន្ទាប់ពីទទួលបានពាក្យស្នើសុំ មន្ត្រីត្រួតពិនិត្យត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលបានបំពេញ ហើយត្រូវឆ្លើយតបដល់បុគ្គលស្នើសុំក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ៦.-**

១. ក្នុងករណីព័ត៌មាន ឬឯកសារតម្រូវមិនគ្រប់គ្រាន់ និង/ឬមិនត្រឹមត្រូវ បុគ្គលស្នើសុំត្រូវធ្វើការកែតម្រូវ ឬផ្តល់នូវព័ត៌មាន ឬឯកសារតម្រូវបន្ថែមក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការជូនដំណឹងពីមន្ត្រីត្រួតពិនិត្យ។ រយៈពេលនៃការពិនិត្យ និងផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែមគ្រប់គ្រាន់។

២. ក្នុងករណីបុគ្គលស្នើសុំ បានដាក់ព័ត៌មានមិនពិត និង/ឬឯកសារក្លែងបន្លំ ឬខកខានមិនបានកែតម្រូវព័ត៌មាន ឬផ្តល់ឯកសារតម្រូវបន្ថែម ក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី១ មន្ត្រីត្រួតពិនិត្យអាចបដិសេធក្នុងការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់បុគ្គលស្នើសុំ។

**ប្រការ៧.-**

លិខិតអនុញ្ញាត និងអាជ្ញាបណ្ណមានសុពលភាព ដូចខាងក្រោម៖

- លិខិតអនុញ្ញាតមានសុពលភាព ០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម។
- អាជ្ញាបណ្ណមានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់អាជ្ញាបណ្ណដោយក្រសួងពាណិជ្ជកម្ម។

**ប្រការ៨.-**

១- បុគ្គលស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនពេលអស់សុពលភាព។ ទម្រង់នៃពាក្យស្នើសុំបន្តលិខិតអនុញ្ញាតដូចភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥.១ និងបន្តអាជ្ញាបណ្ណដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥.២ នៃប្រកាសនេះ។

២- ក្នុងករណីបុគ្គលដែលបានទទួលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណរួចហើយ តែខកខានមិនបានស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដូចបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ នោះត្រូវបានចាត់ទុកថាបោះបង់ចោលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ហើយបុគ្គលនោះត្រូវដាក់ពាក្យស្នើលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណឡើងវិញ ដូចបានកំណត់ក្នុងប្រការ៣ និងប្រការ៥ ខាងលើ ក្រោយពេលអស់សុពលភាព។

**ប្រការ៩.-**

១- រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ដែលបានផ្លាស់ប្តូរ កែប្រែព័ត៌មាន ឬឯកសារក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលធ្វើការកែប្រែ ត្រូវដាក់ពាក្យស្នើសុំប្តូរលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនៅក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋានអាជីវកម្ម សហគ្រាស ឬក្រុមហ៊ុន
- កម្មវត្ថុអាជីវកម្ម ឬគំរូអាជីវកម្ម (Business Model)
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែន
- គំរូកិច្ចសន្យារវាងអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម
- មធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងជាមួយអតិថិជន។

ការស្នើសុំប្តូរលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦.១។

២- រាល់ការផ្លាស់ប្តូរ ឬកែប្រែព័ត៌មាន ឬឯកសារភ្ជាប់ក្រៅពីចំណុចដែលបានចែងក្នុងកថាខណ្ឌទី១ខាងលើ រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ត្រូវធ្វើបច្ចុប្បន្នភាពជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលធ្វើការកែប្រែ តាមរយៈការបំពេញព័ត៌មាន និងឯកសារដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦.២ ឬតាមរយៈគេហទំព័រ www.ecommercelicensing.moc.gov.kh។

**ប្រការ១០.-**

ក្នុងករណីដែលបុគ្គលបានទទួលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណរួចហើយ មានបំណងផ្អាកជាបណ្តោះអាសន្ននូវសកម្មភាព ឬបញ្ឈប់ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំ មកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ហើយត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៧។

**ប្រការ១១.-**

កម្រៃសេវាដែលត្រូវបង់ចូលជាថវិកាជាតិ ត្រូវផ្អែកតាមការកំណត់ក្នុងប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន គ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋានពន្ធដារ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ